គណៈកម្មាធិការ
សហប្រតិបត្តិការដើម្បីកម្ពុជា
Cooperation Committee
for Cambodia
Comité de Coopération
Pour le Cambodge

# របាយការណ៍ស្តីពី

# ការប៉ាន់ប្រមាណតម្រូវការ ការកសាងសមត្ថភាព
# អង្គការសហគមន៍មូលដ្ឋាន



**មករា ២០១៨**

ផ្តល់ថវិកាដោយ៖

Brot
für die Welt

# មាតិកា


អារម្ភកថា ........................................................................................................................3
សេចក្តីថ្លែងអំណរគុណ ........................................................................................................5
សេចក្តីសង្ខេប.....................................................................................................................3
ពាក្យកាត់ ..........................................................................................................................9

**១. សេចក្តីផ្តើម** ...................................................................................................................10

**២. គោលបំណង និងវិសាលភាព** .......................................................................................11

**៣. វិធីសាស្រ្ត**.....................................................................................................................13

**៤. ការសិក្សាអំពីអង្គការសហគមន៍មូលដ្ឋាននៅកម្ពុជា តាមរយៈឯកសារស្រាវជ្រាវ និងរបាយការណ៍ពីអង្គការផ្សេងៗ** ....17

**៥. លទ្ធផលចេញពីការវាយតម្លៃលើតម្រូវការនៃការកសាងសមត្ថភាព** .....................................28

៥.១ លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន.............................................36
៥. ២ ការទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ.............................................................37
៥.៣ សមាជិកភាព និងការគ្រប់គ្រងសមាជិក...............................................................................40
៥.៤ ការគ្រប់គ្រងហិរញ្ញវត្ថុ .......................................................................................................42
៥.៥ គណនេយ្យភាព និងតម្លាភាព...............................................................................................43
៥.៦ ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ .........................................................................43
៥.៧ យុទ្ធសាស្រ្ត និងការធានានិរន្តរភាព ....................................................................................44
៥.៨ ការពង្រឹងសមត្ថភាព និងការយល់ដឹង ..................................................................................45

**៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍**.........................................................................................48

អនុសាសន៍សម្រាប់ពង្រឹងអង្គការសហគមន៍មូលដ្ឋាន និងកសាងសមត្ថភាព .......................50

**ឯកសារយោង** .....................................................................................................................55

ឧបសម្ព័ន្ធ១៖ រូបភាពសកម្មភាពនៃដំណើរពិគ្រោះយោបល់......................................................57
ឧបសម្ព័ន្ធ២៖ បញ្ជីសំណួរទី១ ...............................................................................................59

## អារម្ភកថា

របាយការណ៍ស្តីពីការប៉ាន់ប្រមាណតម្រូវការ ការកសាងសមត្ថភាពរបស់ អង្គការសហគមន៍មូលដ្ឋាននេះ ត្រូវបានចងក្រងឡើងដោយផ្អែកលើការសិក្សាអំពី ដំណើរការប៉ាន់ប្រមាណតម្រូវការ ការកសាងសមត្ថភាព របស់អង្គការសហគមន៍មូលដ្ឋាន តាមជំហានសំខាន់ៗនៃដំណើរការប៉ាន់ប្រមាណ ដូចជា៖ ការត្រួតពិនិត្យឯកសារ និងរបាយការណ៍ពាក់ព័ន្ធដែលមានស្រាប់ ការប្រជុំពិគ្រោះយោបល់តាមរយៈសិក្ខាសាលាថ្នាក់ជាតិ ការផ្ញើបញ្ជីសំណួរទៅអ្នកពាក់ព័ន្ធដើម្បីបំពេញ ការពិគ្រោះយោបល់តាមការទំនាក់ទំនងទូរស័ព្ទ និងការចុះមូលដ្ឋានជួបពិភាក្សាដោយផ្ទាល់ ជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ អង្គការសហគមន៍មូលដ្ឋាន និងអាជ្ញាធរដែនដី ហើយធ្វើការពិគ្រោះយោបល់ចុងក្រោយជាមួយអង្គការជាតិ និងអន្តរជាតិនៅភ្នំពេញ។

ខ្លឹមសារនៃរបាយការណ៍នេះ អធិប្បាយពីការរកឃើញនៃការវាស់វែងផ្នែកសំខាន់ៗ ដែលពាក់ព័ន្ធទៅនឹងដំណើរការផ្សព្វផ្សាយ ការចងក្រងក្រុម រៀបចំរចនាសម្ព័ន្ធគ្រប់គ្រង ការបង្កើតលក្ខន្តិកៈ និងគោលការណ៍នានាសម្រាប់ធ្វើការគ្រប់គ្រង ការចុះបញ្ជី ព្រមទាំងដំណើរការនានា របស់អង្គការសហគមន៍មូលដ្ឋាន ដែលឆ្ពោះទៅរកប្រសិទ្ធភាព និរន្តរភាពទាំងហិរញ្ញវត្ថុ និងស្ថាប័ន ។ល។ និយាយជារួម របាយការណ៍នេះ បង្ហាញពីទិដ្ឋភាពទាំងមូល នៃការប៉ាន់ប្រមាណតម្រូវការ ការកសាងសមត្ថភាពសមាគម អង្គការសហគមន៍មូលដ្ឋានទាំងអស់ ដែលគ្របដណ្តប់រាល់ទិដ្ឋភាព ឬផ្នែកទាំងអស់នៃការកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាននៅកម្ពុជា។ ក្នុងនោះមានការអធិប្បាយពីទិដ្ឋភាព ឬផ្នែកសំខាន់ៗ ដែលជាតម្រូវការ ចំណុចខ្លាំង ចំណុចខ្សោយ ឧបសគ្គ និងឱកាសទាំងឡាយ ក្នុងដំណើរការកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាន ព្រមទាំងធ្វើការអធិប្បាយលំអិតសម្រាប់លទ្ធផលរកឃើញ ដោយវិភាគតាមដ្យាក្រាម ការដាក់ពិន្ទុ និងជាភាគរយ ព្រមលើកឡើងនូវអនុសាសន៍ ដើម្បីបង្កើនសមត្ថភាពដល់អង្គការសហគមន៍មូលដ្ឋាន ឱ្យឈានដល់ចំណុចចុងក្រោយមួយ ដែលពួកគេអាចឈរដោយខ្លួនឯង មានភាពឯករាជ្យ ហើយមាននិរន្តរភាពទាំងហិរញ្ញវត្ថុ និងស្ថាប័ន។

របាយការណ៍នេះ នឹងផ្តល់ជាវិភាគទានផងដែរ ក្នុងការត្រួសត្រាយដល់អ្នកអភិវឌ្ឍន៍ ទាំងឡាយដូចជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ក្រសួង/ស្ថាប័នរបស់រាជរដ្ឋាភិបាល និងស្ថាប័នសាធារណៈដទៃទៀត ក្នុងការកសាងសមត្ថភាព អង្គការសហគមន៍មូលដ្ឋាន ដែលជាក្រុមគោលដៅរបស់ខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ ស្របតាមគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អ របស់អង្គការសហគមន៍មូលដ្ឋាន (ដោយអង្គការ គ.ស.ក ឆ្នាំ២០១៧)។ ទោះជាយ៉ាងណា វិធីសាស្ត្រ និងឧបករណ៍ ដែលបានណែនាំក្នុងរបាយការណ៍នេះ លើកទឹកចិត្តស្នើឱ្យមានការបត់បែនក្នុងពេលប្រើ

ប្រាស់ យោលតាមស្ថានភាពសង្គម និងភូមិសាស្ត្រ ដើម្បីអាចឱ្យការកសាងសមត្ថភាព របស់អង្គការសហគមន៍មូលដ្ឋានទទួលបាននូវប្រសិទ្ធភាព និងគុណភាពខ្ពស់។

ការប៉ាន់ប្រមាណនៃតម្រូវការ ការកសាងសមត្ថភាព អង្គការសហគមន៍មូលដ្ឋាននេះ ត្រូវបានធ្វើឡើងនៅចំពេលល្អបំផុត ខណៈដែលមានព្រួយបារម្ភកាន់តែខ្លាំងឡើង ដោយអង្គការសហគមន៍មូលដ្ឋានខ្លួនឯង និងអ្នកជំនាញការផងដែរ ពីស្ថានភាពវិវឌ្ឍន៍ថ្មីៗ នៃនយោបាយនៅកម្ពុជា ជាពិសេសការរឹតត្បិតសកម្មភាព របស់អង្គការជាតិមិនមែនរដ្ឋាភិបាល អង្គការសហគមន៍មូលដ្ឋាន ពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ដូចដែលបានលើកឡើងម្តងហើយ ម្តងទៀតនៅឯសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ព្រមទាំងព្រឹត្តិការណ៍នយោបាយថ្មីៗ។ របាយការណ៍ នៃការប៉ាន់ប្រមាណនៃតម្រូវការការកសាងសមត្ថភាព អង្គការសហគមន៍មូលដ្ឋាននេះ នឹងត្រូវបានយកទៅប្រើប្រាស់ជាឧបករណ៍សម្រាប់ធ្វើការរៀបចំចងក្រងគោលការណ៍សម្របសម្រួល និងឯកសារមេរៀនសម្រាប់ធ្វើការបណ្តុះបណ្តាលដល់ក្រុមការងារអ្នកសម្របសម្រួលអង្គការសហគមន៍មូលដ្ឋាន ព្រមទាំងជនបង្គោល ដែលបានជ្រើសរើសមកពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ដែលគាំទ្រអង្គការសហគមន៍មូលដ្ឋាន។ គោលបំណងនៃការតាក់តែង គោលការណ៍សម្របសម្រួលនេះឡើង គឺដើម្បីបង្កលក្ខណៈងាយស្រួល និងជាឧបករណ៍ជំនួយស្មារតីដល់អ្នកអភិវឌ្ឍន៍ទាំងឡាយណា ដែលមានតួនាទីជាអ្នកសម្របសម្រួលក្នុងសកម្មភាពបណ្តុះបណ្តាលដល់អង្គការសហគមន៍មូលដ្ឋាន ជាពិសេសទាក់ទិនទៅនឹង ការពង្រឹងស្ថាប័ន និងការកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាន ឱ្យមានប្រតិបត្តិល្អ និងមាននិរន្តរភាពទាំងស្ថាប័ន និងហិរញ្ញវត្ថុ។ ដោយឡែក សៀវភៅគោលការណ៍សម្របសម្រួលបណ្តុះបណ្តាលស្តីពីការកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាននេះ ក៏នឹងជួយផងដែរ ក្នុងការពង្រឹងពង្រីក និងបង្កើនជំនាញដល់អ្នកសម្របសម្រួលខ្លួនឯង ក្នុងការប្រើប្រាស់ឯកសារនេះ ជាមូលដ្ឋានក្នុងការផ្តួចផ្តើមបង្កើតនូវវិធីសាស្ត្រថ្មីផ្សេងៗ ដែលសមស្របតាមបរិយាកាសដូចជា ស្ថានភាព លទ្ធភាព និងសមត្ថភាពរបស់អ្នកចូលរួម ដែលជាអង្គការសហគមន៍មូលដ្ឋាន។

ជាចុងក្រោយ ក្នុងនាមអ្នកស្រាវជ្រាវ សូមអនុញ្ញាតិបញ្ជាក់ថា ឯកសារនេះ មិនមែនជាគោលការណ៍រឹងមាំ ដែលមិនអោយមានការបត់បែននោះទេ យើងខ្ញុំសូមលើកទឹកចិត្ត និងការប្រើប្រាស់ឯកសារផ្សេងៗ ដែលពាក់ពន្ធ័ដើម្បីជាជំនួយស្មារតី ព្រមទាំងភាពបត់បែនក្នុងការប្រើប្រាស់វិធីសាស្ត្រដើម្បីអោយមានប្រសិទ្ធិភាព ហើយសង្ឃឹមយ៉ាងមុតមាំថា របាយការណ៍ការនេះ នឹងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ជាប្រយោជន៍ដល់អង្គការសហគមន៍មូលដ្ឋានទាំងឡាយក្នុងប្រទេស កម្ពុជា ស្របតាមគោលការណ៍នានា ដែលមានស្រាប់ ក្នុងគោលបំណងពង្រឹងស្ថាប័នរបស់ពួកគេឱ្យមានភាពរឹងមាំ ហើយសមត្ថភាពរបស់ពួកគេមានការកើនឡើង ឈរលើស្មារតីឯករាជ្យម្ចាស់ការ និងនិរន្តរភាព។

## សេចក្តីថ្លែងអំណរគុណ

សូមថ្លែងអំណរគុណជាពិសេសដល់ តំណាងក្រសួងរាជរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អន្តរជាតិ និងអង្គការសហគមន៍មូលដ្ឋាន ព្រមទាំងសមាគមទាំងអស់ ជាពិសេសតំណាងអង្គការសហគមន៍មូលដ្ឋាន ដែលបានអញ្ជើញមកពីភូមិ ឃុំ ស្រុក និងខេត្តឆ្ងាយៗ ក្នុងការចូលរួមយ៉ាងសស្រាក់សស្រាំ ក្នុងដំណើរការ ពិគ្រោះយោបល់ស្តីពី ការប៉ាន់ប្រមាណតម្រូវការ ការកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាន តាមរយៈសិក្ខាសាលាជាតិ នៅក្រសួងបរិស្ថាន កាលពីថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៧កន្លងមកនេះ[1]។

យើងខ្ញុំសូមថ្លែងអំណរគុណ ដល់ថ្នាក់ដឹកនាំអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ មន្ត្រីជំនាញ អាជ្ញាធរដែនដី ព្រមទាំងគណៈកម្មការគ្រប់គ្រង និងសមាជិកសមាជិកាអង្គការសហគមន៍មូលដ្ឋាន តាមខេត្តនានា ក្នុងប្រទេសដូចជា នៅខេត្តបាត់ដំបង សៀមរាប កំពង់ធំ ក្រចេះ ស្ទឹងត្រែង មណ្ឌលគីរី ព្រៃវែង កំពត កំពង់សោម កោះកុង និងពោធិ៍សាត់ ដែលបានអនុញ្ញាតឱ្យជួបប្រជុំ ពិគ្រោះយោបល់តាមផែនការដែលបានស្នើសុំ ព្រមទាំងបានជួយបំពេញក្នុងបញ្ជីសំណួរ។ សូមអរគុណផងដែរ ដល់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលជាសមាជិករបស់ អង្គការ គ.ស.ក ដែលបានចំណាយពេលវេលា កម្លាំង ស្មារតីចូលរួមយ៉ាងសកម្ម ក្នុងដំណើរការពិគ្រោះយោបល់ ផ្តល់អនុសាសន៍/សំណូមពរផ្សេងៗ ប្រកបដោយអត្ថន័យបំផុត សម្រាប់បេសកម្មដ៏ថ្លៃថ្លានេះ។

របាយការណ៍នេះបានដឹកនាំការស្រាវជ្រាវ និងរៀបចំចេញជាសេចក្តីព្រាងចុងក្រោយដោយ លោក យុន ប៊ុនណាត អ្នកប្រឹក្សាឯករាជ្យ និងសមាជិកក្រុមស្រាវជ្រាវ។ ហើយចុងក្រោយមានការកែសម្រួលពីក្រុមការងារនៃអង្គការ គ.ស.ក។ សូមឧទ្ទិសសមិទ្ធិផលនេះ ជាប្រយោជន៍ដល់អង្គការសហគមន៍មូលដ្ឋានទាំងអស់ រួមទាំងរាជរដ្ឋាភិបាល ស្ថាប័នសាធារណៈនានា អង្គការមិនមែន រដ្ឋាភិបាលក្នុងស្រុក អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ក្នុងប្រទេសកម្ពុជា។ សង្ឃឹមថា របាយការណ៍ នេះនឹងអាចប្រើប្រាស់យ៉ាងទូលំទូលាយ ជាឧបករណ៍មួយសម្រាប់ជាមូលដ្ឋាន ក្នុងការរៀបចំចងក្រងផែនការ កសាងសមត្ថភាព និងការបណ្តុះបណ្តាលដល់សមាគម និងអង្គការសហគមន៍មូលដ្ឋាន ប្រកបដោយគុណភាព និងប្រសិទ្ធភាព។

---

[1] ដោយមានអញ្ជើញអោយចូលរួម ពីតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន១០ និងអង្គការសហគមន៍មូលដ្ឋានចំនួន៥៦ មកពីខេត្ត ក្រុងចំនួន១៣ ព្រមទាំងមន្ត្រីក្រសួងពាក់ពន្ធ័ចំនួន៥ស្ថាប័ន ដូចជាក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលមានអ្នកចូលរួមសរុបចំនួន៧៨នាក់។

## ខ្លឹមសារសង្ខេប

សហគមន៍នៅក្នុងរបាយការណ៍នេះ គឺត្រូវបានហៅថា អង្គការសហគមន៍មូលដ្ឋាន។ អង្គការសហគមន៍មូលដ្ឋាន ត្រូវបានកំណត់និយមន័យសំដៅលើ ក្រុមប្រជាពលរដ្ឋ អាចជាក្រុមតូច ក្រុមមធ្យម និងក្រុមធំ ដែលត្រូវបានចងក្រងឡើងដោយសហគមន៍ខ្លួនឯង ក្នុងគោលបំណងបម្រើឱ្យក្នុងវិស័យសង្គម សេដ្ឋកិច្ច ធនធានធម្មជាតិ កសិកម្ម ឧស្សាហកម្ម សុខាភិបាល ជំនឿសាសនា និងឥណទានជនបទជាដើម។ល។ សហគមន៍ទាំងអស់នោះ ត្រូវបានចងក្រង និងបង្កើតឡើង ដើម្បីជួយដល់ពួកគេ ក្នុងការកៀងគកម្លាំង អំណាចនៃការសម្រេចចិត្ត សម្លេង តម្លៃសេដ្ឋកិច្ច និងសង្គម ក្នុងចំណោមពួកគេផ្ទាល់ ដើម្បីជម្រះនូវការលំបាក និងឧបសគ្គនានា ដែលបានជួបប្រទះកន្លងមក បច្ចុប្បន្ន និងអនាគត (របាយការណ៍វាយតម្លៃគម្រោង របស់អង្គការ Concern Worldwide ឆ្នាំ២០០១ ដោយ PD Hardcasetle, United Kingdom)។

ទោះបីយ៉ាងដូច្នោះក្តី សមាគម អង្គការសហគមន៍មូលដ្ឋាន គឺសំដៅទៅលើ ក្រុម សមាគម សហគមន៍ទាំងឡាយណាដែលមានរចនាសម្ព័ន្ធច្បាស់លាស់ មានលក្ខន្តិកៈ បទបញ្ញាផ្ទៃក្នុង សមាជិក សមាជិកា និងផែនការប្រតិបត្តិ។ល។ និង។ល។ អាចជាផ្លូវការ និងក្រៅផ្លូវការ ព្រមទាំងអាចទទួលស្គាល់ ឬមិនទទួលស្គាល់ដោយអាជ្ញាធរដែនដី និងស្ថាប័នជំនាញ ព្រមទាំងអាចក្រោមការឧបត្ថម្ភ ឬដោយគ្មានការឧបត្ថម្ភពីអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ឬដៃគូអភិវឌ្ឍន៍[2] ។

អង្គការសហគមន៍មូលដ្ឋានជាទូទៅមានរចនាសម្ព័ន្ធគ្រប់គ្រង និងចាត់ចែងតាមបែបផែន និងវិស័យនីមួយៗ ឧទាហរណ៍សហគមន៍កសិកម្ម ត្រូវបានដឹកនាំដោយក្រុមប្រឹក្សាភិបាល និងគណៈកម្មការដែលមានសមាសភាពមកពីសមាជិក សមាជិកា ដែលជាអ្នកដាក់ភាគហ៊ុន (គោលការណ៍ណែនាំក្នុងការបង្កើតសហគមន៍កសិកម្ម ដោយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ) ខណៈដែលសហគមន៍តំបន់ការពារធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍អេកូទេសចរណ៍ធម្មជាតិ។ល។ ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយគណៈកម្មការមួយ ដែលត្រូវបានបង្កើតឡើងដោយការបោះឆ្នោត និងជាចំនួនសេស (គោលការណ៍ណែនាំស្តីពី និតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ ដោយក្រសួងបរិស្ថាន ឆ្នាំ២០១៧ គោលការណ៍ណែនាំស្តីពីសហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍អេកូទេសចរណ៍ធម្មជាតិ ដោយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ឆ្នាំ២០០៦)។ ទោះបីជាអង្គការសហគមន៍មូលដ្ឋាន មានប្រតិបត្តិការ និងចរិតលក្ខណៈខុសៗក្តី តែដើម្បីធ្វើឱ្យអង្គការសហគមន៍មូលដ្ឋានទាំងអស់នោះ មានការប្រតិបត្តិល្អ គេត្រូវតែអនុវត្តតាមគោលការណ៍ស្មគ្រ័ចិត្តទាំងប្រាំបី ដែលបានចែងក្នុងសៀវភៅណែនាំស្តីពីការប្រតិបត្តិល្អ របស់អង្គការសហា

[2] គោលការណ៍ណែនាំ ពីការបង្កើតសហគមន៍មូលដ្ឋាន របស់គម្រោងអង្គការ Oxfam GB/ STG ។

គមន៍មូលដ្ឋាន ដែលបានបោះពុម្ពផ្សាយដោយ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ.ស.ក) មានដូចជា៖ លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន ការទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ សមាជិកភាព និងការគ្រប់គ្រងសមាជិក ការចាត់ចែងហិរញ្ញវត្ថុ គណនេយ្យភាព និងតម្លាភាព ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ យុទ្ធសាស្រ្ត និងការធានានិរន្តរភាព ការពង្រឹងសមត្ថភាព និងការយល់ដឹង ព្រមទាំងគោលការណ៍បន្ថែមចំនួនបីទៀត ដែលបានរកឃើញក្នុងពេលសិក្សាស្រាវជ្រាវនេះមានដូចជា ការយល់ដឹងពីទស្សនៈសហគមន៍ ភាពជាមេដឹកនាំ និងការអនុវត្តតាមតួនាទី និងភារកិច្ច។

ជារួម អង្គការសហគមន៍មូលដ្ឋានមួយចំនួនធំ ដែលមានភាពរឹងមាំ និងរីកចម្រើនបាន គឺអាស្រ័យនឹងការជ្រើសរើសថ្នាក់ដឹកនាំសហគមន៍បានត្រឹមត្រូវ តាមលក្ខណៈសម្បត្តិដូចជា មានឆន្ទៈក្នុងការបំពេញកិច្ចការដែលផ្តល់ផលប្រយោជន៍រួម មានសមត្ថភាពបំពេញការងារបានល្អ មានភាពអត់ធ្មត់ យោគយល់ និងគំនិតផ្តួចផ្តើម ព្រមទាំងសកម្មក្នុងការបំពេញតាមតួនាទី និងភារកិច្ចជាដើម។ល។ មានការទទួលស្គាល់យ៉ាងទូលំទូលាយថា ការបំពេញតាមតួនាទី និងភារកិច្ចរបស់ថ្នាក់ដឹកនាំ អង្គការសហគមន៍មូលដ្ឋានអាចមានភាពប្រសើរឡើង ខណៈដែលពួកគេ ត្រូវបានធ្វើការបណ្តុះបណ្តាល កសាងសមត្ថភាពជាលំដាប់លំដោយ ស្របតាមម្រូវការជាក់ស្តែង ដើម្បីធ្វើឱ្យមានការផ្លាស់ប្តូរអាកប្បកិរិយា និងឥរិយាបថស្របតាមតម្រូវការ។ ទោះបីជាយ៉ាងដូច្នោះក៏ដោយ ការជួយសម្របសម្រួលអង្គការសហគមន៍មូលដ្ឋាន ដើម្បីអាចឱ្យពួកគេចងជាបណ្តាញ នៅតែជារបៀបវារៈមួយមានសារៈសំខាន់ និងអាទិភាព ដើម្បីអាចឱ្យពួកគេធ្វើការជាមួយគ្នា បង្កើនសម្លេង ផ្តល់អំណាច និងកម្លាំងខ្លាំងឡើង ក្នុងការលើកយកនូវតម្រូវការសំខាន់ៗមកដាក់ជាផែនការ ការបញ្ចុះបញ្ចូល និងការតស៊ូមតិ ដោយសន្តិភាព ទៅស្ថាប័នដែលពាក់ព័ន្ធ ដើម្បីឆ្លើយតបទៅនឹងត្រូវការនោះ យ៉ាងមានប្រសិទ្ធភាព និងអាចទទួលយកបាន។ ទន្ទឹមនឹងនោះ អង្គការជាតិនានា ឬដៃគូអភិវឌ្ឍន៍ គួរតែបង្កើតឱ្យមានផែនការដកថយរបស់ខ្លួន ឱ្យបានច្បាស់លាស់ និងត្រឹមត្រូវ ដើម្បីកាត់បន្ថយនូវភាពពឹងពាក់ដោយអង្គការសហគមន៍មូលដ្ឋាន។ ពួកគេគួរតែផ្តោតការយកចិត្តទុកដាក់ លើការកសាងសមត្ថភាព ថ្នាក់ដឹកនាំអង្គការសហគមន៍មូលដ្ឋាន ជាជាងធ្វើការជំនួស ឬមិនផ្តល់ឱកាសគ្រប់គ្រាន់ ឱ្យពួកគេបំពេញការងារ និងភារកិច្ចរបស់ពួកគេផ្ទាល់។

ផែនការបន្ត បន្ទាប់ពីការផលិតរបាយការណ៍ប៉ាន់ប្រមាណនេះ សៀវភៅគោលការណ៍សម្របសម្រួលបណ្តុះបណ្តាលស្តីពីការពង្រឹងស្ថាប័ន និងកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាននឹងត្រូវបានចងក្រងឡើង បន្ទាប់ពីការសិក្សាពីតម្រូវការកសាងសមត្ថភាព របស់អង្គការសហគមន៍មូលដ្ឋាន ត្រូវបានបញ្ចប់។ ក្នុងដំណើរការសិក្សាពីតម្រូវការកសាងសមត្ថភាព របស់អង្គការ សហគមន៍មូលដ្ឋាន យើងបានធ្វើការឆ្លុះបញ្ចាំង ព្រមទាំងរកឃើញចំណុចធ្វើឱ្យប្រសើរឡើង របស់អង្គការសហគមន៍មូលដ្ឋាននៅកម្ពុជា មានចំនួន១០ចំណុចចម្បងៗ ដែលចំណុចដែលបានរកឃើញទាំងអស់នោះ នឹងក្លាយទៅជាប្រធានបទ បណ្តុះបណ្តាលមានជាអាទ៍៖ លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហ

គមន៍មូលដ្ឋាន ការទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ សមាជិកភាព និងការគ្រប់គ្រងសមាជិក ការគ្រប់គ្រងហិរញ្ញវត្ថុ គណនេយ្យភាព និងតម្លាភាព ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ យុទ្ធសាស្រ្ត និងការធានានិរន្តរភាព ការពង្រឹងសមត្ថភាព និងការយល់ដឹង ភាពជាអ្នកដឹកនាំសហគមន៍ និង តួនាទី និងការគោរពតាម តួនាទី និងភារកិច្ចរបស់គណៈកម្មការដឹកនាំ និងគ្រប់គ្រង។

## ពាក្យកាត់

| | |
|---|---|
| OXFAM GB | អង្គការអុកហ្វាមចក្រភពអង់គ្លេស |
| គ.ស.ក | អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា |
| STG | ស្ទឹងត្រែង |
| RECOFTC | មជ្ឈមណ្ឌលបណ្តុះបណ្តាលសហគមន៍ព្រៃឈើ |
| LWD | អង្គការជីវិតថ្លៃថ្នូ |
| FACT | អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល |
| SARF | អង្គការគាំទ្រកសិករជនបទ |
| FAO | អង្គការស្បៀង និងកសិកររបស់សហប្រជាជាតិ |
| GTZ | កិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ |
| MoE | ក្រសួងបរិស្ថាន |
| FA | រដ្ឋបាលព្រៃឈើ |
| FiA | រដ្ឋបាលជលផល |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| AFD | អង្គការសកម្មភាពដើម្បីអភិវឌ្ឍន៍ |
| EPDO | អង្គការការពារបរិស្ថាន និងអភិវឌ្ឍន៍ |
| PK | អង្គការពន្លឺកុមារ |
| CRDT | អង្គការក្រុមអភិវឌ្ឍន៍កម្ពុជា |

## ១. សេចក្តីផ្តើម

ច្រើនទសវត្សរ៍មកហើយ អង្គការសហគមន៍មូលដ្ឋាន ត្រូវបានសម្របសម្រួល ចងក្រង និងបង្កើតឡើងក្នុងរូបភាពផ្សេងៗ យោងតាមវិស័យ និងតម្រូវការជាមូលដ្ឋាន ជាពិសេស ដើម្បីបម្រើឱ្យវិស័យសេដ្ឋកិច្ច និងសង្គម ។ល។ គំនិតនៃការបង្កើតអង្គការសហគមន៍មូលដ្ឋាន នោះក្នុងរូបភាពជាក្រុមតូច ក្រុមមធ្យម ក្រុមធំ ឬជាសមាគម ត្រូវបានលេចចេញឡើងក្នុងចំណោមអ្នកនយោបាយ អ្នកស្រាវជ្រាវ អ្នកវិទ្យាសាស្រ្ត និងអ្នកជំនាញការនានា នៅក្នុងប្រទេស និងក្រៅប្រទេស។ ទោះបីការបង្កើតអង្គការសហគមន៍មូលដ្ឋានក្នុងទិដ្ឋភាព និងរូបភាពខុសៗគ្នាបែបនេះក្តី ក៏គោលដៅចម្បងនៃការបង្កើតនេះ មិនសូវជាខុសគ្នាប៉ុន្មានទេ។ យោងតាមបទពិសោធន៍ក្នុងកិច្ចការនេះ អ្នកជំនាញការជាតិថ្នាក់តំបន់ និងអន្តរជាតិលើកឡើងថា គោលដៅចម្បងនៃការបង្កើតអង្គការសហគមន៍មូលដ្ឋាន គឺដើម្បីកៀរគរធនធាន ហិរញ្ញវត្ថុ សម្លេង ឆន្ទៈ និងស្មារតី ដើម្បីសម្រេចនូវគោលបំណងអ្វីមួយដែលពាក់ព័ន្ធទៅនឹងតម្លៃ សេដ្ឋកិច្ច សង្គម ជំនឿសាសនា ។ល។ ដោយឈរលើគោលការណ៍ ចង្កឹះមួយអាចកាច់បាក់ តែចង្កឹះមួយបាច់មិនអាចកាច់បាក់ ឬសាមគ្គីជាកម្លាំង ឬសម្លេងមួយឮបានតិច តែសម្លេងច្រើនឮបានឆ្ងាយ និងខ្លាំង។ល។

យោងតាមលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះបានឱ្យដឹងថា សហគមន៍មូលដ្ឋាននៅកម្ពុជា មិនមែនត្រូវបានសម្របសម្រួលបង្កើតឡើង ដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការអន្តរជាតិ ឬដៃគូអភិវឌ្ឍន៍ណាមួយ តែប៉ុណ្ណោះទេ តាមការពិត អង្គការសហគមន៍មូលដ្ឋានត្រូវបានបង្កើតតាំងពីឆ្នាំ១៩៧៥ ដែលគេឱ្យឈ្មោះថា សហករណ៍ និងក្រោយមកទៀត នៅជំនាន់រដ្ឋកម្ពុជា ដែលគេហៅថា ក្រុមប្រវាស់ដៃ ឬក្រុមដប់ខ្នង។ល។ អង្គការសហគមន៍មូលដ្ឋានត្រូវបានបង្កើតយ៉ាងទូលំទូលាយជាបន្តបន្ទាប់ នោះក៏ដោយសារអំណាចរបស់ក្រុម ឬសហគមន៍ទាំងអស់នោះ មានឥទ្ធិពលជាវិជ្ជមាន ដល់តម្លៃសេដ្ឋកិច្ច និងសង្គម[3]។

ទោះបីយ៉ាងណា ការសម្របសម្រួលបង្កើតក្រុម ឬសហគមន៍កន្លងមកហាក់ដូចជា មិនសូវគិត ឬពិបាកធ្វើអោយមាននិរន្តរភាព។ ភាគច្រើនគឺឱ្យតម្លៃលើផលប្រយោជន៍រយៈពេលខ្លី ឬមធ្យម ហើយបន្ទាប់មកក្រុម ឬសហគមន៍ទាំងអស់នោះ ក៏រសាយបាត់ទៅវិញ បន្ទាប់ពីគោលដៅ ឬគោលបំណងរបស់ពួកគេត្រូវបានសម្រេចពី៣ទៅ៥ឆ្នាំ[4]។ អង្គការសហគមន៍មូលដ្ឋានត្រូវបានសម្របសម្រួលចងក្រងកាន់តែមានបរិមាណច្រើន ហើយសកម្មភាពនិរន្តរភាពមួយចំនួនត្រូវបានបញ្ចូលទៅក្នុងដំណើការ

[3] យោងតាមមតិ របស់គណៈកម្មការគ្រប់គ្រងសហគមន៍នេសាទ និងអេកូទេសចរណ៍ធម្មជាតិត្រពាំងសង្កែ ខេត្តកំពត ក្នុងកំឡុងពេលពិគ្រោះយោបល់។

[4] យោងតាមលទ្ធផលនៃការពិគ្រោះយោបល់ជាមួយសហគមន៍កសិកម្មប៊ូមានជ័យ ស្រុកថ្មគោល ខេត្តបាត់ដំបង ក្នុងកំឡុងពេលពិគ្រោះយោបល់នេះ។

នៃការបង្កើតនោះ ដូចជា៖ ការរៀបចំរចនាសម្ព័ន្ធឱ្យមានភាពរឹងមាំ បង្កើតឱ្យមានលក្ខន្តិក: បទបញ្ញាផ្ទៃក្នុង ព្រមទាំងការចុះបញ្ជី ដើម្បីឱ្យមានការទទួលស្គាល់ពីរាជរដ្ឋាភិបាលជាដើម។ល។ ចូលដល់យុគសម័យថ្មីនេះ យុទ្ធសាស្ត្របានផ្តោតការយកចិត្តទុកដាក់លើសមភាព និងយុត្តិធមិសង្គម ព្រមទាំងចីរភាពអង្គការសហគមន៍មូលដ្ឋាន។ នេះមិនមែនជាពេលវេលាឆាប់ពេកទេ ខណៈដែលអង្គការសហគមន៍មូលដ្ឋានត្រូវប្តូរទស្សនៈវិស័យ និងគោលដៅមករកការរបត់ថ្មីបែបនេះ តែទោះបីយ៉ាងដូច្នោះក៏ដោយ ការផ្លាស់ប្តូររបត់ថ្មីនេះ បានធ្វើឱ្យអង្គការសហគមន៍មូលដ្ឋានជួបនូវឧបសគ្គ និងភាពប្រឈមមួយចំនួន ជាពិសេសការផ្លាស់ប្តូរមួយ ដែលមិនស្ថិតក្រោមការគ្រប់គ្រង និងត្រៀមខ្លួនបានរួចរាល់ ជាពិសេស ឱកាសនៃការពង្រឹងស្ថាប័ន ព្រមទាំងការកសាងសមត្ថភាពជាមុន។ល។ និង។ល។

អង្គការសហគមន៍មូលដ្ឋាន និងអ្នកជំនាញការទទួលស្គាល់នៅឯសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៧ នៅឯក្រសួងបរិស្ថានថា ដើម្បីអាចឱ្យពួកគេគ្រប់គ្រងស្ថានការណ៍នៃការផ្លាស់ប្តូររបត់សង្គមថ្មីបាន គឺការពង្រឹងស្ថាប័ន និងការកសាងសមត្ថភាពពួកគេ ទៅតាមតម្រូវការ ដោយចាប់ផ្តើមពីជំនាញ ចំណេះដឹង និងបទពិសោធន៍ ដែលគេមាន បន្ទាប់មកផ្តល់ចំណេះដឹង ជំនាញ និងបទពិសោធន៍ ដែលជាតម្រូវការពិតប្រាកដ ដែលពួកគេមិនទាន់មាន ហើយត្រូវការប្រើប្រាស់រាល់ថ្ងៃ ដើម្បីអាចជំរុញឱ្យគណៈកម្មការដឹកនាំ មានការផ្លាស់ប្តូរលើអាកប្បកិរិយា និងឥរិយាបថ ឆ្ពោះទៅរកភាពគុណភាព និងប្រសិទ្ធភាពការងារ ហើយជាចុងក្រោយធ្វើឱ្យសហគមន៍មានភាពរឹងមាំឯករាជ្យ និងចីរភាព ស្របតាមប្រទេសដែលប្រកាន់យកនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ ដ៏មានអត្ថន័យពិតប្រាកដ។

## ២. គោលបំណង និងវិសាលភាព

ការសិក្សានេះ មានគោលបំណងដើម្បីវាស់វែងពីតម្រូវការនៃការកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន ដោយធ្វើការផ្តោតការយកចិត្តទុកដាក់លើបទដ្ឋាន គោលការណ៍ និងសេចក្តីណែនាំទាំងប្រាំបី ជំពូក ដែលបានចែងក្នុងគោលការណ៍ណែនាំស្តីពី ការប្រតិបត្តិល្អរបស់អង្គការសហគមន៍មូលដ្ឋាន ព្រមទាំងនិរន្តរភាពហិរញ្ញវត្ថុ។ ដើម្បីចងក្រងជាសៀវភៅណែនាំសម្របសម្រួល ព្រមទាំងឯកសារមេរៀន ការកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាន ដោយធ្វើការដោះស្រាយរាល់គំហើញ ដែលបានរកឃើញ ក្នុងពេលធ្វើការប៉ាន់ប្រមាណ។

ការសិក្សាស្រាវជ្រាវនេះ មិនផ្តោតទៅលើការងារបច្ចេកទេសលំអិត នៃវិស័យនីមួយៗ របស់អង្គការសហគមន៍មូលដ្ឋានទេ ហើយក៏មិនតម្រូវឱ្យ ធ្វើការសិក្សាលើភាពលំអិត នៃដំណើរការ ឬជំហាននៃការបង្កើតចងក្រងអង្គការសហគមន៍មូលដ្ឋានណាមួយជាក់លាក់ដែរ ឧទាហរណ៍ដូចជា៖ ដំណើរការបង្កើតសហគមន៍ព្រៃឈើ ដែលមាន៨ជំហាននៃដំណើរការចងក្រងបង្កើត មានដូចជា ការ

ផ្សព្វផ្សាយ ការចងក្រងក្រុម ការបោះឆ្នោតជ្រើសរើសគណៈកម្មការ ការចងក្រងបទបញ្ជាផ្ទៃក្នុង ការចងក្រងលក្ខន្តិកៈ ការកំណត់ព្រំប្រទល់ព្រៃ និងការផលិតផែនទី ការចុះកិច្ចព្រមព្រៀងព្រៃសហគមន៍ ព្រមទាំងធ្វើផែនការគ្រប់គ្រងព្រៃសហគមន៍ជាដើម[5]។ ហើយក៏មិនបានពិនិត្យពិច័យទៅលើទិដ្ឋភាព ច្បាប់ ប្រកាស និងគោលការណ៍នានា ក្នុងការគ្រប់គ្រង អង្គការសហគមន៍មូលដ្ឋានទាំងអស់នោះដែរ។ នោះក៏ព្រោះតែ វិស័យនីមួយៗ របស់អង្គការសហគមន៍មូលដ្ឋានមានភាពខុសប្លែកគ្នាខ្លាំងពេក ផ្អែកលើគោលការណ៍នានារបស់វិស័យទាំងអស់នោះ ដែលបានចែង និងភាពលំអិតនៃវិស័យទាំងអស់នោះ ដែលទាមទារចំណាយពេលវេលា ធនធានមនុស្ស និងហិរញ្ញវត្ថុច្រើនថែមទៀត ក្នុងការសិក្សាស្រាវជ្រាវ ហើយលទ្ធផលនៃការសិក្សាស្រាវជ្រាវនោះ ក៏មិនសូវមានប្រយោជន៍ក្នុងការឆ្លើយតបដោយអង្គការសហគមន៍មូលដ្ឋាន និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិដែលពាក់ព័ន្ធដែរ ។

<u>រូបភាពទី១: ដំណើរការរៀបចំបង្កើតសហគមន៍ព្រៃឈើ</u>




*(ផ្ទាំងរូបភាព ផលិតដោយរដ្ឋបាលព្រៃឈើ និងអង្គការពាក់ព័ន្ធមួយចំនួន)*

[5] គោលការណ៍ណែនាំ ការបង្កើតសហគមន៍ព្រៃឈើ។

ជាក់ស្តែង អង្គការសហគមន៍មូលដ្ឋាន ក៏ត្រូវបានលើកទឹកចិត្តផងដែរ ក្នុងការរកឱ្យឃើញនូវកត្តា ឬផ្នែកសំខាន់ៗ ផ្សេងទៀត ដែលមិនត្រូវបានរៀបរាប់ក្នុងគោលការណ៍ខាងលើ ក្នុងពេលសិក្សាជាប្រយោជន៍ ដើម្បីរៀបចំចងក្រងគោលការណ៍សម្របសម្រួលការបណ្តុះបណ្តាល និងឯកសារមេរៀន ដែលមានភាពគ្រប់ជ្រុងជ្រោយ ឆ្លើយតបជាពហុប្រយោជន៍ ដល់អង្គការសហគមន៍មូលដ្ឋានពិតប្រាកដ។ ទន្ទឹមនឹងនោះ ការសិក្សាស្រាវជ្រាវក៏បានជួបនូវការលំបាកមួយចំនួន ក្នុងដំណើរការនៃការសិក្សាពិគ្រោះយោបល់នេះ នោះក៏ដោយសារតែអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយចំនួន មានការស្ទាក់ស្ទើរក្នុងការផ្តល់នូវចម្លើយ និងឯកសារ ព្រមទាំងរបាយការណ៍សំខាន់ៗ សម្រាប់ការសិក្សានេះ ដោយបង្ហាញពីការព្រួយបារម្ភពីការប្រកួតប្រជែងលើការស្នើសុំថវិកាពីម្ចាស់ផ្តល់ជំនួយនានា ហើយម្យ៉ាងទៀត ក៏មានការលំបាកក្នុងការទៅដល់សហគមន៍មួយចំនួន ដែលមានទីតាំងឆ្ងាយពេក ដោយគ្មានសេវាទំនាក់ទំនង និងពិបាកផ្លូវគមនាគមន៍ក្នុងការធ្វើដំណើរ ដូចករណីសហគមន៍ជនជាតិដើមភាគតិចមណ្ឌលគីរីជាដើម។

## ៣. វិធីសាស្ត្រ

ដំណើរការនៃការប៉ាន់ប្រមាណតម្រូវការ កសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាន ត្រូវបានអនុវត្ត តាមជំហានចំនួនបួនធំៗ៖ **ទី១** ធ្វើការសិក្សាលើឯកសារ របាយការណ៍ដែលមានស្រាប់ ព្រមទាំងការស្រាវជ្រាវតាមគេហទំព័ររបស់អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងក្រសួងស្ថាប័នពាក់ពន្ធ័។ គោលបំណងគឺ ដើម្បីធ្វើឱ្យដំណើរការនៃការសិក្សាស្រាវជ្រាវមានការយល់ដឹងទូលំទូលាយ ព្រមទាំងមានអំណះអំណាងច្បាស់លាស់ ដើម្បីការពាររាល់លទ្ធផលដែលសិក្សាស្រាវជ្រាវរកឃើញ។ **ទី២** ធ្វើការប៉ាន់ប្រមាណតម្រូវការ តាមរយៈសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ដោយអញ្ជើញតំណាងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន១០ និងសហគមន៍ចំនួន៥៦ មកពីខេត្ត ក្រុងចំនួន១៣ ព្រមទាំងមន្ត្រីក្រសួងពាក់ព័ន្ធចំនួន៥ស្ថាប័ន ដូចជាក្រសួងបរិស្ថាន ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ រដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល និងសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលមានអ្នកចូលរួម៧៨នាក់។

សិក្ខាសាលាបានធ្វើការបែងចែករបៀបវារៈជាពីរ៖ ទីមួយ គឺការរៀនសូត្រពីបទបង្ហាញចំនួនបួន ដោយមន្ត្រីជំនាញទាំងបួនស្ថាប័ន ស្តីពីការបង្កើតសហគមន៍ក្នុងតំបន់ការពារធម្មជាតិ និងអេកូទេសចរណ៍ធម្មជាតិ សហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍កសិកម្ម និងទីពីរ គឺការបែងចែកសហគមន៍ទាំងអស់ទៅជាប្រាំបួនក្រុម ដោយធ្វើការសម្របសម្រួលដោយបុគ្គលិកអង្គការជាតិ រាប់បញ្ចូលទាំងអង្គការ ដែលជាសមាជិកក្រុមការងារបច្ចេកទេស របស់អង្គការ គ.ស.ក ផងដែរ ដោយផ្តោតការឆ្លុះបញ្ចាំងទៅនឹងបទបង្ហាញទាំង៨ ដែលជាគោលការណ៍ប្រតិបត្តិល្អ របស់អង្គការសហគមន៍មូលដ្ឋាន ព្រមទាំងផ្នែកសំខាន់ដទៃទៀត ដែលមិនបានរាប់បញ្ចូលទៅក្នុងគោលការណ៍ទាំង៨ ខាង

លើ។ ជាផ្នែកនៃការពិគ្រោះយោបល់ក្នុងសិក្ខាសាលា ដើម្បីអាចឱ្យសិក្ខាកាមបានត្រៀមខ្លួនជាមុន បញ្ជីសំណួរដែលពាក់ព័ន្ធទៅនឹង ការប៉ាន់ប្រមាណពីតម្រូវការ ការកសាងសមត្ថភាព ត្រូវបានផ្តល់ជូន (បញ្ជីសំណួរមានភ្ជាប់នៅទំព័រឧបសម្ព័ន្ធ)។ **ទី៣** វិធីសាស្ត្រការសង្កេតផ្ទាល់ (Observation) ក៏បានធ្វើការប្រើប្រាស់ផងដែរ ដោយការពិនិត្យជាក់ស្តែងទៅលើរបាយការណ៍ កំណត់ហេតុ និងបញ្ជីហិរញ្ញវត្ថុ កំណត់ត្រានានា ព្រមទាំងឯកសារជាភស្តុតាងមួយចំនួន ដែលគាំទ្រដល់ការសិក្សាស្រាវជ្រាវនេះ នៅឯទីតាំងជាក់ស្តែងរបស់អង្គការសហគមន៍មូលដ្ឋាន មានដូចជា រចនាសម្ព័ន្ធ បញ្ជីឈ្មោះសមាជិក បទបញ្ជាផ្ទៃក្នុង លក្ខន្តិកៈ ផែនការជំនួញ វិញ្ញាបនបត្រចុះបញ្ជី ព្រមទាំងបញ្ជីស្នាម និងបង្កាន់ដៃនានា ជាដើម។ល។ ការប៉ាន់ប្រមាណតាមរយៈការចុះតាមមូលដ្ឋាន ដើម្បីធ្វើការប្រមូលទិន្នន័យ ដោយបានកំណត់គោលដៅលើ អង្គការសហគមន៍មូលដ្ឋាន ដោយធ្វើការបែងចែកជាប្រាំតំបន់រួមមាន៖ ខេត្តបាត់ដំបង កំពង់ធំ មណ្ឌលគីរី កំពត និងព្រៃវែង ព្រមទាំងខេត្តមួយចំនួនទៀត។ ដោយផ្តោតការយកចិត្តទុកដាក់លើ វិស័យខុសៗគ្នា របស់អង្គការសហគមន៍មូលដ្ឋាន ដូចបង្ហាញក្នុងតារាងខាងក្រោម៖

<u>តារាងទី១: ការជ្រើសរើសតំបន់សម្រាប់ចុះសិក្សាតាមរបៀបដោយចៃដន្យ (Random selection)</u>

| ល.រ | តំបន់ | ប្រភេទ | វិស័យ |
|---|---|---|---|
| ១ | បាត់ដំបង | • សហគមន៍កសិកម្ម<br>• សហគមន៍សហគ្រាស | • កសិកម្ម<br>• អាជីវកម្ម |
| ២ | កំពង់ធំ | • សហគមន៍ក្នុងតំបន់ការពារធម្មជាតិ<br>• សហគមន៍ព្រៃឈើ | • ធនធានធម្មជាតិ<br>• ព្រៃឈើ |
| ៣ | មណ្ឌលគីរី | • សហគមន៍ជនជាតិដើមភាគតិច<br>• ក្រុមសន្សំប្រាក់ | • ជនជាតិដើមភាគតិច<br>• ឥណទានជនបទ |
| ៤ | កំពត | • សហគមន៍អេកូទេសចរណ៍ធម្មជាតិ<br>• សហគមន៍នេសាទ | • ទេសចរណ៍សហគមន៍<br>• ជលផល |
| ៥ | ព្រៃវែង | • ធនាគារស្រូវ<br>• សហគមន៍ប្រើប្រាស់ទឹកកសិកម្ម | • ធនាគារស្រូវ<br>• ធនធានទឹក |

*(កំណត់សំគាល់៖ បញ្ជីឈ្មោះសហគមន៍ភ្ជាប់នៅទំព័រឧបសម្ព័ន្ធ)*

ការសិក្សាបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវ ដោយមានការចូលរួម (Participatory Research Actions) តាមរយៈការសម្ភាសន៍ពាក់កណ្តាលផ្លូវការ (Semi-structure Interview) ដោយប្រើសំណួរបើក (Open questions) ជាមួយក្រុមគណៈកម្មការគ្រប់គ្រងអង្គការសហគមន៍មូលដ្ឋាន ដែលមានតួនាទីជាក់លាក់ មានសមាជិកពី ៥ ទៅ ៩នាក់។ **ទី៤** ប្រើប្រាស់បញ្ជីសំណួរ សម្រាប់ជាឧបករណ៍មួយក្នុងការធ្វើការប្រមូលទិន្នន័យ ដែលជាសំណួរបើក ជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអង្គ

ការអន្តរជាតិ។ សំណួរពាក់ព័ន្ធដទៃទៀត នឹងត្រូវបានបង្កើតឡើង ក្នុងពេលសម្ភាសន៍ និងពិភាក្សា ដើម្បីសម្រេចបាននូវផ្នែកសំខាន់ៗ ដែលចង់បាន។ បញ្ជីសំណួរមានពីរប្រភេទ គឺបញ្ជីសំណួរសម្រាប់ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិ ដែលកំពុងតែបំពេញការងារជាមួយអង្គការ សហគមន៍មូលដ្ឋានទាំងអស់នោះ និងបញ្ជីសំណួរមួយទៀត សម្រាប់ការពិគ្រោះយោបល់ ដូចដែលបានរៀបរាប់ ក្នុងជំហានទី២ (បញ្ជីសំណួរភ្ជាប់នៅឧបសម្ព័ន្ធ)។ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយចំនួន ត្រូវបានកំណត់សម្រាប់ការសិក្សាស្រាវជ្រាវនេះ[6]។ ឯកសារមួយចំនួនដែលពាក់ពន្ធ័ សម្រាប់ការសិក្សាស្រាវជ្រាវបន្ត ត្រូវបានស្នើសុំផងដែរ បន្ទាប់ពីការពិភាក្សាដោយប្រើប្រាស់បញ្ជីសំណួរបានបញ្ចប់រួចមក (បញ្ជីសៀវភៅ និងឯកសារមានភ្ជាប់នៅទំព័រឧបសម្ព័ន្ធ)។

ជារួមការសិក្សាប៉ាន់ប្រមាណនេះ បានធ្វើការពិគ្រោះយោបល់ជាមួយអ្នកផ្តល់ព័ត៌មានដោយផ្ទាល់ និងដោយប្រយោលចំនួន១៧៨នាក់ (ស្រី៩៨នាក់) មកពីអង្គការសហគមន៍មូលដ្ឋានចំនួន៦៦ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន១៥។

យើងបានប្រើប្រាស់ឧបករណ៍វិភាគទិន្នន័យ វាស់វែងសមត្ថភាពដោយប្រើប្រាស់ពិន្ទុ ដែលមានតម្លៃស្មើទៅលើចម្លើយដែលបានផ្តល់ជូន ដោយការផ្តល់ពិន្ទុរាប់ចាប់ពី១ ទៅ៥ ដែលតំណាង ដោយគ្រាប់ពូជ កូនឈើ ដើមឈើ ផ្កា និងផ្លែ ដូចបានបង្ហាញខាងក្រោម៖

- **ពិន្ទុ១ = គ្រាប់ពូជ** - អង្គការសហគមន៍មូលដ្ឋាន មានការយល់ដឹងតិចតួច ហើយពឹង ផ្អែកទាំងស្រុកលើការជួយពីខាងក្រៅ។
- **ពិន្ទុ២ = កូនឈើ** - អង្គការសហគមន៍មូលដ្ឋាន មានការយល់ដឹងមួយចំនួនធំ តែនៅត្រូវការពឹងផ្អែកលើការជួយពីខាងក្រៅមួយចំណែកធំ។
- **ពិន្ទុ៣ = ដើមឈើ** - អង្គការសហគមន៍មូលដ្ឋាន មានការយល់ដឹង ហើយត្រូវការជួយពីខាងក្រៅ មួយចំណែកតូច។
- ពិន្ទុ៤ = **ផ្កាឈើ** - អង្គការសហគមន៍មូលដ្ឋាន មានការយល់ដឹងច្រើន ហើយអាចគ្រប់គ្រងដោយខ្លួនឯងបានជាអន្លើៗ។
- **ពិន្ទុ៥ = ផ្លែឈើ** - អង្គការសហគមន៍មូលដ្ឋាន អាចគ្រប់គ្រង និងចាត់ចែងដោយខ្លួនឯង។

[6] មានដូចជា មជ្ឈមណ្ឌលសិក្សារបស់អង្គការជីវិតថ្លៃថ្នូរ អង្គការលីវ អែនលើន អង្គការព្រហ្មវិហារធម៌ អង្គការកម្មវិធីអភិវឌ្ឍន៍ខ្មែរ អង្គការវីប៊ីល អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល អង្គការក្រុមអភិវឌ្ឍន៍កម្ពុជា អង្គការគាំទ្រជនជាតិដើមភាគតិច អង្គការអភិវឌ្ឍន៍ និងការពារបរិស្ថាន អង្គការពន្លឺកុមារ និងអង្គការ SARF អង្គការ Children and Women Development Center in Cambodia, RECOFTC និងអង្គការ Forum Syd។

ឧទាហរណ៍របៀបគណនា តាមរូបមន្តៈ

| សន្ទស្សន៍សំខាន់ៗ | ការដាក់ពិន្ទុ និងការតាងតម្លៃស្មើ | | | | | |
|---|---|---|---|---|---|---|
| | គ្រាប់ពូជ (១) | កូនឈើ (២) | ដើមឈើ (៣) | ផ្កាឈើ (៤) | ផ្លែឈើ (៥) | សរុបពិន្ទុ |
| លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន | ៩២ | ៥០ | ៣៦ | | | ១៧៨ |

តួលេខ៩២ ៥០ និង៣៦ ជាចំនួនពិន្ទុដែលបូកសរុប ក្នុងចំណោមអ្នកផ្តល់ព័ត៌មាន១៧៨នាក់ (ដូចបង្ហាញក្នុងតារាងខាងលើ)។ នោះមានន័យថា អ្នកផ្តល់ព័ត៌មានចំនួន៩២នាក់ បានទទួលពិន្ទុ ១ (គ្រាប់ពូជ) ដូចគ្នា។ ៥០អ្នកនៃអ្នកបានផ្តល់ព័ត៌មានបានទទួលពិន្ទុ២ (កូនឈើ) និង៣៦នាក់ទៀត បានទទួលពិន្ទុ៣ (ដើមឈើ) ដែលពិន្ទុទាំងអស់នោះ ផ្តល់ជូនដោយអ្នកសិក្សា។ រូបមន្ត[7] ការគណនារកភាគរយ នៃផ្នែកនីមួយៗ យកកំណត់យក១៧៨ ស្មើនឹងមួយរយភាគ។ ឧទាហរណ៍ៈ ៩២X១០០%១៧៨=៥១.៦៨។

របៀបនៃការវិភាគទិន្នន័យ យើងបានអនុវត្តដូចតទៅៈ ទីមួយ ធ្វើការសំភាសន៍ដោយប្រើបញ្ជីសំណួរ និងទីពីរធ្វើការផ្តល់ពិន្ទុទៅលើចម្លើយទាំងអស់នោះ។ ការផ្តល់ពិន្ទុទាបពី១ទៅ៣ និងពិន្ទុខ្ពស់ពី៣ទៅ៥ អាស្រ័យទៅលើភាពត្រឹមត្រូវនៃចម្លើយនីមួយៗ ឧទាហរណ៍ក្នុងករណីសំណួរទី១ អ្នកចូលរួមផ្តល់ចម្លើយឱ្យមិនត្រឹមត្រូវសោះ ផ្តល់ពិន្ទុឱ្យ១ តែបើចម្លើយត្រឹមត្រូវមធ្យម ផ្តល់ឱ្យ៣ តែបើចម្លើយមានភាពត្រឹមត្រូវទាំងអស់ ផ្តល់ពិន្ទុឱ្យខ្ពស់បំផុតគឺ៥ (បញ្ជីសំណួរនៅទំព័រឧបសម្ព័ន្ធ)។ បន្ទាប់មកធ្វើការបូកសរុប ពិន្ទុលើផ្នែកនីមួយៗតាមតារាង ដោយដាក់សញ្ញាតាងទាំង៥ ជារូមមានគ្រាប់ពូជ កូនឈើ ដើមឈើ ផ្កា និងផ្លែឈើ។ ការបូកពិន្ទុតាមផ្នែក និងដាក់ក្នុងតារាងដោយតាងដោយសញ្ញាខាងលើ អាចអោយយើងវិភាគរកឃើញ ថាតើកម្រិតយល់ដឹង និងសមត្ថភាពរបស់ពួកគេជាទូទៅនៅកម្រិតណា លើផ្នែកនីមួយៗ ទាំងជាបុគ្គល និងជាចំនួនសរុប នៃអ្នកដែលបានផ្តល់ព័តិមានទាំងអស់។ ទោះបីយ៉ាងដូច្នោះក៏ដោយ ការដាក់ពិន្ទុនេះ មិនមានភាពសុក្រិតមួយរយភាគរយទេ តែលទ្ធផលជារួមអាចទទួលយកបាន។ បន្ទាប់មកពិន្ទុទាំងអស់នោះ ត្រូវបានយកមកបញ្ចូលទៅក្នុងដ្យាក្រាម និងក្រាហ្វិក ដើម្បីធ្វើការវិភាគ និងបង្ហាញពីគម្លាតជាភាគរយនៃផ្នែកនីមួយៗ ដោយឆ្លុះបញ្ចាំងពីកម្រិតគម្លាតនៃការយល់ដឹងជាបរិមាណ និងគុណភាពរបស់អង្គការសហគមន៍មូលដ្ឋាន ដូចដែលបានធ្វើការពន្យល់ខាងលើ។ វិធីសាស្ត្រនេះ និយាយដោយឡែក ត្រូវបានគេបានប្រើប្រាស់យ៉ាងទូលំទូលាយ ក្នុងការវាស់វែងទៅ

[7] រូបមន្តនេះ ប្រើសម្រាប់តែរបាយការណ៍នេះតែប៉ុណ្ណោះ

លើសមត្ថភាព ឬការប៉ាន់ប្រមាណតម្រូវការ ការកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន ដែលធ្វើឡើងដោយអង្គការអន្តរជាតិ[8]មួយចំនួនបានអនុវត្តរួចមកហើយ។

## ៤. ការសិក្សាអំពីអង្គការសហគមន៍មូលដ្ឋាននៅកម្ពុជា តាមរយៈឯកសារស្រាវជ្រាវ និងរបាយការណ៍ពីអង្គការផ្សេងៗ

លទ្ធផលបឋម ដែលបានមកពីការសិក្សាស្រាវជ្រាវពីឯកសារ និងរបាយការណ៍នានា ដែលបានមកពីអង្គការជាតិក្នុងស្រុក និងអន្តរជាតិនានា ជាសមាជិករបស់អង្គការ គ.ស.ក ឃើញថា អង្គការទាំងអស់នោះ ភាគច្រើនបាន និងកំពុងតែធ្វើការសម្របសម្រួលចងក្រង និងបង្កើត ព្រមទាំងធ្វើការកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាន ដែលជាក្រុមគោលដៅរបស់ខ្លួន ផ្អែកតាមយុទ្ធសាស្ត្រ និងបែបផែនរៀងៗខ្លួន និងខុសៗគ្នា ដូចដែលបានរកឃើញក្នុងពេលពិគ្រោះយោបល់លើឯកសារពាក់ព័ន្ធជាមួយមន្ត្រីកម្មវិធី[9]។ យុទ្ធសាស្ត្រ វិធីសាស្ត្រ និងឧបករណ៍នៃការកសាងសមត្ថភាពរបស់អង្គការទាំងអស់នោះ យោងតាមសមត្ថភាព និងចំណេះដឹង ព្រមទាំងបទពិសោធន៍របស់បុគ្គលិក នៃអង្គការទាំងអស់នោះ ហើយមួយចំនួនទៀត ត្រូវបានការជួយកែលំអដោយអង្គការ ដែលជាដៃគូអភិវឌ្ឍន៍របស់ខ្លួន។ ប្រធានបទបណ្តុះបណ្តាលដែលបានរកឃើញ ពីការសិក្សាបឋមរបស់អង្គការទាំងអស់នោះ ភាគច្រើនផ្តោតការយកចិត្តទុកដាក់ទៅលើប្រធានបទ ទាំងឡាយណា ដែលមានភាពពាក់ព័ន្ធទៅនឹងគម្រោង ជាពិសេសប្រធានបទបច្ចេកទេស ដូចជារបៀបបង្កើតសហគមន៍នេសាទ សហគមន៍អេកូទេសចរណ៍ធម្មជាតិ ក្រុមជួយខ្លួនឯង ប្រព័ន្ធហិរញ្ញវត្ថុសហគមន៍ បច្ចេកទេសកសិកម្ម សហគ្រិនភាព ទីផ្សារ ព្រមទាំងភាពជាអ្នកដឹកនាំ។ល។

តាមការសិក្សា ទាំងលើឯកសារ និងការពិភាក្សាដោយផ្ទាល់ជាមួយថ្នាក់ដឹកនាំ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិមួយចំនួន ឃើញថា មិនមានផែនការយុទ្ធសាស្ត្រណាមួយ ដោយបានបង្កើតឱ្យមានផែនការពេញលេញ ជាលក្ខណៈប្រព័ន្ធ ឬជាកញ្ចប់ ក្នុងដំណើរការកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាននៅឡើយ ដោយដាក់បញ្ចូលទាំងដំណើរការដំបូង និងវិធីសាស្ត្រវាយតម្លៃ ឬប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាល មុនពេលធ្វើការបណ្តុះបណ្តាល ក្នុងពេលធ្វើការបណ្តុះបណ្តាល និងក្រោយការបណ្តុះបណ្តាល ព្រមទាំងការកំណត់សូចនាករលើការវាស់វែងលើឥទ្ធិពលទាំងបរិមាណ និងគុណភាព នៃការបណ្តុះបណ្តាលរយៈពេល។ តែទោះបីយ៉ាងដូច្នោះក្តី ការសិក្សាបានរកឃើញថា ដំណើរការ ឬសកម្មភាពសម្របសម្រួលបណ្តុះបណ្តាលកសាងសមត្ថភាព មានភាពល្អប្រសើរជាទូទៅ ទាំងការរៀបចំតាក់តែង ឯកសារសម្រាប់គាំទ្រដល់ការសម្របសម្រួលបណ្តុះបណ្តាល

[8] Concern Worldwide, Community Forestry International, PACT International, Oxfam GB, Asian Foundation, ForumSyd និង FACT ជាដើម។

[9] ដូចជាអង្គការ Forum Syd ប្រធានកម្មវិធីរបស់អង្គការ Live and Learn Cambodia នាយកស្តីទីរបស់ Learning Center/ LWD ព្រមទាំងគោលការណ៍ការកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋានរបស់អង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) ជាដើម។

ដូចជា ការផលិតឯកសារមេរៀនបានច្បាស់លាស់ ការផលិតឧបករណ៍ និងសម្ភារៈបណ្តុះបណ្តាលដូចជា កូនសៀវភៅ ផ្ទាំងរូបភាព និងកម្រងរូបភាព ធ្វើអោយមានការចាប់អារម្មណ៍ ព្រមទាំងទម្រង់នៃការវាយតម្លៃការបណ្តុះបណ្តាល និងទម្រង់ការធ្វើផែនការអនុវត្តន៍ជាក់ស្តែង បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាលមួយលើកៗជាដើម។

## ៤. ១ តើអង្គការសហគមន៍មូលដ្ឋាននៅកម្ពុជា ធ្វើការផ្តោតលើវិស័យអ្វី?

អង្គការសហគមន៍មូលដ្ឋាន ដែលកំពុងតែដំណើរការសកម្មភាពរបស់ខ្លួន ក្នុងប្រទេសកម្ពុជាភាគច្រើនធ្វើការទៅលើវិស័យផ្សេងៗ ដូចជាកសិកម្ម តាមរយៈការបង្កើតទៅជាសហគមន៍កសិកម្ម សហគមន៍កសិករប្រើប្រាស់ទឹក សហគមន៍ខ្នាតតូច និងមធ្យម ទៅលើផលិតផលកសិកម្ម។ល។ បច្ចុប្បន្ននេះសហគមន៍ទាំងអស់ខាងលើមានចំនួន៨៥៧ សហគមន៍ទូទាំងប្រទេស យោងតាមឯកសារស្ថិតិឆ្នាំ២០១៧ ដែលទទួលបានពីនាយកដ្ឋានអភិវឌ្ឍន៍សហគមន៍កសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ក្នុងពេលពិគ្រោះយោបល់នេះ។ ដោយឡែកសហគមន៍ព្រៃឈើមានចំនួន ៥៩៥ ជាស្ថិតិទូទាំងប្រទេស នៅឆ្នាំ២០១៧ ដែលស្ថិតិនេះទទួលបានពីអង្គការ RECOFTC Cambodia និងពីរដ្ឋបាលព្រៃឈើ។ សហគមន៍ព្រៃឈើនៅកម្ពុជា បានផ្តួចផ្តើម និងបង្កើតឡើងចាប់តាំងពីឆ្នាំ១៩៩៤ មកម្ល៉េះ ដោយអង្គការអន្តរជាតិជាអ្នកគាំទ្រ (Concern Worldwide, FAO, MCC និង GTZ) ហើយចំនួននៃការបង្កើតនៅតែបន្តរហូតមកដល់បច្ចុប្បន្ន។ តាមរបាយការណ៍ស្ថិតិសហគមន៍ព្រៃឈើកម្ពុជា បោះពុម្ពផ្សាយដោយរដ្ឋបាលព្រៃឈើ ឆ្នាំ២០១៧។

<u>តារាងទី២: ស្ថិតិសហគមន៍ព្រៃឈើ និងទីតាំងសហគមន៍ទាំងអស់នោះនៅក្នុងផែនទី</u>

| លរ | ខេត្ត | ស.ព | ផ្ទៃដីព្រៃ | ស្រុក | ឃុំ | ភូមិ | គ្រួសារ |
|---|---|---|---|---|---|---|---|
| ១ | កែប | 3 | 1 009 | 2 | 2 | 4 | 1 048 |
| ២ | កោះកុង | 13 | 17 514 | 4 | 8 | 19 | 451 |
| ៣ | ក្រចេះ | 46 | 63 143 | 6 | 20 | 56 | 11 110 |
| ៤ | កំពង់ឆ្នាំង | 34 | 11 020 | 5 | 16 | 65 | 10 965 |
| ៥ | កំពង់ធំ | 87 | 84 226 | 7 | 29 | 116 | 13 995 |
| ៦ | កំពង់ស្ពឺ | 39 | 17 744 | 6 | 24 | 122 | 11 935 |
| ៧ | កំពត | 33 | 13 543 | 7 | 22 | 76 | 16 998 |
| ៨ | តាកែវ | 13 | 10 791 | 2 | 14 | 106 | 12 601 |
| ៩ | ត្បូងឃ្មុំ | 11 | 3 521 | 2 | 3 | 11 | 2 027 |
| ១០ | ប មានជ័យ | 12 | 4 970 | 4 | 9 | 26 | 3 850 |
| ១១ | ប៉ៃលិន | 4 | 858 | 2 | 4 | 12 | 1 024 |
| ១២ | បាត់ដំបង | 32 | 11 095 | 7 | 14 | 47 | 7 081 |
| ១៣ | ពោធិសាត់ | 82 | 17 773 | 6 | 24 | 82 | 12 973 |
| ១៤ | ព្រះវិហារ | 41 | 59 464 | 5 | 18 | 51 | 4 850 |
| ១៥ | ព្រះសីហនុ | 2 | 1 274 | 1 | 2 | 3 | 492 |
| ១៦ | មណ្ឌលគិរី | 8 | 10 268 | 3 | 4 | 8 | 724 |
| ១៧ | រតនៈគិរី | 37 | 22 754 | 7 | 19 | 57 | 5 238 |
| ១៨ | សៀមរាប | 57 | 31 263 | 12 | 30 | 95 | 15 510 |
| ១៩ | ស្ទឹងត្រែង | 19 | 35 557 | 3 | 16 | 31 | 5 638 |
| ២០ | ស្វាយរៀង | 8 | 1 220 | 6 | 9 | 25 | 3 728 |
| ២១ | ឧ មានជ័យ | 14 | 65 168 | 4 | 9 | 60 | 5 091 |
| | សរុប | **595** | **484 175** | **101** | **296** | **1072** | **147 329** |




*(ប្រភព៖ រដ្ឋបាលព្រៃឈើ និង RECOFTC ២០១៧)*

ចំណែកសហគមន៍តំបន់ការពារធម្មជាតិ ស្ថិតិត្រឹមខែធ្នូ ២០១៧ មានចំនួន ១៥២ សហគមន៍នៅទូទាំងប្រទេស តាមរបាយការណ៍របស់ក្រសួងបរិស្ថានចែកចាយ ក្នុងពេលសិក្ខាសាលាពិគ្រោះយោបល់កន្លងមក។

<u>តារាងទី៣: ក្រាហ្វិកស្ថិតិសហគមន៍នេសាទ និងទីតាំងសហគមន៍ទាំងអស់នោះនៅក្នុងផែនទី</u>




*(ប្រភព៖ រដ្ឋបាលជលផល ២០១៧)*

បច្ចុប្បន្នសហគមន៍នេសាទមានចំនួន ៥១៦ ជាស្ថិតិទូទាំងប្រទេស គិតត្រឹមខែធ្នូ ២០១៧ តាមរយៈរបាយការណ៍របស់រដ្ឋបាលជលផល ក្នុងពេលធ្វើបទបង្ហាញក្នុងសិក្ខាសាលាពិគ្រោះយោបល់កន្លងមក។ សហគមន៍នេសាទត្រូវបានបង្កើតឡើង នៅពេលដែលរាជរដ្ឋាភិបាលធ្វើកំណែទម្រង់វិស័យជលផល ដោយលុបឡូត៍នេសាទចំនួនជាង ៥៦% នៃផ្ទៃឡូត៍សរុប ប្រមាណជិតកន្លះលានហិតា នៅឆ្នាំ២០០០ ដោយប្រគល់ជូនប្រជាពលរដ្ឋ ធ្វើនេសាទជាលក្ខណៈគ្រួសារ និងជំរុញការរៀបចំសហគមន៍នេសាទទូទាំងប្រទេស។

រូបភាពទី២: ជំហាននៃការរៀបចំសហគមន៍នេសាទ




*(ផ្ទាំងរូបភាពផ្សព្វផ្សាយផលិតដោយរដ្ឋបាលជលផល និងអង្គការអុកហ្វាមអង់គ្លេស)*

ម្យ៉ាងវិញទៀត តាមរបាយការណ៍ស្ថិតិរបស់អង្គការជីវិតថ្លៃថ្នូរ (LWD) នៅឆ្នាំ២០១៦ ដែលមានទីតាំងនៅ៤ខេត្ត គឺខេត្ត កំពង់ស្ពឺ កំពង់ឆ្នាំង ពោធិ៍សាត់ និងបាត់ដំបងគឺមានចំនួន៣៩២ ធនាគារភូមិ។ ធនាគារភូមិមួយចំនួនជាផ្នែកមួយនៃក្រុមសន្សំប្រាក់ សហគមន៍សហគ្រាសខ្នាតតូច និងមធ្យម និងមួយចំនួនទៀត គឺសហគមន៍កសិកម្ម យោងតាមរបាយការណ៍ស្ថិតិ របស់អង្គការ។ ជាក់ស្តែង សហគមន៍មួយចំនួន ដែលជាធនាគារភូមិ មិនទាន់បានទទួលស្គាល់ និងចុះបញ្ជីជាលក្ខណៈទូលំទូលាយនៅឡើយ លើកលែងតែសហគមន៍កសិកម្ម នោះក៏ដោយសារតែមិនទាន់មានច្បាប់ ឬគោលការណ៍ណាមួយជាក់លាក់។ អង្គការសហគមន៍មូលដ្ឋានស្ទើរតែទាំងអស់ ត្រូវបានធ្វើការបង្កើនសមត្ថភាពតាមរយៈការបណ្តុះបណ្តាល ពីប្រធានបទដែលពាក់ព័ន្ធទៅនឹងការបង្កើតចងក្រងអង្គការសហគមន៍មូលដ្ឋាន ព្រមទាំងការងារបច្ចេកទេសកសិកម្ម ដូចជា ការដាំបន្លែ ចិញ្ចឹមសត្វ ការផលិតជីកំប៉ុស ព្រមទាំងប្រព័ន្ធហិរញ្ញវត្ថុសហគមន៍។ល។ ការសិក្សាស្រាវជ្រាវរកឃើញថា ប្រធានបទបណ្តុះបណ្តាលមិនត្រូវគ្នានឹងប្រធានបទគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អ របស់អង្គការសហគមន៍មូលដ្ឋានទាំងស្រុងទេ ដោយសារតែអង្គការផ្តល់អាទិភាពធ្វើការបណ្តុះបណ្តាលទៅលើប្រធានបទទាំងឡាយណា

ដែលពាក់ព័ន្ធទៅនឹងគម្រោង ដូចជាដំណើរការរៀបចំសហគមន៍ និងការងារបច្ចេកទេសកសិកម្ម អាជីវកម្ម និងទីផ្សារ។ល។

ដោយឡែក បណ្តាញអង្គការសហគមន៍មួយចំនួនត្រូវបានបង្កើតឡើង ក្នុងរូបភាព និងវិស័យផ្សេងៗគ្នា ក្នុងគោលបំណងធ្វើការរួមគ្នា និងលើកតម្កើងសម្លេងតែមួយ ក្នុងចំណោមពួកគេ។ បណ្តាញអង្គការសហគមន៍មូលដ្ឋានទាំងអស់នោះ មានបង្កើតជារចនាសម្ព័ន្ធទំនាក់ទំនង និងបញ្ជីសមាជិកភាព ដូចជាបណ្តាញ បណ្តាញសកម្មជនជាតិដើមភាគតិចហៅថា អាយរ៉ាម (Indigenous Rights Active Members-IRAM)។ បណ្តាញនៃអង្គការសហគមន៍មូលដ្ឋាននេះបាន និងកំពុងតែគាំទ្រយ៉ាងល្អពីអង្គការ គាំទ្រជនជាតិដើមភាគតិច (ICSO) និងអង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។ បណ្តាញនេះមានសមាជិកមកពី១១ខេត្ត ដែលមានជនជាតិដើមភាគតិចរស់នៅ។ លក្ខណៈពិសេសគឺបណ្តាញនេះ អនុញ្ញាតឱ្យតែជនជាតិដើមភាគតិច ចូលជាសមាជិកប៉ុណ្ណោះ។

ចំណែកបណ្តាញសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ ត្រូវបានបង្កើតឡើងតាំងពីឆ្នាំ១៩៩៩ ដោយអង្គការ Concern Worldwide, រដ្ឋបាលព្រៃឈើ និងក្រសួងបរិស្ថាន។ បណ្តាញនេះមានរូបភាពជាថ្នាក់ជាតិ ដោយមានការចូលរួមពីសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិទាំងអស់ទូទាំងប្រទេស តាមរយៈកិច្ចប្រជុំរៀងរាល់ត្រីមាស យោងតាមរបាយការណ៍កិច្ចប្រជុំបណ្តាញ ផែនទីបង្ហាញផ្លូវ និងផែនការយុទ្ធសាស្ត្ររបស់បណ្តាញ ដែលបានចែងក្នុងផែនការយុទ្ធសាស្ត្រព្រៃឈើជាតិ ដោយរដ្ឋបាលព្រៃឈើ ឆ្នាំ២០១០ ដល់២០២៩។ បច្ចុប្បន្នបណ្តាញនេះ ត្រូវបានគាំទ្រដោយ USAID/ WINROCK យោងតាមបទបង្ហាញរបស់គម្រោងព្រៃឈើ នៅឯកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីតំបន់ព្រៃឡង់ឆ្នាំ២០១៧។

បណ្តាញព្រៃឡង់ ជាបណ្តាញព្រៃឈើមួយដែលមានសកម្មជនព្រៃឈើចំនួន៤ខេត្ត បានចូលរួម មានដូចជាខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ និងស្ទឹងត្រែង។ គោលបំណងនៃបណ្តាញនេះ គឺដើម្បីពង្រឹងការទំនាក់ទំនង និងសម្របសម្រួលជាមួយអ្នកពាក់ព័ន្ធទាំងអស់ដែលកំពុងតែធ្វើការក្នុងតំបន់ព្រៃឡង់ ដើម្បីបង្កើនការចូលរួម ក្នុងការចូលរួមផែនការយុទ្ធសាស្ត្ររួម ក្នុងការការពារព្រៃឡង់។ ដើម្បីបង្កើនភាពសុខដុមរម្យនារវាងដៃគូអភិវឌ្ឍន៍ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងៗ[10] ក្នុងការលើកឡើងរាល់កង្វល់ទាំងអស់ដែលកំពុងតែកើតមានក្នុងតំបន់ព្រៃឡង់ ព្រមទាំងបញ្ចូលនូវផែនការ និងយុទ្ធសាស្ត្ររួមគ្នា ដើម្បីធ្វើឱ្យមានឥទ្ធិពលក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់អ្នកនយោបាយទៅលើអនុក្រិ

[10] 1) Danmission, 2) Community Economic Development (CED), 3) Organization to Promote Kuoy Culture (OPKC), 4) Winrock International (WI), 5) Prey Lang Community Network (PLCN), 6)Environment and Health Education Organization (EHEO), 7) Conservation International (CI), 8) Community Peace-Building Network (CPN), 9)Cambodian Youth Network (CYN), 10)Action for Development (AFD), and 11) Peace Bridge Organization (PBO)

ត្យព្រៃឡង់ និងកម្មវិធីព្រៃឈើជាតិ។ បណ្តាញនេះ ជួបជុំគ្នារៀងរាល់៣ខែម្តង ដោយអញ្ជើញសមាជិកទាំងអស់ ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អន្តរជាតិ ព្រមទាំងដៃគូអភិវឌ្ឍន៍នានាចូលរួមផងដែរ យោងតាមឯកសារគោលរបស់បណ្តាញព្រៃឡង់ ចេញខែមិនា ឆ្នាំ២០១៥។

បណ្តាញព្រៃឈើ និងជនជាតិដើមភាគតិច ជាបណ្តាញមួយដែលមានការចូលរួមជាសមាជិកទាំងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសហគមន៍មូលដ្ឋាន។ បណ្តាញត្រូវបានសម្របសម្រួលដោយគណៈកម្មការគ្រប់គ្រងមួយ ដែលកើតឡើងដោយការបោះឆ្នោត ពីសមាជិកទាំងអស់។ បច្ចុប្បន្នបណ្តាញនេះ កំពុងតែសម្របសម្រួល និងផ្តល់ហិរញ្ញវត្ថុដោយ អង្គការវេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា។ គោលបំណងនៃបណ្តាញ គឺធ្វើការពង្រឹងទំនាក់ទំនង និងបង្កើនសហប្រតិបត្តិការក្នុងចំណោមអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក អង្គការអន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសហគមន៍មូលដ្ឋាន ដែលពាក់ព័ន្ធទៅនឹងជនជាតិដើមភាគតិច និងព្រៃឈើ សិទ្ធិជាប្រពៃណី ក្នុងការគ្រប់គ្រងធនធានព្រៃឈើ ដើម្បីឆ្លើយតបទៅនឹងសង្គម សេដ្ឋកិច្ច និងវប្បធម៌។ ព្រមទាំងបង្កើនការទទួលខុសត្រូវ និងការយល់ដឹងពីតួនាទីភារកិច្ចរបស់បណ្តាញ (យោងតាមឯកសារគោលគំនិត របស់បណ្តាញចុះថ្ងៃទី២ ខែសីហា ឆ្នាំ២០១៦។

បណ្តាញអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ត្រូវបានបង្កើតចាប់តាំងពីឆ្នាំ១៩៩៧ តាមខេត្តនានា។ ចាប់ពីឆ្នាំ២០១២ បណ្តាញនេះបានកើនចំនួន១៥ បណ្តាញអង្គការក្រៅរដ្ឋាភិបាលថ្នាក់ខេត្ត ហើយប្រតិបត្តិការក្នុងខេត្តចំនួន១៥ មានដូចជា៖ បាត់ដំបង ក្រុងព្រះសីហនុ ពោធិ៍សាត់ សៀមរាប មណ្ឌលគីរី ស្វាយរៀង បន្ទាយមានជ័យ កំពង់ចាម ស្ទឹងត្រែង ព្រះវិហារ តាកែវ កំពត កំពង់ស្ពឺ ព្រៃវែង និងរតនគីរី។ បណ្តាញថ្នាក់ខេត្តទាំងអស់នេះ ត្រូវបានគាំទ្របច្ចេកទេស និងថវិកាដោយ អង្គការស្តារកម្ពុជា។ គោលបំណងនៃបណ្តាញ គឺធ្វើការពង្រឹង និងបង្កើនការធ្វើការរួមគ្នា ដើម្បីដោះស្រាយសម្របសម្រួលរាល់បញ្ហា និងការលំបាកដែលពាក់ព័ន្ធទៅនឹងសិទ្ធិជនជាតិភាគតិច ព្រៃឈើ ដីធ្លី និងការចិញ្ចឹមជីវិត ដោយធ្វើការរួមគ្នាជាមួយអង្គការពាក់ព័ន្ធទាំងអស់នៅថ្នាក់ក្រោមជាតិ។ ចាប់ពីឆ្នាំ២០១៤ រហូតមកដល់បច្ចុប្បន្នអង្គការស្តារកម្ពុជាបានប្តូរគោលនយោបាយ ពីរបៀបធ្វើការជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ទៅជាធ្វើការផ្ទាល់ជាមួយអង្គការសហគមន៍មូលដ្ឋានវិញ យោងតាមគេហទំព័រ របស់អង្គការស្តារកម្ពុជា[11]។ ក្រោយមក ក៏មានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយចំនួនបានប្រើប្រាស់បណ្តាញតាមខេត្តទាំងអស់ ជាយន្តការសម្រាប់សកម្មភាពតស៊ូមតិ[12]នានា ដែលធ្វើឱ្យមានការយល់ច្រឡំពីមន្ត្រីរាជរដ្ឋាភិបាល ជាពិសេសករណីនៅខេត្តពោធិ៍សាត់។ ករណីនេះបានធ្វើឱ្យ

[11] http://www.starkampuchea.org.kh/en/home

[12] ព័ត៌មានទទួលបានពីអតីតសមាជិកបណ្តាញអង្គការក្រៅរដ្ឋាភិបាល ខេត្តពោធិ៍សាត់ ខែមករា ២០១៨។

មានការស្នាក់ស្ទើរខ្លាំងឡើងក្នុងការចូលរួម កិច្ចប្រជុំបណ្តាញប្រចាំត្រីមាស និងសកម្មភាពមួយចំនួនទៀត។ បច្ចុប្បន្នបណ្តាខេត្តមួយចំនួននៅបន្តសកម្មភាពបណ្តាញជាធម្មតាដូចជាខេត្តកំពង់ធំ តែមួយចំនួនទៀតមិនសូវមានសកម្មភាព ឬគ្មានសកម្មភាពសោះតែម្តង ដូចករណីខេត្តពោធិ៍សាត់ និងកំពង់ឆ្នាំង[13]ជាដើម។ បញ្ជីឈ្មោះសមាជិកបណ្តាញតាមខេត្តនីមួយៗ មានភ្ជាប់នៅទំព័រឧបសម្ព័ន្ធ នៃរបាយការណ៍នេះ។

> នាយកអង្គការទស្សនៈបៃតង (GVO) និងជាប្រធានបណ្តាញអង្គការមិនមែនរដ្ឋាភិបាលប្រចាំនៅខេត្តពោធិ៍សាត់ បានផ្តល់យោបល់ថា៖ បណ្តាញអាចនឹងដើរយ៉ាងរលូនឡើងវិញ ប្រសិនបើយើងមានយុទ្ធសាស្ត្រ និងផែនការច្បាស់លាស់ ដោយប្រើយន្តការ ការពិគ្រោះយោបល់ ជាជាងការតស៊ូមតិជាមួយរាជរដ្ឋាភិបាល ព្រមទាំងមានការគាំទ្រផ្នែកហិរញ្ញវត្ថុ រយៈពេលវែង អាចពី៣ទៅ៥ឆ្នាំពីដៃគូអភិវឌ្ឍន៍ណាមួយ។

បើធ្វើការប្រៀបធៀបជាមួយប្រទេសមួយចំនួនក្នុងតំបន់ដូចជា ប្រទេសថៃ ហ្វីលីពីន និង នេប៉ាល់ជាដើម នៅប្រទេសកម្ពុជាមិនទាន់មានបណ្តាញអង្គការសហគមន៍ណាមួយដែលមានភាពរឹងមាំដែលមានឥទ្ធិពលលើគោលនយោបាយជាតិនៅឡើយទេ។ បណ្តាញអង្គការសហគមន៍មូលដ្ឋាននៅប្រទេសនេប៉ាល់[14] គឺបណ្តាញក្រុមប្រើប្រាស់ព្រៃឈើ គឺមានភាពជោគជ័យ និងរឹងមាំបំផុត ដែលអាចជំរុញឱ្យមានការផ្លាស់ប្តូរគោលនយោបាយជាតិបាន ស្របតាមតម្រូវការរបស់អង្គការសហគមន៍មូលដ្ឋាន ដែលចង់បាន។

## ៤ .២ តើអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកណាខ្លះ ដែលបានធ្វើការសម្របសម្រួលជាមួយ អង្គការសហគមន៍មូលដ្ឋាន? ហើយតើអង្គការសហគមន៍មូលដ្ឋាន ទទួលបានការគាំទ្រអ្វីខ្លះ ក្នុងការគ្រប់គ្រងរបស់ខ្លួន?

តាមប្រព័ន្ធទិន្នន័យគេហទំព័រ របស់ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) មានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិចំនួន១៨៧៦[15] ក្នុងនោះអង្គការក្នុងស្រុកមានចំនួន១២០០ និងអង្គការអន្តរជាតិចំនួន៦៧៦។ ជាក់ស្តែងមានអង្គការមិនមែនរដ្ឋាភិបាលតែចំនួន៥៧៩ កំពុងតែមានសកម្មភាព និង២៧០ បានបិទលែងបន្តសកម្មភាព និង១០២៧ មិនបានធ្វើសេចក្តីរាយការណ៍មកក្រុមប្រឹក្សា

[13] ព័ត៌មានទទួលបានពីអតីតសមាជិកបណ្តាញអង្គការក្រៅរដ្ឋាភិបាល ខេត្តកំពង់ឆ្នាំង ខែមករា ២០១៨។

[14] របាយការណ៍បណ្តាញ FECOFUN នេប៉ាល ២០១៦។

[15] បញ្ជីឈ្មោះអង្គការមិនបានបញ្ចូលក្នុងរបាយការណ៍នេះទេ ដោយសារតែមានចំនួនច្រើនពេក។

អភិវឌ្ឍន៍កម្ពុជា[16]។ ទោះបីយ៉ាងដូច្នោះក៏ដោយ អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងអន្តរជាតិទាំងអស់នោះ[17]ភាគច្រើនលើសលុបគឺប្រតិបត្តិគម្រោង ឬកម្មវិធីរបស់ខ្លួនតាមរយៈការចងក្រងបង្កើតអង្គការសហគមន៍មូលដ្ឋាន ដែលមានដូចជា សហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍អេកូទេសចរណ៍ធម្មជាតិ សហគមន៍កសិកម្ម ធនាគារស្រូវ ធនាគារសត្វ ក្រុមជួយខ្លួនឯង ធនាគារភូមិ ក្រុមសន្សំប្រាក់ ក្រុមផ្សព្វផ្សាយសុខភាព ក្រុមអប់រំមិត្ត សហគមន៍សហគ្រាសខ្នាតតូច និងមធ្យម ក្រុមកែច្នៃសិប្បកម្ម។ល។ និង។ល។

## ៤. ៣ តើសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន មានកម្រិតណាដែរ?

នៅពេលសិក្សានេះ មិនមានរបាយការណ៍ស្រាវជ្រាវណាមួយ ដែលនិយាយពីលទ្ធផលនៃការប៉ាន់ប្រមាណ ឬវាស់វែងពីតម្រូវការ នៃការកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋានជាលក្ខណៈទូលំទូលាយ ត្រូវបានរកឃើញទេ។ តែមានអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក មួយចំនួន[18] បានធ្វើការវាស់វែង និងប៉ាន់ប្រមាណពីសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន ដែលជាក្រុមគោលដៅគម្រោងរបស់ខ្លួន តាមវិធីសាស្ត្រ និងឧបករណ៍ផ្សេងៗ។ ជាក់ស្តែងអង្គការសហគមន៍មូលដ្ឋាន គឺជាផ្នែកមួយនៃសង្គម ជាស្ថាប័នមូលដ្ឋានដែលបង្កើតឡើងដោយសមាជិកសហគមន៍ខ្លួនឯងដើម្បីបម្រើផលប្រយោជន៍ និងតម្រូវការសមាជិករបស់ខ្លួន[19]។ ទោះបីយ៉ាងនោះក៏ដោយ សមាសភាពសមាជិកក្រុមអង្គការសហគមន៍មូលដ្ឋានមានលក្ខណៈចម្រុះរវាងក្រុមកសិករក្រីក្របំផុត ក្រីក្រ អ្នកដែលមានជីវភាពមធ្យម និងអ្នកដែលមានជីវភាពគ្រាន់បើ។ ទន្ទឹមនឹងនោះ ភាគច្រើនមិនចេះអាន និងសរសេរអក្សរខ្មែរ និងមួយចំនួនជាជនជាតិដើមភាគតិច ដែលស្ទើរតែមិនអាចនិយាយភាសាខ្មែរបានទៀតផង (របាយការណ៍ស្តីពីសហគមន៍ព្រៃឈើ នៅមូលដ្ឋាន ដោយ RECOFTC No. 16, July 1997។

[16] http://odacambodia.com/ngo/summary/summary.asp

[17] អង្គការទាំងនោះកំពុងតែប្រតិបត្តិសកម្មភាពគម្រោងផ្សេងៗគ្នា នៅទូទាំងប្រទេស ជាពិសេសលើវិស័យ៖ កសិកម្ម និងធនធានទឹក វិមជ្ឈការ និងវិសហមជ្ឈការ អប់រំ ជលផល សន្តិសុខស្បៀង និងអាហារូបបត្ថម្ភ ព្រៃឈើ និងបរិស្ថាន យេនឌ័រ និងសុខាភិបាល មេរោគអេដស៍ និងជំងឺអេដស៍ ហេដ្ឋារចនាសម្ព័ន្ធ និងសមាហរណកម្មតំបន់ ដីធ្លី កំណែទម្រង់ច្បាប់ និងតុលាការ សកម្មភាពមីន ភាពជាដៃគូ និងសុខដុមនីយកម្ម ផែនការ និងកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍវិស័យឯកជន កំណែទម្រង់រដ្ឋបាលសាធារណៈ គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផ្គត់ផ្គង់ទឹកជនបទ អនាម័យ និងការរស់នៅស្អាត (សៀវភៅណែនាំស្តីពី ការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាលទៅក្នុងយន្តការសម្របសម្រួលជំនួយនៅកម្ពុជា ឆ្នាំ២០១២)។

[18] Learning Center/ LWD, FACT, Forum Syd, និង Live and Learn។

[19] ឯកសារគម្រោងរបស់អង្គការ Forum Syd មិនចុះថ្ងៃខែឆ្នាំ

ដោយសារតែចរិតលក្ខណៈអង្គការសហគមន៍មូលដ្ឋានមានភាពខុសៗគ្នា ដូច្នេះសមត្ថភាពរបស់ពួកគេក៏មានកម្រិតខុសៗគ្នា។ ជាក់ស្តែងអង្គការសហគមន៍មូលដ្ឋាន ដែលមានទីតាំងក្នុងក្រុង ឬទីប្រជុំជន តែងតែមានសមត្ថភាពក្នុងការគ្រប់គ្រងសហគមន៍របស់ខ្លួន ល្អជាងសហគមន៍ ដែលមានទីតាំងឆ្ងាយ ដាច់ស្រយាល ឬជនជាតិដើមភាគតិច ដែលមានឱកាសតិចតួច ឬគ្មានសោះក្នុងការទទួលបាននូវសេវាកម្មអប់រំសាធារណៈដែលមានគុណភាព។ និយាយជារួម កម្រិតវប្បធម៌ ចំណេះដឹងផ្នែកច្បាប់ គោលការណ៍នានា និងជំនាញបច្ចេកទេសទំនើបកម្មភាគច្រើនស្ថិតក្នុងកម្រិតទាប រាប់បញ្ចូលទាំងការទំនាក់ទំនង ការគ្រប់គ្រងហិរញ្ញវត្ថុ ចំណេះដឹងលើជំនាញសម្របសម្រួល និងភាពជាអ្នកដឹកនាំ។ល។ ស្ថិតក្នុងកម្រិតមួយ ដែលទាមទារឱ្យមានជួយការបណ្តុះបណ្តាល និងគាំទ្រពីស្ថាប័នខាងក្រៅ[20]។

## ៤. ៤ កិច្ចអន្តរាគមន៍ អង្គការមិនមែនរដ្ឋាភិបាលជាមួយអង្គការសហគមន៍មូលដ្ឋាន លើការកសាងសមត្ថភាព ព្រមទាំងឧបករណ៍ និងសម្ភារៈដែលបានបង្កើត

លទ្ធផលបឋម ដែលបានមកពីការសិក្សាស្រាវជ្រាវពីឯកសារ និងរបាយការណ៍នានា ដែលបានមកពីអង្គការផ្សេងៗ និងសមាជិករបស់អង្គការ គ.ស.ក ឃើញថា អង្គការទាំងអស់នោះ ភាគច្រើនបាន និងកំពុងតែធ្វើការសម្របសម្រួលចងក្រង និងបង្កើត ព្រមទាំងធ្វើការកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាន ដែលជាក្រុមគោលដៅរបស់ខ្លួន ផ្អែកតាមយុទ្ធសាស្ត្រ និងបែបផែនផ្សេងៗគ្នា។ យុទ្ធសាស្ត្រ គោលការណ៍ វិធីសាស្ត្រ និងឧបករណ៍នៃការកសាងសមត្ថភាព យោងតាមសមត្ថភាព និងចំណេះដឹង ព្រមទាំងបទពិសោធន៍។ ចំណេះដឹង និងបទពិសោធន៍មួយចំនួនទៀត ដែលពាក់ព័ន្ធទៅនឹងការកសាងសមត្ថភាពនេះ ត្រូវបានការជួយកែលំអ និងចែករំលែកដោយអង្គការ ដែលជាដៃគូអភិវឌ្ឍន៍។ អង្គការបានផលិតសម្ភារៈ និងឧបករណ៍សម្រាប់ជួយដល់ការបណ្តុះបណ្តាល យោលទៅតាមខ្លឹមសារមេរៀននីមួយៗដូចជា តារាងវាយតម្លៃ និងវាស់វែងសមត្ថភាព សៀវភៅតែងការសម្របសម្រួល កូនសៀវភៅមេរៀន រូបភាពផ្ទាំងធំ និងតូច រូបថ្លុកអប់រំ កម្រងខ្សែវីឌីអូខ្លីៗ ខិតប័ណ្ណ ករណីសិក្សា ព្រមទាំងកម្រងរូបភាពមេរៀនជាដើម ។ល។

តាមការសិក្សា ទាំងលើឯកសារ និងការពិភាក្សាដោយផ្ទាល់ជាមួយថ្នាក់ដឹកនាំ អង្គការជាតិមិនមែនរដ្ឋាភិបាល និងអន្តរជាតិមួយចំនួន ឃើញថា មិនមានផែនការយុទ្ធសាស្ត្ររយៈពេលវែងណាមួយត្រូវបានបង្កើត ដោយបង្ហាញជាផែនទីបង្ហាញផ្លូវ ឬផែនការពេញលេញ ជាលក្ខណៈប្រព័ន្ធ និងវិជ្ជាជីវៈខ្ពស់ ដោយបញ្ចូលទាំងដំណើរការ និងវិធីសាស្ត្រវាយតម្លៃ ឬប៉ាន់ប្រមាណតម្រូវការបណ្តុះបណ្តាលមុនពេលធ្វើការបណ្តុះបណ្តាលទេ ក្នុងពេលធ្វើការបណ្តុះបណ្តាល ក្រោយការបណ្តុះបណ្តាល ព្រម

[20] Community-Based Capacity Development (CBO) Guidelines by LWD Feb, 2009

ទាំងការកំណត់សូចនាករ ឬសន្ទស្សន៍ ពីការវាស់វែងលើឥទ្ធិពលទាំងបរិមាណ និងគុណភាព ព្រមទាំងប្រព័ន្ធគ្រប់គ្រងទិន្នន័យ ក្នុងដំណើរការកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាននៅឡើយ។ ប្រធានបទនៃវគ្គបណ្តុះបណ្តាល និងផែនការអនុវត្តន៍ជាក់ស្តែង គឺធ្វើឡើងក្នុងក្របខ័ណ្ឌអង្គការ ឬគម្រោង ដែលឆ្លើយតបទៅនឹងប្រសិទ្ធភាពគម្រោងរយៈពេលខ្លី និងមធ្យម តែមិនឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដទាំងស្រុង តែកំពុងបានផ្តល់ជាវិភាគទានមួយចំណែក ដល់អង្គការសហគមន៍មូលដ្ឋានឆ្ពោះទៅរកគោលការណ៍ទាំងប្រាំបី។ ជាក់ស្តែងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក ដែលមានគម្រោង ឬកម្មវិធីកសិកម្ម ពួកគេធ្វើការបណ្តុះបណ្តាលអង្គការសហគមន៍មូលដ្ឋានតែទៅលើប្រធានបទកសិកម្មប៉ុណ្ណោះ ទោះបីអង្គការសហគមន៍មូលដ្ឋាននោះត្រូវការជំនាញបន្ថែម ដូចជាភាពជាអ្នកដឹកនាំ ឬជំនាញសម្របសម្រួលក្តី។ ការបណ្តុះបណ្តាលភាគច្រើនឆ្លើយតបទៅលើតែលើតម្រូវការបន្ទាន់ ព្រមទាំងបាននឹងកំពុងតែផ្តោតការយកចិត្តទុកដាក់ទៅលើតែការបង្កើនសមត្ថភាព គណៈកម្មការ ឬក្រុមអ្នកគ្រប់គ្រង របស់អង្គការសហគមន៍មូលដ្ឋាន ដែលអាចផ្តល់លទ្ធផលក្នុងអាយុកាលរបស់គម្រោងដូចជា បច្ចេកទេសដាំបន្លែ ការចិញ្ចឹមមាន់ ការបណ្តុះផ្សិតចំបើង ការចិញ្ចឹមត្រី ការវេចខ្ចប់បន្លែ និងជំនាញទីផ្សារជាដើម។ល។

ទោះយ៉ាងដូច្នោះក្តី ការសិក្សាបានរកឃើញថា ដំណើរការ ឬសកម្មភាពសម្របសម្រួលវគ្គបណ្តុះបណ្តាលកសាងសមត្ថភាព ដែលជាការអនុវត្តជាក់ស្តែងហាក់មានភាពល្អប្រសើរទៅវិញ ជាទូទៅ ទាំងការរៀបចំតាក់តែងឯកសារមេរៀន ការសម្របសម្រួលវគ្គបណ្តុះបណ្តាល ការផលិតឯកសារមេរៀន ការផលិតឧបករណ៍ និងសម្ភារៈបណ្តុះបណ្តាល ការវាយតម្លៃការបណ្តុះបណ្តាល និងការធ្វើផែនការអនុវត្តន៍ជាក់ស្តែង បន្ទាប់ពីបញ្ចប់វគ្គបណ្តុះបណ្តាលមួយលើកៗ[21]។

## ៤.៥ ការអនុវត្តល្អ របស់អង្គការមិនមែនរដ្ឋាភិបាល ជាមួយអង្គការសហគមន៍មូលដ្ឋាន ពាក់ព័ន្ធការកសាងសមត្ថភាព និងការចែករំលែកចំណេះដឹង

តាមការកត់សំគាល់ពីកិច្ចពិភាក្សាជាមួយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក គឺមានមជ្ឈមណ្ឌលសិក្សានៃអង្គការជីវិតថ្លៃថ្នូរ (Learning Center of LWD) អង្គការលីវ អែនលើន (Live and Learn) និងអង្គការអង្គការសម្ព័ន្ធភាពដើម្បីអភិរក្សធនធានជលផល (FACT) បានបង្កើតឱ្យមានគម្រោងមួយដាច់ដោយឡែក ក្នុងស្ថាប័នរបស់ខ្លួន ទទួលបន្ទុកការផ្តល់សេវាកម្ម ការបង្កើន និងការកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាន ដែលជាក្រុមសហគមន៍គោលដៅរបស់ខ្លួន ដោយបង្កើតឱ្យមានគោលការណ៍ច្បាស់លាស់ មុនពេល ក្នុងពេល និងក្រោយពេលធ្វើការបណ្តុះបណ្តាលបង្កើន

[21] របាយការណ៍បណ្តុះបណ្តាល និងតារាងវាយតម្លៃវគ្គបណ្តុះបណ្តាលរបស់ CL/ LWD, Live & Learn និងឯកសារបណ្តុះបណ្តាលរបស់ Forum Syd

សមត្ថភាពអង្គការសហគមន៍មូលដ្ឋាន។ ទន្ទឹមនឹងនោះ ពួកគេបានបង្កើតឱ្យមានទម្រង់បែបបទក្នុងការប៉ាន់ប្រមាណតម្រូវការ ការវិភាគទិន្នន័យ និងការបង្កើតផែនការមេបង្កើនសមត្ថភាព។ ចងក្រងឯកសារសម្របសម្រួលបណ្តុះបណ្តាល ព្រមទាំងឯកសារមេរៀន ឧបករណ៍ និងសម្ភារៈសំខាន់ៗ ដូចជា ផ្ទាំងរូបភាពតូច ធំ រូបថ្លុកអប់រំ និងខ្សែវីឌីអូខ្លីៗ។ល។ សម្រាប់គាំទ្រដល់ដំណើរការសម្របសម្រួល ការបណ្តុះបណ្តាល។ អង្គការក៏មានទម្រង់បែបបទសម្រាប់ការវាយតម្លៃលទ្ធផល ការបណ្តុះបណ្តាលរយៈពេលខ្លី និងឥទ្ធិពលរយៈពេលវែង។ មានឯកសារ និងរបាយការណ៍មួយចំនួន ដែលមានសារសំខាន់ក្នុងការ ផ្តល់វិភាគទានដល់ការរៀបចំឯកសារគោលសម្រាប់សម្របសម្រួល និងឯកសារមេរៀនសម្រាប់ការពង្រឹងស្ថាប័ន និងកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាន។ ជាក់ស្តែងមជ្ឈមណ្ឌលសិក្សានៃ អង្គការ LWD បានបង្កើតគោលការណ៍កសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាននៅឆ្នាំ២០០៩ ព្រមទាំងឯកសារមេរៀនបច្ចេកទេសមួយចំនួនទៀត ដែលត្រូវជាមួយនឹងគម្រោង និងវិស័យក្រុម សហគមន៍ដែលកំពុងតែសម្របសម្រួល។ អង្គការលើវ អែនលើន បានចងក្រងរបាយការណ៍ប៉ាន់ប្រមាណតម្រូវការកសាងសមត្ថភាព ផ្ទៃក្នុងរបស់អង្គការសហគមន៍មូលដ្ឋាននៅឆ្នាំ២០១៧ ព្រមទាំងគោលការណ៍បង្កើតអង្គការសហគមន៍មូលដ្ឋាន។ ចំណែកអង្គការ FACT បានបង្កើតឯកសារគោលការណ៍កសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាន ព្រមទាំងវាយតម្លៃការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋានគំរូ ក្នុងតំបន់គោលដៅរបស់ខ្លួន ដែលឯកសារនោះភាគច្រើនមានភាពពាក់ព័ន្ធខ្លាំងជាមួយគោលការណ៍ស្ម័គ្រចិត្តទាំងប្រាំបី ដែលបានចែងក្នុងសៀវភៅណែនាំស្តីពីការប្រតិបត្តិល្អ របស់អង្គការសហគមន៍មូលដ្ឋាន ដែលបានបោះពុម្ពផ្សាយដោយអង្គការ គ.ស.ក។

ទោះជាយ៉ាងនេះក៏ដោយ នៅមានភាពប្រឈមខ្លាំងជាមួយសហគមន៍មូលដ្ឋាន ដែលជាជនជាតិដើមភាគតិច ពាក់ព័ន្ធទៅនឹងការផ្តល់ការកសាងសមត្ថភាពនេះ នោះក៏ដោយសារតែពួកគេមួយចំនួនធំ រាប់ទាំងគណៈកម្មការគ្រប់គ្រងផងដែរ ដែលមិនចេះអាន និងសរសេរអក្សរច្បាស់លាស់។ បទពិសោធន៍របស់អង្គការ CONCERN WORLDWIDE គឺបណ្តុះបណ្តាលគណៈកម្មការកត់ត្រាដោយប្រើប្រាស់សញ្ញាសំគាល់ សាមញ្ញៗ ដែលងាយចងចាំ និងងាយយល់ សម្រាប់ធ្វើការកត់ត្រាលើតារាងដែលមានស្រាប់។ អង្គការអន្តរជាតិ CONCERN WORLDWIDE តែងធ្វើការប៉ាន់ប្រមាណតម្រូវការកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន តាមរយៈបង្កើតនូវឧបករណ៍ និងវិធីសាស្ត្រងាយៗ បន្ទាប់មកបង្កើតនូវធនាគារជំនាញ ដើម្បីធ្វើការគ្រប់គ្រងការកសាងសមត្ថភាពរបស់គណៈកម្មការអង្គការសហគមន៍មូលដ្ឋានទាំងអស់ ដែលជាក្រុមគោលដៅរបស់ខ្លួន។ ផែនការបង្កើនសមត្ថភាពត្រូវបានបង្កើតឡើង ផ្អែកតាមលទ្ធផលប៉ាន់ប្រមាណតម្រូវការ ការកសាងសមត្ថភាព និងធនាគារជំនាញដែលមានរយៈពេលពី៣ ទៅ៥ឆ្នាំ។ ក្រុមការងារបច្ចេកទេសមួយត្រូវបានបង្កើតឡើង ដោយបុគ្គលិកជំនាញ ដើម្បីរៀបចំតាក់តែងសៀវភៅតែងការបណ្តុះបណ្តាល និងសៀវភៅណែនាំ ការសម្របសម្រួល។ ជាចុងក្រោយ ការបណ្តុះបណ្តាលត្រូវបានរៀបចំឡើង ដោយតម្រូវទៅតាម តម្រូវការជាក់ស្តែងរបស់អង្គការសហគមន៍នីមួយៗ។ បន្ទាប់ពីការបណ្តុះបណ្តាលមួយវគ្គត្រូវបានបញ្ចប់ ការវាយ

តម្លៃវគ្គត្រូវបានធ្វើឡើង ដោយបំពេញតាមទម្រង់បែបបទដែលបានបង្កើត ហើយទិន្នន័យនៃលទ្ធផលនៃការបណ្តុះបណ្តាល រួមទាំងអ្នកចូលរួមទាំងអស់ត្រូវបានបញ្ចូលទៅក្នុងធនាគារជំនាញ ដើម្បីតាមដានភាពរីកចំរើន និងឥទ្ធិពលនៃការបណ្តុះបណ្តាលរយៈពេលវែង។ វិធីសាស្ត្រនេះ បានទទួលលទ្ធផលយ៉ាងធំធេង បន្ទាប់ពីគម្រោងបានធ្វើការវាយតម្លៃឥទ្ធិពលនៃសកម្មភាពការកសាងសមត្ថភាពរបស់អង្គការសហគមន៍មូលដ្ឋាន។

## ៥. លទ្ធផលចេញពីការវាយតម្លៃលើតម្រូវការនៃការកសាងសមត្ថភាព

ដូចបានអធិប្បាយសម្រាប់វិធីសាស្ត្រខាងលើ ការវាយតម្លៃត្រូវបានវិភាគតាមរយៈការផ្តល់ពិន្ទុដោយពិន្ទុតិចចាប់ពី១ ដល់ខ្លាំងរហូតដល់៥ (១=គ្រាប់ពូជ, ២=កូនឈើ, ៣=ដើមឈើ, ៤=ផ្កាឈើ, ៥=ផ្លែឈើ។ លទ្ធផលខាងក្រោមទទួលបានពីអ្នកផ្តល់ព័ត៌មាន ក្នុងកិច្ចប្រជុំពិភាក្សាចំនួន ១៧៨ នាក់ (ស្រី ៩៨នាក់) ដែលមកពីបណ្តាអង្គការសហគមន៍មូលដ្ឋានចំនួន៦៦ និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកចំនួន១៥[22] ធ្វើការឆ្លុះបញ្ចាំងទៅលើគោលការណ៍ណែនាំស្តីពីការប្រតិបត្តិល្អ របស់អង្គការសហគមន៍មូលដ្ឋានចំនួន៨ និងការរកឃើញបន្ថែមចំនួន២ទៀត ដូចបង្ហាញខាងក្រោម។

យើងបានធ្វើការដាក់ជាសំណាក[23] តំណាងឱ្យតម្លៃនៃពិន្ទុនីមួយៗ ដូចបានធ្វើការអធិប្បាយក្នុងវិធីសាស្ត្រខាងលើ។ ដើម្បីរក្សានូវភាពសម្ងាត់នៃអង្គការសហគមន៍មូលដ្ឋាននីមួយៗ លទ្ធផលដែលទទួលបានដោយផ្ទាល់ និងដោយប្រយោល មិនត្រូវបានបង្ហាញនូវអត្តសញ្ញាណ អ្នកផ្តល់ព័ត៌មានទេក្នុងរបាយការណ៍ការប៉ាន់ប្រមាណតម្រូវការ ការកសាងសមត្ថភាពនេះ។ តែទោះបីយ៉ាងដូច្នោះក៏ដោយ បញ្ជីឈ្មោះអង្គការជាតិមិនមែនរដ្ឋាភិបាល និងអន្តរជាតិ ព្រមទាំងអង្គការសហគមនន៍មូលដ្ឋានស្ថាប័នរដ្ឋាភិបាល សាកលវិទ្យាល័យ ត្រូវបានកត់ត្រាទុក ជាឧបសម្ព័ន្ធក្នុងរបាយការណ៍នេះ។

ទិន្នន័យដែលបានពីការសិក្សាស្រាវជ្រាវ យើងបានធ្វើការគណនាទៅជាភាគរយ (%) ដើម្បីងាយស្រួលក្នុងការវិភាគទិន្នន័យ ដូចបង្ហាញក្នុងតារាងក្រាហ្វិកខាងក្រោម៖

---

[22] បញ្ជីឈ្មោះស្ថាប័ន និងអ្នកបានចូលរួមពិភាក្សា ផ្តល់ចម្លើយ នៅក្នុងទំព័រឧបសម្ព័ន្ធ។

[23] ឧបករណ៍នេះ ត្រូវបានប្រើប្រាស់ដោយអង្គការ CONCERN WORLDWIDE នៅឆ្នាំ១៩៩៧

<u>តារាងទី៩: លទ្ធផលពិន្ទុតាមផ្នែកនីមួយៗ ដោយគណនាតាមប្រេកង់ និងភាគរយ</u>

| សន្ទស្សន៍សំខាន់ៗ | ការដាក់ពិន្ទុ និងការតាងតម្លៃស្មើ | | | | | |
|---|---|---|---|---|---|---|
| | គ្រាប់ពូជ (១) | កូនឈើ (២) | ដើមឈើ (៣) | ផ្កាឈើ (៤) | ផ្លែឈើ (៥) | សរុបពិន្ទុ[24] |
| ១-លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន | ៩២ | ៥០ | ៣៦ | 0 | 0 | ១៧៨ |
| | ៥១.៦៨ | ២៨.០៨ | ២០.២២ | 0 | 0 | ១០០% |
| ២-ការទំនាក់ទំនង កិច្ចសហការ និងការចងបណ្ដាញ | ១០២ | ៤៦ | ៣០ | 0 | 0 | ១៧៨ |
| | ៥៧.៣០ | ២៥.៨៤ | ១៦.៨៥ | 0 | 0 | ១០០% |
| ៣-សមាជិកភាព និងការគ្រប់គ្រងសមាជិក | ៨២ | ៣០ | ៦៦ | 0 | 0 | ១៧៨ |
| | ៤៦.០៦ | ១៦.៨៥ | ៣៧.០៧ | 0 | 0 | ១០០% |
| ៤-ការគ្រប់គ្រងហិរញ្ញវត្ថុ | ២៨ | ៨២ | ៦៨ | 0 | 0 | ១៧៨ |
| | ១៥.៧៣ | ៤៦.០៦ | ៣៨.២០ | 0 | 0 | ១០០% |
| ៥-គណនេយ្យភាព និងតម្លាភាព | ៥៦ | ៤៨ | ៣០ | ៤៤ | 0 | ១៧៨ |
| | ៣១.៤៦ | ២៦.៩៦ | ១៦.៨៥ | ២៦.៩៦ | 0 | ១០០% |
| ៦-ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ | ៩៥ | ៥៣ | ១២ | ១៨ | 0 | ១៧៨ |
| | ៥៣.៣៧ | ២៩.៧៧ | ៦.៧៤ | ១០.១១ | 0 | ១០០% |
| ៧-យុទ្ធសាស្ត្រ និងការធានានិរន្តរភាព | ១២៩ | ៤៩ | 0 | 0 | 0 | ១៧៨ |
| | ៧២.៤៧ | ២៧.៥២ | 0 | 0 | 0 | ១០០% |
| ៨-ការពង្រឹងសមត្ថភាពនិងការយល់ដឹង | ៣៣ | ៥៨ | ៦៧ | ១២ | ៨ | ១៧៨ |
| | ១៨.៥៣ | ៣២.៥៨ | ៣៧.៦៤ | ៦.៧៤ | ៤.៤៩ | ១០០% |
| ៩-ភាពជាអ្នកដឹកនាំ | ១២០ | ៣៥ | ២៣ | 0 | 0 | ១៧៨ |
| | ៦៧.៤១ | ១៩.៦៦ | ១២.៩២ | 0 | 0 | ១០០% |
| ១០-ការគោរពតាមតួនាទី និងភារៈកិច្ច | ៩៩ | ៦៨ | ១១ | 0 | 0 | ១៧៨ |
| | ៥៥.៦១ | ៣៨.២០ | ៦.១៧ | 0 | 0 | ១០០% |

[24] ការគណនានេះ អាចមានការលំអៀងតិចតួច តែអាចទទួលយកជាការបាន។

<u>ដ្យាក្រាមទី១៖ ការវិភាគលើផ្នែកគ្រាប់ពូជ ដោយធៀបជាមួយវិស័យទាំង១០</u>




នៅក្នុងការវិភាគលំអិតលើចំណុចគ្រាប់ពូជពីវិស័យទាំង១០ យើងអង្កេតឃើញថា យុទ្ធសាស្ត្រ និងការធានានិរន្តរភាព (៧២.៤៧%) គឺជាតម្រូវការអាទិភាព លើសគេបំផុត បន្ទាប់មកភាពជាអ្នកដឹកនាំ (៦៧.៤១) ទី២ រីឯការទំនាក់ទំនង កិច្ចសហការ និងការចងបណ្ដាញ(៥៧.៣០) ទី៣។ ការគោរពតាម តួនាទី និងភារៈកិច្ច(៥៥.៦១)ទី៤ ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ (៥៣.៣៧)ទី៥ ហើយលក្ខណៈផ្លូវច្បាប់និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន(៥១.៦៨)ទី៦ សមាជិកភាព និងការគ្រប់គ្រងសមាជិក(៤៦.០៦) ទី៧ គណនេយ្យភាព និងតម្លាភាព(៣១.៤៦) ទី៨ ការពង្រឹងសមត្ថភាព និងការយល់ដឹង (១៨.៥៣)ទី៩ ព្រមទាំងការគ្រប់គ្រងហិរញ្ញវត្ថុ (១៥.៧៣)ទី១០។

ដ្យាក្រាមទី២៖ ការវិភាគលើផ្នែកកូនឈើ ដោយធៀបជាមួយវិស័យទាំង១០




នៅផ្នែកកូនឈើការគ្រប់គ្រងហិរញ្ញវត្ថុ (៤៦.០៦%) គឺជាតម្រូវការអាទិភាពបំផុត ការគោរពតាមតួនាទី និងភារៈកិច្ច (៣៨.២០%) ជាតម្រូវការទី២ ការពង្រឹងសមត្ថភាព និងការយល់ដឹង (៣២.៥៨%) ទី៣ ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ(២៩.៧៧%) ទី៤ លក្ខណៈផ្លូវច្បាប់និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន(២៨.០៨%)ទី៥ យុទ្ធសាស្ត្រ និងការធានានិរន្តរភាព (២៧.៥២%) ទី៦ គណនេយ្យភាព និងតម្លាភាព(២៦.៩៦%)ទី៧ ការទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ(៤៦.០៦%)ទី៨ ភាពជាអ្នកដឹកនាំ(១៩.៦៦%) ទី៩ ហើយសមាជិកភាព និងការគ្រប់គ្រងសមាជិក ជាអាទិភាព(១៦.៨៥%) ទី១០។

ដ្យាក្រាមទី៣៖ ការវិភាគលើផ្នែកដើមឈើ ដោយធៀបជាមួយវិស័យទាំង១០




នៅផ្នែកដើមឈើ មានបីវិស័យដែលមានពិន្ទុស្រដៀងគ្នាតាមលំដាប់លំដោយរួមមាន៖ ការគ្រប់គ្រងហិរញ្ញវត្ថុ (៣៨.២០%) គឺជាតម្រូវការអាទិភាពបំផុត សមាជិកភាព និងការគ្រប់គ្រងសមាជិក(៣៧.៧០%)ជាអាទិភាពទី២ ការពង្រឹងសមត្ថភាព និងការយល់ដឹង(៣៧.៦៤%)ទី៣។ លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន(២០.២២%)ទី៤។ ការទំនាក់ទំនង កិច្ចសហការ និងការចងបណ្ដាញ ក៏ដូចជា គណនេយ្យភាព និងតម្លាភាពគឺមានអាទិភាពដូចគ្នា នៅលំដាប់ទី៥ (១៦.៨៥%)។ ចំណែកភាពជាអ្នកដឹកនាំ (១៣.០០%)ទី៧ ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ (៦.៧៥%)ទី៨ ការគោរពតាមតួនាទី និងភារៈកិច្ច(៦.២០%)ទី៩ និងយុទ្ធសាស្ត្រ និងការធានានិរន្តរភាពគឺមិនមានពិន្ទុឡើយ ដែលជាអាទិភាពចុងក្រោយ(ទី១០)។

ដ្យាក្រាមទី៤៖ ការវិភាគលើផ្នែកផ្កាឈើ ដោយធៀបជាមួយវិស័យទាំង១០




នៅផ្នែកផ្កាឈើ គណនេយ្យភាព និងតម្លាភាព(២៦.៩៦%)គឺជាតម្រូវការអាទិភាពបំផុត បន្ទាប់មក ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ(១០.១១%)ទី២ ចំណែកឯ ការពង្រឹងសមត្ថភាព និងការយល់ដឹង(៦.៧៤%)ទី៣។ ចំណែកលក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន ការទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ សមាជិកភាព និងការគ្រប់គ្រងសមាជិក ការគ្រប់គ្រងហិរញ្ញវត្ថុ យុទ្ធសាស្ត្រ និងការធានានិរន្តរភាព ភាពជាអ្នកដឹកនាំ ការគោរពតាមតួនាទី និងភារៈកិច្ចគឺមិនមានផ្តល់ជាពិន្ទុដូចគ្នា ដែលជាអាទិភាពទី៤ ដូចៗគ្នា។

ដ្យាក្រាមទី៥៖ ការវិភាគលើផ្នែកផ្លែឈើ ដោយធៀបជាមួយវិស័យទាំង១០




នៅផ្នែកផ្លែឈើ ការពង្រឹងសមត្ថភាព និងការយល់ដឹង(៤.៤៨%)គឺជាតម្រូវការអាទិភាពទី១ ខណៈដែលលក្ខណៈផ្សេងៗទៀតមិនមានពិន្ទុនោះឡើយរួមមាន៖ ផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន ការទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ សមាជិកភាព និងការគ្រប់គ្រងសមាជិកការគ្រប់គ្រងហិរញ្ញវត្ថុ គណនេយ្យភាព និងតម្លាភាព ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ យុទ្ធសាស្ត្រ និងការធានានិរន្តរភាព ភាពជាអ្នកដឹកនាំ ការគោរពតាមតួនាទី និងភារៈកិច្ច ដែលជាតម្រូវការអាទិភាពទី២ ដូចៗគ្នា។

ដ្យាក្រាមទី៦៖ ក្រាហ្វិក កម្រិតនៃចំណេះដឹងតាមផ្នែកនីមួយៗ




ដ្យាក្រាមទី៧៖ ការវិភាគលើគម្លាតវាស់វែងទាំង៥



ដ្យាក្រាមទី៨៖ ការវិភាគលើកម្រិតអាទិភាព នៃតម្រូវការកសាងសមត្ថភាព




## ៨.១ លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន

លទ្ធផលបង្ហាញថា ក្នុងជួរថ្នាក់ដឹកនាំគណៈកម្មការ មានការយល់ដឹងតិចតួច ដំបូងឡើយនៃដំណាក់ការចងក្រងបង្កើតសហគមន៍ ទាំងគោលបំណង ហេតុផល និងផលប្រយោជន៍នៃការចងក្រងបង្កើតជាសហគមន៍។ តែបន្ទាប់ពីបានចូលរួមវគ្គផ្សព្វផ្សាយ និងបណ្តុះបណ្តាលពីអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ដែលបានគាំទ្រពួកគេជាបន្តបន្ទាប់ ការយល់ដឹងមានការកើនច្រើនឡើង។ ដោយឡែក កសិករមួយចំនួនទៀតបានចូលរួមតាមគេតាមឯងជាសមាជិកអង្គការសហគមន៍មូលដ្ឋាន ដោយព្រោះតែមើលឃើញពីផលប្រយោជន៍រយៈពេលខ្លី ដូចជា ប្រាក់ឧបត្ថម្ភ និងអាហារសម្រន់ ។ល។ មានសមាជិកខ្លះបានយល់ច្រឡំ ដោយរំពឹងថានឹងទទួលបានជំនួយមនុស្សធម៌ ដូចជា អង្ករ ប្រេងឆា ត្រីខកំប៉ុង ឬថវិកា បន្ទាប់ពីបានចុះឈ្មោះជាសមាជិករួច។ តែទោះបីយ៉ាងដូច្នោះក្តី ក៏មានសមាជិកថ្នាក់ដឹកនាំដទៃទៀត មានការយល់ដឹងច្បាស់លាស់ពីគោលការណ៍ គោលបំណង និងផលប្រយោជន៍សហគមន៍ ដោយពួកគេបានទទួលការផ្សព្វផ្សាយ និងបណ្តុះបណ្តាលជាច្រើនលើក និងច្រើនសារនៅដំណាក់កាលនៃការចងក្រងបង្កើត តែសមាជិកបែបនេះមានចំនួនតិចតួចបំផុត យោងតាមការសំភាសន៍ដោយផ្ទាល់ពីថ្នាក់ដឹកនាំ។ ជាងនេះទៀត មូលហេតុដែលពួកគេមិនបានយល់ដឹងពីទស្សនៈជាមូលដ្ឋាន របស់អង្គការសហគមន៍មូលដ្ឋាន នោះអាចមកពី ការផ្សព្វផ្សាយមិនបានធ្វើឡើង

ឱ្យមានលក្ខណៈទូលំទូលាយ ការប្រើប្រាស់ពេលវេលាមិនសមស្រប និងការប្រើប្រាស់ពាក្យពេចន៍ ខ្លឹមសារ ណែនាំដែលមិនត្រូវនឹងចំណេះដឹង ឬសមត្ថភាពសហគមន៍មូលដ្ឋាន ឧទាហរណ៍ជនជាតិដើមភាគតិច និងអ្នកមិនចេះអក្សរជាដើម។ ដោយឡែក សមាជិកសហគមន៍ខ្លះទៀត មិនបានយល់ដឹងច្រើន ដោយសារតែពួកគាត់មិនសូវបានចូលរួមសកម្មភាពផ្សព្វផ្សាយផ្សេងៗ ដោយសារភាពរវល់ និងមមាញឹកខ្លាំងក្នុងរបរអាជីវកម្មប្រចាំថ្ងៃ។ ចំណុចសំខាន់ៗ ដែលគណៈកម្មការ ព្រមទាំងសមាជិក សមាជិកាអង្គការសហគមន៍មូលដ្ឋានគួរមានការយល់ដឹង ឱ្យបានច្បាស់លាស់មុនពេលចាប់ផ្តើមសកម្មភាពចងក្រងក្រុម ឬសហគមន៍ គឺទស្សនៈ គោលដៅ គោលបំណង និងល័ក្ខខ័ណ្ឌសំខាន់ៗសម្រាប់ដំណើរការចងក្រងសហគមន៍ ព្រមទាំងផលប្រយោជន៍ ដែលពួកគេនឹងត្រូវទទួលបាន ព្រមទាំងគោលការណ៍ច្បាប់ ឬនិតិវិធីនៃការប្រព្រឹត្តទៅនៃអង្គការសហគមន៍មូលដ្ឋាន។ល។

ដោយឡែក ការអនុវត្តតាមច្បាប់ និងគោលការណ៍ណែនាំនានា របស់រាជរដ្ឋាភិបាលក្នុងដំណាក់កាលដំបូងនៃការបង្កើតអង្គការសហគមន៍មូលដ្ឋាន ឬចងក្រងក្រុម បានតាមព័ត៌មានដែលទទួលបានពីអង្គការសហគមន៍មូលដ្ឋាន ក៏ដូចអង្គការជាតិមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ គឺអង្គការសហគមន៍មូលដ្ឋានភាគច្រើនមិនបានគិតដល់ ឬមិនបានយល់ដឹងច្រើនឡើយ ជាពិសេសខ្លឹមសារ និងអត្ថន័យភាសាច្បាប់។ គោលការណ៍ និងបទដ្ឋានច្បាប់ទាំងឡាយដែលពួកគេគួរស្វែងយល់ និងអនុវត្តតាមមានដូចជាៈ អនុក្រិត្យស្តីពីការបង្កើតសហគមន៍កសិកម្ម សហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍ក្នុងតំបន់ការពារធម្មជាតិ សហគមន៍អេកូទេសចរណ៍ ការបង្កើតសហគមន៍សហគ្រាសតូច និងមធ្យម និងគោលការណ៍បង្កើតធនាគារភូមិជាដើម។ល។ ជាក់ស្តែងដូចជា សហគមន៍កសិកម្ម ព្រៃឈើ នេសាទ អេកូទេសចរណ៍ សហគមន៍ក្នុងតំបន់ការពារធម្មជាតិ និងឥណទានជនបទ នៅតែមិនទាន់បានយល់ដឹងច្បាស់លាស់ពីគោលការណ៍ច្បាប់ ទោះបីបានបង្កើតឡើងបានជាង១០ឆ្នាំហើយក៏ដោយ។

## ៨. ២ ការទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ

ការទំនាក់ទំនង កិច្ចសហប្រតិបត្តិការ និងបណ្តាញ ទាំងផ្លូវការ និងក្រៅផ្លូវការការមានកម្រិតទាបបំផុត យោងតាមការសិក្សាស្រាវជ្រាវនេះ។ មូលហេតុសំខាន់ៗ គឺដោយសារតែថ្នាក់ដឹកនាំអង្គការសហគមន៍មូលដ្ឋានខ្វះបទពិសោធន៍ មិនមានទំនុកចិត្តខ្លួនឯង និងមិនសូវមានឆន្ទៈ ក្នុងការបំពេញភារកិច្ចនេះ។ ជាទូទៅ ពួកគេពឹងផ្អែកទាំងស្រុងលើអង្គការមិនមែនរដ្ឋាភិបាល ឬម្ចាស់ជំនួយ ជាអ្នកត្រួសត្រាយ និងគាំទ្រ។ យ៉ាងណាក៏ដោយ គេសង្កេតឃើញថា ទំនាក់ទំនងផ្ទៃក្នុង[25]សហគមន៍ខ្លួនហាក់មាន

[25] ទំនាក់ទំនងផ្ទៃក្នុង គឺការទំនាក់ទំនងរវាងគណៈកម្មការ និងសមាជិកខ្លួនឯង ទៅវិញទៅមក ក្នុងក្របខ័ណ្ឌ ឬព្រំដែនអង្គការសហគមន៍មូលដ្ឋាន។

ភាពល្អប្រសើរជាង ទំនាក់ទំនងខាងក្រៅ[26]។ កិច្ចការសំខាន់ៗ សម្រាប់ធ្វើទំនាក់ទំនងខាងក្នុងមានដូចជា៖ ការផ្សព្វផ្សាយពីកម្មវិធីប្រជុំ ផ្ដល់ដំណឹងពីភ្ញៀវមកទស្សនកិច្ច និងការចូលរួមសកម្មភាពជាធម្មតាក្នុងសហគមន៍ដូចជា ការដាក់ភាគហ៊ុន ការសងការប្រាក់និងប្រាក់ដើម ការដាក់ពាក្យស្នើប្រាក់កម្ចី និងសកម្មភាពអាជីវកម្មសហគមន៍ ការល្បាតព្រៃ ការចូលរួមដាំឈើ ដែលមានសមាជិកចំនួនច្រើន ចូលរួម។ កិច្ចសហប្រតិបត្តិការជាមួយស្ថាប័ន និងអង្គការសហគមន៍មូលដ្ឋានផ្សេងៗទៀត ស្ទើរតែមិនមាន លើកលែងតែការចូលប្រជុំ ឬបណ្ដុះបណ្ដាល ដែលរៀបចំឡើងដោយអង្គការគាំទ្រនានា។ ទោះដូច្នោះក៏ដោយ សហគមន៍មួយចំនួនត្រូវបានអញ្ជើញឱ្យចូលរួមកិច្ចប្រជុំរបស់ក្រុមប្រឹក្សាឃុំ/សង្កាត់ប្រចាំខែផងដែរ។

កម្រិតទាបបំផុត នៃការទំនាក់ទំនងជាទូទៅ បានធ្វើឱ្យអង្គការសហគមន៍មូលដ្ឋាន មានភាពឯកោ និងដាច់ឆ្ងាយពីសេវាកម្មសាធារណៈរបស់រដ្ឋអំណាច ជំនាញ និងការគាំទ្រនានាពីអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ ព្រមទាំងដៃគូនានា ជាពិសេសការចូលរួមក្នុងដំណើរការសមាហរណកម្មផែនការអភិវឌ្ឍ និងផែនការវិនិយោគឃុំ។ មានការប្រឈមខ្លាំង ចំពោះអង្គការសហគមន៍មូលដ្ឋាន ដែលធ្វើការទាក់ទងទៅនឹងព្រៃឈើ នេសាទ ដីធ្លី អេកូទេសចរណ៍ធម្មជាតិ និងតំបន់ការពារធម្មជាតិ ព្រោះអង្គការសហគមន៍មូលដ្ឋានទាំងអស់នោះ ទាមទារការចូលរួមពីសំណាក់អាជ្ញាធរ និងជំនាញ ក្នុងការគ្រប់គ្រងបទល្មើស ក្នុងដែនសមត្ថកិច្ចរបស់ពួកគេ។ ចំណែកសហគមន៍ដទៃទៀត ការទំនាក់ទំនងក៏មានសារសំខាន់ណាស់ផងដែរ លើការចុះបញ្ជី ការសុំអនុញ្ញាតផ្សេងៗ ទាំងទិដ្ឋភាពច្បាប់ និងបច្ចេកទេស។ល។

ការប្រជុំបណ្ដាញភាគច្រើនរៀបចំឡើងដោយអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកគាំទ្រ ហើយជាធម្មតាពួកគេមិនមានរបៀបវារៈច្បាស់លាស់ណាមួយ ដើម្បីលើកឡើងនៅឯកិច្ចប្រជុំនោះទេ។ ហើយពេលវេលានៃកិច្ចប្រជុំបណ្ដាញមិនសូវជាទៀងទាត់ ហើយសហគមន៍មូលដ្ឋាន មិនបានដាក់បញ្ចូលផែនការប្រជុំនោះ ទៅក្នុងផែនការរបស់ខ្លួនក៏ទេដែរ។

ដោយឡែក ការចងក្រងបណ្ដាញថ្នាក់មូលដ្ឋាន មានដូចជាថ្នាក់ខេត្ត និងថ្នាក់ស្រុក មានដូចជាសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ ជនជាតិដើមភាគតិច ដីធ្លី មានដំណើរការទៅបានល្អ ដោយមានការសម្របសម្រួលដោយអង្គការអន្តរជាតិ ឬដៃគូអភិវឌ្ឍន៍។ តែបន្ទាប់មកបណ្ដាញទាំងអស់នោះ បានបាត់បង់បន្តិចម្ដងៗ ហើយដំណើរការនេះក៏ផ្លាស់ប្ដូរដែរ។ នោះក៏ដោយសារតែគ្មាន

---

[26] គឺជាការទំនាក់ទំនងរវាងគណៈកម្មការអង្គការសហគមន៍មូលដ្ឋាន ទៅស្ថាប័នខាងក្រៅដូចជា អង្គការជាតិមិនមែនរដ្ឋាភិបាល ម្ចាស់មូលនិធិ មន្ទីរជំនាញ ឬអាជ្ញាធរដែនដីជាដើម។

ស្ថាប័នណាមួយមានសមត្ថភាពទទួលខុសត្រូវ ក្នុងការសម្របសម្រួល និងចាត់ចែងបណ្តាញទាំងអស់នោះបន្ត។

ទោះដូច្នោះ ក៏គេមើលឃើញជាទូទៅ គ្រប់បណ្តាញអង្គការសហគមន៍មូលដ្ឋានទាំងអស់ ត្រូវបានដឹកនាំ និងចាត់ចែងដោយអង្គការមិនមែនរដ្ឋាភិបាលជាតិ ឬអន្តរជាតិ។ មិនមានភស្តុតាងណាដែលមានភាពរឹងមាំបង្ហាញពីបណ្តាញអង្គការសហគមន៍មូលដ្ឋានណាមួយ ដែលត្រូវបានគ្រប់គ្រង និងចាត់ចែងដោយអង្គការសហគមន៍មូលដ្ឋានបានដោយខ្លួនឯងនៅឡើយ[27]។ នោះគឺដោយសារតែពួកគេមិនទាន់មានសមត្ថភាព និងលទ្ធភាពគ្រប់គ្រាន់ក្នុងការបំពេញការងារដ៏លំបាកស្មុគស្មាញនេះ ប៉ុន្តែដោយសារមើលឃើញពីគុណតម្លៃ និងផលប្រយោជន៍នៃការបង្កើតបណ្តាញ អង្គការជាតិ និងអន្តរជាតិ ព្រមទាំងស្ថាប័នរដ្ឋាភិបាលមួយចំនួន បានផ្តើមផ្តើមបង្កើតបណ្តាញផ្សេងៗ តាមផែនការ និងគម្រោងរបស់ខ្លួន។ តាមបទពិសោធន៍មួយចំនួន ដែលបានរៀនសូត្រកន្លងមក[28] បណ្តាញ ដែលមានប្រសិទ្ធភាព និងឥទ្ធិពលបំផុតគឺត្រូវចាត់ចែង និងដឹកនាំដោយអង្គការសហគមន៍មូលដ្ឋានខ្លួនឯង តាមរយៈបង្កើតឱ្យមានទស្សនៈវិស័យ និងគោលដៅច្បាស់លាស់ រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច ផែនទីបង្ហាញផ្លូវ ដែលជាយុទ្ធសាស្ត្រច្បាស់លាស់ សកម្មភាពប្រតិបត្តិ ព្រមទាំងថវិកាសម្រាប់ដំណើរការ ។ល។ ថ្នាក់ដឹកនាំបណ្តាញត្រូវបានពង្រឹងស្ថាប័ន និងការកសាងសមត្ថភាពប្រកបដោយគុណភាព ជាលំដាប់លំដោយ តាមរយៈការបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា និងការបង្វឹកជាដើម។ល។

<u>តារាងទី៦៖ បញ្ជីឈ្មោះបណ្តាញអង្គការជាតិមិនមែនរដ្ឋាភិបាល និងអង្គការសហគមន៍មូលដ្ឋាន</u>

| ល.រ | ឈ្មោះបណ្តាញ | វិស័យ | ប្រភេទសមាជិកភាព |
|---|---|---|---|
| ១ | បណ្តាញជនជាតិដើមភាគតិច អាយរ៉ាម | ជនជាតិដើមភាគតិច ដីធ្លី សិទ្ធិជនជាតិដើមភាគតិច និងទំទាស់នានា ដែលទាក់ទិនផលប្រយោជន៍ជនជាតិដើមភាគតិចកម្ពុជា | អង្គការសហគមន៍ជនជាតិដើមភាគតិច |
| ២ | បណ្តាញព្រៃឈើ និងជនជាតិដើមភាគតិច | ព្រៃឈើ ដីធ្លី ជនជាតិដើមភាគតិច និងសិទ្ធិមនុស្សដែលពាក់ព័ន្ធវិស័យខាងលើ | អង្គការជាតិ ក្នុងស្រុក អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសហគមន៍មូលដ្ឋាន |
| ៣ | បណ្តាញសហគមន៍កសិកម្ម | កសិកម្ម ផលិតផល និងទីផ្សារ | សហគមន៍កសិកម្ម និងក្រុមផលិតកសិកម្ម |

[27] តាមការពិគ្រោះយោបល់ជាមួយសមាជិកបណ្តាញអង្គការជាតិមិនមែនរដ្ឋាភិបាលខេត្តពោធិ៍សាត់ និងកំពង់ឆ្នាំង។

[28] បណ្តាញសហគមន៍ព្រៃឡង់ និងបណ្តាញជនជាតិដើមភាគតិច។

| | | | |
|---|---|---|---|
| ៤ | បណ្ដាញសហគមន៍ព្រៃឈើ | ព្រៃឈើ និងព្រៃសហគមន៍ក្នុងដែនសមត្ថកិច្ច រដ្ឋបាលព្រៃឈើ នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ | អង្គការជាតិ ក្នុងស្រុក អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសហគមន៍មូលដ្ឋាន |
| ៥ | បណ្ដាញសហគមន៍តំបន់ការពារធម្មជាតិ | ព្រៃឈើ និងព្រៃសហគមន៍ក្នុងដែនសមត្ថកិច្ច ក្រសួងបរិស្ថាន | អង្គការជាតិ ក្នុងស្រុក អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសហគមន៍មូលដ្ឋាន |
| ៦ | បណ្ដាញទន្លេ | ទន្លេមេគង្គ | អង្គការជាតិ ក្នុងស្រុក អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសហគមន៍មូលដ្ឋាន |
| ៧ | បណ្ដាញរ៉េត អង្គការមិនមែនរដ្ឋាភិបាល | ព្រៃឈើ បរិស្ថាន ជីវសាស្ត្រចម្រុះ ដីធ្លី និងជនជាតិដើមភាគតិច | អង្គការជាតិ ក្នុងស្រុក អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសហគមន៍មូលដ្ឋាន |
| ៨ | បណ្ដាញអង្គការមិនមែនរដ្ឋាភិបាលពោធិ៍សាត់ | អន្តរវិស័យ ក្នុងដែនសមត្ថកិច្ចខេត្តពោធិ៍សាត់ | អង្គការជាតិ ក្នុងស្រុក អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសហគមន៍មូលដ្ឋាន |
| ៩ | បណ្ដាញព្រៃឡង់ | ព្រៃឈើ បរិស្ថាន ជីវសាស្ត្រចម្រុះ ដីធ្លី និងជនជាតិដើមភាគតិច។ វិសាលភាពបួនខេត្តកំពង់ធំ ព្រះវិហារ ក្រចេះ និងស្ទឹងត្រែង | អង្គការជាតិ ក្នុងស្រុក អន្តរជាតិ ដៃគូអភិវឌ្ឍន៍ និងអង្គការសហគមន៍មូលដ្ឋាន |

### ៤.៣ សមាជិកភាព និងការគ្រប់គ្រងសមាជិក

ភស្តុតាងមួយចំនួន បានបង្ហាញពីការស្ម័គ្រចិត្តដោយខ្លួនឯង ក្នុងការដាក់ពាក្យចូលជាសមាជិកអង្គការសហគមន៍មូលដ្ឋាន ដូចជាពាក្យស្នើសុំជាដើម ត្រូវបានបង្ហាញជូនដោយគណៈកម្មការអង្គការសហគមន៍មូលដ្ឋាន ក្នុងពេលចុះទៅជួបពិភាក្សាតាមសហគមន៍។ អង្គការសហគមន៍មូលដ្ឋានខ្លះ មានគោលការណ៍សាមញ្ញក្នុងការអនុញ្ញាតឱ្យចូលជាសមាជិក ដោយអនុញ្ញាតប្រជាពលរដ្ឋគ្រប់អាយុចាប់ពី១៨ឆ្នាំ អាចដាក់ពាក្យស្នើសុំជាសមាជិក។ សហគមន៍មួយចំនួនទៀត អនុញ្ញាតមួយគ្រួសារ អាចដាក់ពាក្យសុំចូលជាសមាជិកបានតែតំណាងម្នាក់ប៉ុណ្ណោះ។ ជាក់ស្តែង គណៈកម្មការមួយចំនួនធំ មានការយល់ដឹងពីករណីនេះ តែសមាជិកមួយចំនួនធំ មិនបានយល់ដឹងលើករណីនេះទេ ដោយពួកគេទុកចិត្តលើការសម្រេចចិត្តរបស់គណៈកម្មការក្នុងការអនុញ្ញតឱ្យចូលជាសមាជិក ឬមិនអនុញ្ញាត។ តែក៏មានការបើកចំហក្នុងការពិគ្រោះយោបល់ផងដែរ ក្នុងករណីប្រជាពលរដ្ឋណាម្នាក់ត្រូវបានបដិសេធមិនឱ្យចូលជាសមាជិក។ ភាពជាសមាជិក អង្គការសហគមន៍មូលដ្ឋានខ្លះ គឺតម្រូវឱ្យមានការបង់វិភាគទានក្នុងទំហំសាច់ប្រាក់តិចតួចមួយ ដើម្បីពញ្ញាក់ស្មារតីសហគមន៍ថា នោះគឺជាកម្មសិទ្ធិរបស់ពួកគេ ដូច

ជាសហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍ក្នុងតំបន់ការពារធម្មជាតិ សហគមន៍អេកូទេសចរណ៍ធម្មជាតិ។ល។ តែចំពោះសហគមន៍កសិកម្ម ក្រុមសន្សំប្រាក់ ធនាគារភូមិ និងក្រុមសហគ្រាសខ្នាតតូច និងមធ្យម មានការទាមទារឱ្យមានការបង់ជាភាគហ៊ុនចំនួនមួយ ដែលពួកគេបានព្រមព្រៀង និងឯកភាពគ្នាជាគោលការណ៍។ សមាជិកត្រូវបានលើកទឹកចិត្តឱ្យទិញភាគហ៊ុនចូល ក្នុងចំនួនដែលកំណត់ ឬមិនកំណត់ ជាធម្មតា មួយភាគហ៊ុនមានតម្លៃ ១០.០០០ ឬ២០.០០០រៀល[29]។ មានការកត់សំគាល់ថា សមាជិកក្រីក្របំផុតភាគច្រើន មិនមានឱកាសចូលជាសមាជិកទេ ដោយសារតែខ្វះប្រាក់ដាក់ជាភាគហ៊ុន។ ជាធម្មតាសមាជិកណាដាក់ប្រាក់សន្សំ ឬភាគហ៊ុនច្រើន សមាជិកនោះនឹងទទួលបានផលប្រយោជន៍ច្រើន យោងតាមចំនួនទឹកប្រាក់សន្សំ និងចំនួនហ៊ុនបានទិញ។ ករណីនេះបានបង្ហាញពីគម្លាត មិនសមធម៌រវាងសមាជិកក្រខ្លាំង និងសមាជិក ដែលមានជីវភាពគ្រាន់បើ។ គណៈកម្មការអង្គការសហគមន៍មូលដ្ឋានបានទទួលស្គាល់ពីចំណុចខ្សោយនេះ តែមិនអាចដោះស្រាយបាន នោះគឺជាសម្លេងសម្លូហាភាព។ សមាជិកត្រូវបានចងក្រងជារូបភាពភូមិ ឬជាក្រុម ហើយត្រូវបានគ្រប់គ្រង និងចាត់ចែងដោយប្រធានគណៈកម្មការ ឬប្រធានក្រុម[30]។ អង្គការសហគមន៍មូលដ្ឋានខ្លះមានគោលការណ៍ ដែលចែងពីការដាក់ទោស ដល់សមាជិក ដែលបានរំលោភបំពានគោលការណ៍សហគមន៍ តែក្នុងកម្រិតមួយដែលស្រាល។ ជាគោលការណ៍ពួកគេផ្តល់ការណែនាំជាមុនសិន មុនពេលសម្រេចដាក់ទោសណាមួយ ឬត្រូវបណ្តេញចេញ។ ទោះជាយ៉ាងនេះ សហគមន៍ដែលមានលទ្ធភាពអាចរក្សាបាននូវភាពជាសមាជិកមានភាពរឹងមាំ គឺសហគមន៍ទាំងឡាយណា ដែលមានតម្លៃសេដ្ឋកិច្ច ដូចជា សហគមន៍កសិកម្ម សហគមន៍សហគ្រាសខ្នាតតូច និងមធ្យម ក្រុមសន្សំប្រាក់ និងធនាគារភូមិជាដើម។ ចំណែកសហគមន៍ ដែលមិនមានភាពរឹងមាំក្នុងការរក្សាបាននូវសមាជិកភាពដូចជា សហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍ប្រើប្រាស់ទឹកកសិកម្មជាដើម។ នោះក៏ដោយសារ តែសហគមន៍ទាំងអស់នោះទាមទារការចូលរួមវិភាគទានពីសមាជិក ទាំងថវិកា ធន្ទៈ និងកម្លាំងពលកម្ម ហើយមានភាពរសើបខ្លាំង ព្រមទាំងប្រឈមមុខជាមួយគ្រោះថ្នាក់នានាជាដើម។

---

[29] ការបង់វិភាគទានសហគមន៍ និងការដាក់ប្រាក់ភាគហ៊ុន មានចែងក្នុងលក្ខន្តិកៈអង្គការសហគមន៍មូលដ្ឋាន។

[30] គោលការណ៍គ្រប់គ្រងសមាជិកមានចែង ក្នុងបទបញ្ជាផ្ទៃក្នុង ឬលក្ខន្តិកៈសហគមន៍។ តែទោះបីយ៉ាងដូច្នោះក្តីការអនុវត្តជាក់ស្តែងមួយចំនួនមានការខ្វះចន្លោះ ជាពិសេសទាក់ទងទៅនឹងការកោះប្រជុំសមាជិកប្រចាំត្រីមាស និងការពិន័យ។ល។

## ៥.៤ ការគ្រប់គ្រងហិរញ្ញវត្ថុ

ជាទូទៅយើងបានទទួលចម្លើយ ក្នុងពេលពិភាក្សាជាមួយគណៈកម្មការស្ទើតែទាំងអស់ថា សហគមន៍មូលដ្ឋាន[31]មានភាពកម្សោយលើផ្នែកហិរញ្ញវត្ថុ ជាពិសេសការបង្កើតគោលការណ៍ហិរញ្ញវត្ថុ សម្រាប់ការប្រតិបត្តិការហិរញ្ញវត្ថុផ្ទៃក្នុង ប៉ុន្តែមិនមានន័យទាំងស្រុងថា ពួកគេមិនមានសមត្ថភាពក្នុង ការចាត់ចែង និងគ្រប់គ្រងហិរញ្ញវត្ថុទេ។

ទន្ទឹមនឹងនោះ ពួកគេក៏មិនបានបង្ហាញពីភាពកម្សោយលើការប្រតិបត្តិការជាក់ស្តែងផងដែរ ដូចជាចំនួនថវិកា ដែលត្រូវអនុម័តឱ្យប្រើប្រាស់ ថវិកាដែលទុកក្នុងទូដែក ថវិកាដែលត្រូវដាក់នៅ ធនាគារ និងការចាយវាយប្រចាំថ្ងៃ ការកត់ត្រា និងការទុកដាក់ឯកសារហិរញ្ញវត្ថុជាដើម។ កាលពីជាង ៥ ទៅ១០ឆ្នាំមុន ឯកសារហិរញ្ញវត្ថុដូចជា បញ្ជីប្រាក់ចំណូលនិងបញ្ជីប្រាក់ចំណាយ វិក្ក័យបត្រចំណាយ និងចំណូលខ្លះ ត្រូវបានដាក់សៀតតាមតំបូល ឬជញ្ជាំងផ្ទះ និងជង្រុកស្រូវ ដែលជាហេតុធ្វើអោយ ឯកសារមួយចំនួនត្រូវបានបាត់បង់ និងខូចខាត ដោយទឹកភ្លៀង និងការបំផ្លាញដោយសត្វល្អិត។

ការរកឃើញក្នុងកំឡុងពេលសិក្សានេះ ជាពិសេសលើសហគមន៍កសិកម្មទាំង១៧ ដែលស្ថិត នៅ៤ខេត្ត មានខេត្តបាត់ដំបង ពោធិសាត់ កំពង់ឆ្នាំង និងកំពង់ស្ពឺ សម្របសម្រួលដោយអង្គការជីវិតថ្លៃថ្នូ ផ្តល់ថវិកាដោយព្រះវិហារប្រ៊្វាំងឡង់។ សហគមន៍កសិកម្មទាំងអស់នោះ ត្រូវបានបំពាក់ដោយ ប្រព័ន្ធរបាយការណ៍ហិរញ្ញវត្ថុទំនើបមួយ ដែលពួកគេធ្វើរបាយការណ៍ហិរញ្ញវត្ថុបានយ៉ាងល្អ និងគួរឲ្យ ជឿជាក់បាន។ តែទោះបីយ៉ាងដូច្នោះក៏ដោយ សហគមន៍ត្រូវការយុវជនស្មគ្រ័ចិត្ត ដែលមានបទ ពិសោធន៍ប្រើប្រាស់កំព្យូទ័រ ដើម្បីជួយពួកគាត់ក្នុងការបញ្ចូលទិន្នន័យចំណូល និងចំណាយតាម សប្តាហ៍ និងប្រចាំខែជាទៀងទាត់។ តាមការអង្កេតជាក់ស្តែងតាមការិយាល័យ ក្រុមការងារបានមើល ឃើញពីទូឈើសម្រាប់ដាក់ឯកសារ និងរបាយការណ៍ហិរញ្ញវត្ថុ ដែលពួកគាត់ប្រើប្រាស់ជាប្រចាំ។ អង្គការសហគមន៍មូលដ្ឋាន[32] ដែលមានតម្រូវការបំពាក់ប្រព័ន្ធហិរញ្ញវត្ថុនេះជាងគេគឺ ធនាគារភូមិ ក្រុម សន្សំប្រាក់ សហគមន៍សហគ្រាសខ្នាតតូច និងមធ្យម និងសហគមន៍កសិកម្ម ដែលបច្ចុប្បន្ននេះ មិន ទាន់មានលទ្ធភាពបំពាក់នៅឡើយ។ ទោះបីយ៉ាងនេះក្តី គេមិនទាន់ឃើញមានអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិមានប្រព័ន្ធនេះនៅឡើយទេ ក្រៅពីក្រុមហ៊ុនឯកជនដែលមានជំនាញ និងសេវាកម្មបែបនេះ ដូចជា Standard Business Consultant (SBC) ជាដើម។

---

[31] សហគមន៍កសិកម្មនៅខេត្តបាត់ដំបង សហគមន៍ជនជាតិដើមភាគតិចនៅកំពង់ធំ សហគមន៍សហគ្រាសខ្នាតតូចជ័រទឹក នៅមណ្ឌលគីរី និងសហគមន៍នេសាទ និងអេកូទេសចរណ៍នៅកំពត។

[32] របាយការណ៍ទទួលបានពីគណៈកម្មការសហគមន៍កសិកម្មនៅខេត្តកំពង់ឆ្នាំង ដែលគាំទ្រដោយអង្គការ LWD ខេត្តកំពង់ឆ្នាំង។

## ៥.៥ គណនេយ្យភាព និងតម្លាភាព

ជាទូទៅស្ទើរតែអង្គការសហគមន៍មូលដ្ឋានទាំងអស់ ដែលបានធ្វើការពិគ្រោះយោបល់ គឺមិនមានគោលការណ៍គណនេយ្យភាព និងតម្លាភាពដាច់ដោយឡែកទេ តែបានចែងយ៉ាងច្បាស់លាស់ ក្នុងបទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈសហគមន៍របស់ខ្លួន នូវចំណុចរសើបមួយចំនួនធំ ដែលពាក់ព័ន្ធ។ តែ គេអាចមើលឃើញមានភាពរឹងមាំ ក្នុងការអនុវត្តជាក់ស្តែង ក្នុងការប្រតិបត្តិហិរញ្ញវត្ថុ សហគមន៍ដូចជាៈ មុនពេលចាយវាយថវិកា ត្រូវមានការប្រជុំសម្រេចរួមគ្នា តម្លៃនៃទំនិញត្រូវមានការដឹងឮ ពីសមាជិកគណៈកម្មការគ្រប់គ្រង បន្ទាប់មកវាល់ការទិញដូរ ត្រូវមានបង្កាន់ដៃ ឬឯកសារពាក់ព័ន្ធ មានការទុកដាក់បានល្អ ព្រមទាំងការផ្សព្វផ្សាយនៅឯសមាជសហគមន៍ប្រចាំឆ្នាំផងដែរ។ ប៉ុន្តែសមាជិក សមាជិកា និងមនុស្សសំខាន់ៗ របស់អង្គការសហគមន៍មូលដ្ឋានមួយចំនួន មិនទាន់យល់ស៊ីជម្រៅពីនិយមន័យ និងខ្លឹមសារពិតប្រាកដនៃពាក្យ គណនេយ្យ និងតម្លាភាព[33]។ តែសហគមន៍បានទទួលស្គាល់ថា គណនេយ្យភាព និងតម្លាភាព គឺមានសារសំខាន់ សម្រាប់ពួកគេ និងសង្គមទាំងមូល។ ពួកគេចង់ឃើញសហគមន៍ពួកគេ មានគណនេយ្យភាព និងតម្លាភាព ដើម្បីការពារមិនឱ្យមានទំនាស់ផ្ទៃក្នុង ព្រមទាំងបាត់បង់ការគាំទ្រពីស្ថាប័នជំនាញ អាជ្ញាធរដែនដី និងជាពិសេសអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ។ យោងតាមស្ថានភាពជាក់ស្តែង ពួកគេមិនធ្លាប់បានទទួលការបណ្តុះបណ្តាលណាមួយ ពីប្រធានបទដ៏សំខាន់នេះ ដោយសារតែប្រធានបទនេះ មិនពាក់ព័ន្ធជាមួយគម្រោងដែលអង្គការជាតិមិនមែនរដ្ឋាភិបាលកំពុងតែធ្វើការគាំទ្រ ហើយការបណ្តុះបណ្តាលហាក់មានលក្ខណៈចង្អៀត ដោយផ្តោតការយកចិត្តទុកដាក់តែទៅលើប្រធានបទ ដែលម្ចាស់មូលនិធិអនុញ្ញាតឱ្យតែប៉ុណ្ណោះ។ តែអ្វីដែលជាចំណុចខ្លាំងរបស់អង្គការសហគមន៍មូលដ្ឋាន ពួកគេអាចអនុវត្តបាន ព្រមទាំងអាចពន្យល់បានយ៉ាងត្រឹមត្រូវ ដោយប្រើប្រាស់ភាសាមូលដ្ឋាន។ នេះអាចជាឱកាសដ៏ល្អមួយក្នុងការបំពាក់បំប៉ន និងផ្តល់ជាទ្រឹស្តីបន្ថែមទៅលើចំណេះ និងជំនាញ ដែលពួកគេមានស្រាប់ ដើម្បីអាចឱ្យពួកគេមានលទ្ធភាពផ្ទេរចំណេះដឹងទាំងអស់នេះ ដល់សមាជិក និងមនុស្សសំខាន់ៗរបស់ខ្លួន។

## ៥.៦ ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ

តាមការសិក្សាស្រាវជ្រាវនៅមូលដ្ឋាន ជាមួយគណៈកម្មការ និងមនុស្សសំខាន់ៗ របស់អង្គការសហគមន៍មូលដ្ឋាន បានឱ្យឃើញថាការចូលរួមត្រួតពិនិត្យរាល់សកម្មភាព និងភាពរីកចម្រើនរបស់សហគមន៍មូលដ្ឋានប្រព្រឹត្តទៅ ដោយមានការចូលរួមពីគណៈកម្មការដឹកនាំសហគមន៍ តែមិនមានការចូលរួមពេញលេញពីសំណាក់សមាជិកទេ។ ហើយការវាយតម្លៃទៀតសោត ក៏មិនទាន់បានអនុវត្តជា

[33] យោងតាមការពិភាក្សា ក្នុងពេលប្រជុំពិភាក្សាជាមួយក្រុមការងារស្រាវជ្រាវតាមសហគមន៍។

លក្ខណៈស្តង់ដារដែរ។ ជាធម្មតា ទាំងសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍នេសាទ សហគមន៍កសិកម្ម ក្រុមធនាគារភូមិជាដើម គឺធ្វើការត្រួតពិនិត្យ និងវាយតម្លៃសកម្មភាព និងលទ្ធផលសម្រេចបានរបស់ខ្លួនមួយឆ្នាំម្តង។ ដោយធ្វើការផ្សព្វផ្សាយដល់សមាជិកទាំងពីរភេទ ពីសកម្មភាពដែលខ្លួនបានធ្វើ ការលំបាក ឧបសគ្គ ភាពងាយស្រួល និងប្រាក់ចំណេញ ឬខាតប្រចាំឆ្នាំជូនសមាជិក ដើម្បីជ្រាបនិងផ្តល់យោបល់។ សមាជិកអង្គការសហគមន៍មូលដ្ឋានមួយចំនួនធំ នៅតែមានអារម្មណ៍ថាការត្រួតពិនិត្យ និងវាយតម្លៃគឺជាតួនាទីរបស់ថ្នាក់ដឹកនាំគណៈកម្មការ និងអង្គការជាតិក្នុងស្រុក ដែលសម្របសម្រួលតែប៉ុណ្ណោះ។

យើងបានស្វះស្វែង រកមើលទម្រង់បែបបទ ឬតារាងងាយៗ ណាមួយសម្រាប់ធ្វើការត្រួតពិនិត្យ និងវាយតម្លៃសកម្មភាពផែនការរបស់អង្គការសហគមន៍មូលដ្ឋាន ក្នុងពេលសិក្សាស្រាវជ្រាវ តែមិនមានទម្រង់ណាមួយត្រូវបានរកឃើញទេ សម្រាប់អង្គការសហគមន៍មូលដ្ឋានទាំងអស់ ដែលក្រុមការងារបានទៅជួបពិភាក្សា ក្នុងពេលធ្វើរបាយការណ៍នេះ។ ប៉ុន្តែក្រុមការងារបានសង្កេតឃើញថាសមាជិកគណៈកម្មការខ្លះមានទម្លាប់នាំយកមកជាមួយនូវកូនសៀវភៅ និងប៊ិចសម្រាប់ធ្វើការកត់ត្រារាល់កិច្ចប្រជុំនានានៅសហគមន៍ និងនៅក្រៅសហគមន៍។ ចំណុចនេះអាចជា ចំណុចផ្តើមល្អមួយដើម្បីធ្វើការបង្កើនសមត្ថភាពពួកគេដោយធ្វើការចាប់ផ្តើមពីអ្វី ដែលពួកគេមានស្រាប់។

ទោះបីយ៉ាងនោះក្តី គណៈកម្មការអង្គការសហគមន៍មូលដ្ឋានបានបង្ហាញពីឆន្ទៈខ្ពស់ក្នុងការទទួលយកការបណ្តុះបណ្តាលដែលទាក់ទិនទៅនឹងប្រធានបទនេះ នោះក៏ដោយសារតែពួកគេមានការពិបាកក្នុងការរៀបចំបង្ហាញជូនសមាជិករបស់ខ្លួន នៅឯកិច្ចប្រជុំ ឬសមាជប្រចាំឆ្នាំ នូវលទ្ធផលដែលសហគមន៍សម្រេចបានប្រចាំឆ្នាំនីមួយៗ។ បទពិសោធន៍បច្ចុប្បន្ន ពួកគេធ្វើរបាយការណ៍ជូនសមាជិករបស់ខ្លួន ដោយការចងចាំ និងការកត់ត្រាទុករៀងៗខ្លួន របស់សមាជិកគណៈកម្មការ។

### ៥.៧ យុទ្ធសាស្ត្រ និងការធានានិរន្តរភាព

អង្គការសហគមន៍មូលដ្ឋាន ដែលបានជួបពិភាក្សា គឺមិនទាន់មានផែនការយុទ្ធសាស្ត្ររយៈពេលវែង និងនិរន្តរភាពទេ តែមានស្មារតីនៃការយល់ដឹងពីផែនការយុទ្ធសាស្ត្ររយៈពេលវែង និងនិរន្តរភាពនេះ ថាមានសារសំខាន់សម្រាប់សហគមន៍រយៈពេលវែង ជាពិសេសសម្រាប់ក្មេងជំនាន់ក្រោយក្នុងការបន្តសកម្មភាពរបស់សហគមន៍។ គោលបំណងរបស់សមាជិករបស់អង្គការសហគមន៍មូលដ្ឋានភាគច្រើន គឺចង់បានលទ្ធផលរយៈពេលខ្លី ជាពិសេសតម្លៃសេដ្ឋកិច្ច ដើម្បីធ្វើឱ្យជីវភាពពួកគេមានភាពល្អប្រសើរឡើងដោយការប្រកួតប្រជែងជាមួយមជ្ឈដ្ឋានខាងក្រៅ ខណៈដែលគណៈកម្មការភាគច្រើនខ្វាយខ្វល់ផលប្រយោជន៍សហគមន៍រយៈពេលវែង។ មានមូលហេតុជាច្រើន ដែលបណ្តាលឱ្យសមាជិកពួកគេមិនសូវខ្វល់ខ្វាយ ក្នុងការបង្កើតឱ្យមានផែនការយុទ្ធសាស្ត្ររយៈពេលវែង និងនិរន្តរ

ភាព ដូចជា ខ្វះការយល់ដឹងពីរបៀបនៃការធ្វើផែនការយុទ្ធសាស្ត្រ និងម្យ៉ាងទៀតដោយគ្មានការសម្របសម្រួលណាមួយពីអង្គការជាតិមិនមែនរដ្ឋាភិបាល ឬស្ថាប័នជំនាញណាមួយ ដើម្បីជួយពួកគេក្នុងការផលិតផែនការនេះ។

ប៉ុន្តែ គណៈកម្មការគ្រប់គ្រងបានបង្ហាញថា យុទ្ធសាស្ត្ររយៈពេលវែង និងនិរន្តរភាព ដែលពួកគេស្រមើស្រមៃ គឺមានក្នុងសណ្តានចិត្ត និងឆន្ទៈរបស់គណៈកម្មការគ្រប់គ្រង តែមិនទាន់បានចងក្រង។ ការដែលខ្វះនូវផែនការយុទ្ធសាស្ត្ររយៈពេលវែង និងនិរន្តរភាពធ្វើឱ្យផែនការប្រតិបត្តិប្រចាំថ្ងៃពួកគេហាក់មានភាពចង្អៀត ហើយដំណើរការទៅបានអាស្រ័យទៅនឹងការគាំទ្រ និងសម្របសម្រួលពីអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិនានា ហើយករណីនេះជំរុញឱ្យអង្គការសហគមន៍មូលដ្ឋាន គ្មានទំនុកចិត្តលើខ្លួនឯង បាត់បង់អំណាចសម្រេចចិត្ត គ្មានសម្លេងក្នុងការគាំទ្រគ្នាឯង ហើយរុញច្រានសហគមន៍ពឹងពាក់ខាងក្រៅកាន់តែខ្លាំងឡើង។

តែទោះយ៉ាងដូច្នោះក្តី យើងបានអង្កេតឃើញថា អង្គការសហគមន៍មូលដ្ឋានមួយចំនួន ដូចជា៖ សហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍ក្នុងតំបន់ការពារធម្មជាតិ និងសហគមន៍កសិកម្ម មានទម្រង់ផែនការស្រាប់[34] ដែលបានតាក់តែងដោយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងក្រសួងបរិស្ថាន តែផែនការយុទ្ធសាស្ត្រ ឬហៅថាផែនការគ្រប់គ្រងនោះ មានរយៈពេលតែ៥ឆ្នាំប៉ុណ្ណោះ ហើយផែនការនេះទៀតសោត ផ្តោតការយកចិត្តទុកលើកិច្ចការបច្ចេកទេស សម្រាប់ការគ្រប់គ្រង ដូចជា ការបែងចែកតំបន់ ការដកហូត ការថែទាំ និងការដាំស្តារ ព្រមទាំងយន្តការបែងចែកផលប្រយោជន៍ជាដើម។ល។ ទន្ទឹមនឹងនោះ ផែនការគ្រប់គ្រងរយៈពេលវែងនោះ ទាមទារការទទួលស្គាល់ តាមរយៈការចុះហត្ថលេខា ដោយស្ថាប័នជំនាញ។ ចំណែកអង្គការសហគមន៍មូលដ្ឋានដទៃទៀត មិនមានទម្រង់ ឬបែបផែនណាមួយ ជាគំរូនៅឡើយទេ។

## ៥.៨ ការពង្រឹងសមត្ថភាព និងការយល់ដឹង

មិនមានផែនការស្តីពីការពង្រឹងសមត្ថភាព និងបង្កើនការយល់ដឹង ដែលធ្វើឡើងដោយអង្គការសហគមន៍មូលដ្ឋាននៅឡើយទេ។ នោះក៏ព្រោះតែគ្រប់សកម្មភាពពង្រឹងសមត្ថភាព ត្រូវបានសម្របសម្រួលរៀបចំឱ្យដោយអង្គការជាតិមិនមែនរដ្ឋាភិបាល និងអន្តរជាតិ ដែលបានកំណត់យកអង្គការសហគមន៍ពួកគេ ជាក្រុមគោលដៅ ។ សកម្មភាពដែលអង្គការ មិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិធ្វើការពង្រឹងសមត្ថភាព និងបង្កើនការយល់ដឹងដល់គណៈកម្មការអង្គការសហគមន៍មូលដ្ឋានមានដូចជា៖ វគ្គបណ្តុះបណ្តាល សិក្ខាសាលា ទស្សនកិច្ចសិក្សា ការបង្វឹក និងការធ្វើបង្ហាញ តាមផែនការប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ ។ល។ ដោយប្រើប្រាស់កញ្ចប់ថវិការបស់អង្គការទាំងអស់នោះ។

[34] គោលការណ៍ណែនាំស្តីពីការបង្កើតសហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ សហគមន៍នេសាទ និងគំរូផែនការគ្រប់គ្រង ផ្សាយចេញក្នុងឆ្នាំផ្សេងៗ ដោយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ព្រមទាំងក្រសួងបរិស្ថាន។

ទន្ទឹមនឹងនោះ ពួកគេក៏ធ្លាប់បានទទួលការបណ្តុះបណ្តាល និងពង្រឹងសមត្ថភាពតាមរយៈក្រសួង និង មន្ទីរជំនាញរាជរដ្ឋាភិបាលផងដែរ។ អង្គការសហគមន៍ដែលមានឱកាសខ្ពស់ក្នុងការទទួលនូវសេវាកម្ម ពង្រឹងសមត្ថភាពទាំងអស់នោះមានដូចជា សហគមន៍កសិកម្ម សហគមន៍ព្រៃឈើ សហគមន៍នេសាទ ព្រមទាំងសហគមន៍សហគ្រាសខ្នាតតូច និងមធ្យម។ល។

បន្ទាប់ពីទទួលបានការបណ្តុះបណ្តាលពីអង្គការជាតិ និងអន្តរជាតិ ព្រមទាំងពីស្ថាប័នជំនាញ របស់រាជរដ្ឋាភិបាលមក ថ្នាក់ដឹកនាំអង្គការសហគមន៍មូលដ្ឋានទាំងនោះ បានយកចំណេះដឹង ដែល ខ្លួនទទួលបាន ធ្វើការពង្រឹងស្ថាប័នរបស់ខ្លួនតាមរយៈកិច្ចប្រជុំគណៈកម្មការរៀងរាល់មួយខែម្តង កិច្ច ប្រជុំមិនកំណត់នៅពេលមានករណីពិសេស និងកិច្ចប្រជុំរួម ឬសមាជប្រចាំឆ្នាំ។ នេះគឺផ្នែកខ្លាំងមួយ ដែលអង្គការសហគមន៍មូលដ្ឋាន[35] ដែលបានគាំទ្រពីស្ថាប័នទាំងអស់នោះ មានឱកាសខ្ពស់ក្នុងការ ទទួលបាននូវសេវាកម្មពង្រឹងស្ថាប័ន និងបង្កើនការយល់ដឹងពីស្ថាប័នទាំងអស់នោះ។ សមាជិកខ្លះ បានរាយការណ៍ក្នុងពេលសិក្សានេះថា ពួកគាត់បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញកសិកម្ម និង ជំនាញបង្កើតមុខរបរពីអង្គការ និងស្ថាប័នរដ្ឋ ជិត១០ដង រាប់ទាំងទស្សនកិច្ចចំនួន៣ លើកផងដែរ ក្នុង ឆ្នាំ២០១៧។

### ៨.៩ ការរកឃើញផ្សេងទៀត

មានការលើកឡើងជាច្រើន ពីថ្នាក់ដឹកនាំគណៈកម្មការក្នុងពេលចុះពិគ្រោះយោបល់ ដែល ចំណុចទាំងអស់នោះ មិនមានចែងក្នុងគោលការណ៍ណែនាំស្តីពីការប្រតិបត្តិរបស់អង្គការសហគមន៍ មូលដ្ឋានទេ។ ចំណុចទាំងអស់នោះមានដូចជា៖ ភាពជាអ្នកដឹកនាំសហគមន៍ និងការពង្រឹងលើការអនុ វត្តតួនាទី និងភារកិច្ចសមាសភាពគណៈកម្មការដឹកនាំសហគមន៍ ដែលមានតួនាទីដូចជា ប្រធាន អនុ ប្រធាន ហិរញ្ញិក និងលេខាធិការ។ ភាពទន់ខ្សោយក្នុងការបំពេញកាតព្វកិច្ច ជាពិសេសការពិពណ៌នា ភារកិច្ចរបស់គណៈកម្មការ មានស្ទើរតែគ្រប់សហគមន៍ទាំងអស់ ទោះបីអង្គការសហគមន៍មូលដ្ឋាន ទាំងអស់កំពុងតែគាំទ្រ និងសម្របសម្រួលដោយស្ថាប័ននានាក៏ដោយ ជាក់ស្តែងដូចជា សហគមន៍ កសិកម្ម សហគមន៍នេសាទ ធនាគារភូមិ សហគមន៍ព្រៃឈើ សហគមន៍អេកូទេសចរណ៍ សហគមន៍ ជនជាតិដើមភាគតិច ធនាគារស្រូវ ធនាគារសត្វ ក្រុមប្រើប្រាស់ទឹកកសិកម្ម និងសហគមន៍ក្នុងតំបន់ ធម្មជាតិជាដើម។ល។

---

[35] អង្គការសហគមន៍មូលដ្ឋានទាំងអស់ ដែលបានសិក្សាស្រាវជ្រាវ បាននិងកំពុងតែទទួលការពង្រឹងសមត្ថភាពពី អង្គការមួយចំនួនដូចជា៖ CL/ LWD, FACT, Forym Syd, ICSO, V-build, CRDT, Live & Learn, PK, EPDO, PVT និង AFD ព្រមទាំងពីមន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ និងមន្ទីរបរិស្ថាន។

ជាការលើកឡើង ម្តងហើយម្តងទៀតរបស់អង្គការសហគមន៍មូលដ្ឋាន ដែលទាក់ទងទៅនឹងភាពជាអ្នកដឹកនាំគឺថា សមាជិកគណៈកម្មការមួយចំនួនធំ[36]មិនបានបំពេញតាមតួនាទី និងភារកិច្ចបានត្រឹមត្រូវនៅឡើយ នោះក៏ដោយសារពួកគេ មិនសូវមានសមត្ថភាព និងបទពិសោធន៍គ្រប់គ្រង ខ្វះឆន្ទៈក្នុងការបំពេញកាតព្វកិច្ច និងខ្វល់ខ្វាយតែរឿងសេដ្ឋកិច្ច និងមុខរបរផ្ទាល់ខ្លួន។ ជាទូទៅគណៈកម្មការគ្រប់គ្រងត្រូវបានបោះឆ្នោតដោយសមាជិកសហគមន៍ យោលតាមលក្ខណៈវិនិច្ឆ័យមួយចំនួន តែឆន្ទៈបំពេញការងារជូនសហគមន៍ដោយស្មគ្រ័ចិត្ត គឺជាចំណុចអទិភាពនៃការជ្រើសរើស។ អាណត្តិរបស់គណៈកម្មការអាចពី៣ទៅ៥ឆ្នាំ។ សមាជិកគណៈកម្មការខ្លះ ត្រូវបានពន្យាចាប់ពី២ទៅ៣អាណត្តិ ដោយសារពិបាកស្វែងរកមនុស្សដែលមានសមត្ថភាព និងឆន្ទៈ។ ភាពប្រឈមខ្លាំងជាពិសេសជាមួយសមាភាពគណៈកម្មការថ្មី ដែលមិនសូវមានចំណេះ និងបទពិសោធន៍។ តួនាទីដែលប្រឈមការលំបាកជាងគេគឺ ប្រធាន និងហិរញ្ញិក។ ដោយសារតែមិនមានសមត្ថភាពបំពេញការងារអោយបានពេញលេញ ព្រមទាំងភាពជឿជាក់លើខ្លួនឯង ករណីនេះ បានធ្វើអោយប៉ះទង្គិចដល់សតិអារម្មណ៍ ហើយធ្វើអោយបាត់បង់ឆន្ទៈបន្តិចៗ ក្នុងការដឹកនាំការងាររបស់អង្គការសហគមន៍មូលដ្ឋាន។ ករណីដោយឡែកមួយទៀត សមាជិកសហគមន៍មួយចំនួនដែលមានសមត្ថភាពគ្រប់គ្រាន់ បែជាសហគមន៍មិនផ្តល់ទំនុកចិត្តផ្តល់សម្លេងឆ្នោតទៅវិញ នោះក៏ព្រោះតែសមាជិកមិនពេញចិត្តលើឆន្ទៈ និងភាពស្មោះត្រង់របស់បុគ្គលនោះ តែករណីនេះមានតិចតួច។

ចំពោះការអនុវត្តតាមតួនាទី និងភារកិច្ចរបស់សមាជិកសមាជិកគណៈកម្មការគ្រប់គ្រងវិញ យើងបានរកឃើញថា គណៈកម្មការមួយចំនួនធំ មិនបានបំពេញភារកិច្ចបានត្រឹមត្រូវនៅឡើយ នោះក៏ដោយសារៈ ទី១ ពួកគេមិនយល់ច្បាស់ពីភារកិច្ចនីមួយៗ ដែលបានចែងក្នុងបទបញ្ជាផ្ទៃក្នុង។ ទី២ ដោយសំអាង និងភាពពឹងពាក់សមាជិកគណៈកម្មការដទៃទៀត ឬបុគ្គលិកអង្គការអោយធ្វើជួស និងទី៣ មិនមានស្ថាប័នណាមួយ ជួយបណ្តុះបណ្តាលពីភារកិច្ចជាក់លាក់ទាំងអស់នោះ ព្រោះការបណ្តុះបណ្តាលភាគច្រើនលើសលុបកន្លងមក គឺសំដៅទៅលើតែប្រធានបទទាំងឡាយណា ដែលពាក់ព័ន្ធទៅនឹងគម្រោងរបស់ស្ថាប័ន ជាពិសេសប្រធានបទ ដែលទាក់ទិនទៅនឹងការងារបច្ចេកទេសជាដើម។ មានការលើកឡើងជាសំណូមពរពីអ្នកបានផ្តល់ព័ត៌មានស្ទើរតែទាំងអស់ ដោយស្នើសុំឱ្យបញ្ចូលប្រធានបទទាំង២ ទៅក្នុងវគ្គបណ្តុះបណ្តាលអង្គការសហគមន៍មូលដ្ឋាន ទោះបីប្រធានបទទាំងនេះមិនពាក់ព័ន្ធទៅនឹងគម្រោងរបស់អង្គការក៏ដោយចុះ ព្រោះប្រធាននេះ អាចផ្តល់វិភាគទានដល់ការគ្រប់គ្រងអង្គការសហគមន៍មូលដ្ឋានប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព។

[36] ការលើកឡើងរបស់គណៈកម្មការស្ទើរតែទាំងអស់ បានជួបពិភាក្សាក្នុងកំឡុងពេលសិក្សានេះ ទាំងនៅបាត់ដំបង កំពង់ធំ មណ្ឌលគីរី កំពង់ឆ្នាំង កំពត ព្រៃវែង និងកោះកុង។

មានការកត់សំគាល់ថា អង្គការសហគមន៍មូលដ្ឋាន ដែលធ្វើការលើវិស័យកសិកម្ម និងសហគមន៍ខ្នាតតូច និងមធ្យម មិនសូវមានភាពប្រឈម នឹងបញ្ហានេះទេ នោះក៏ដោយសារតែសហគមន៍ពួកគេមានប្រាក់ចំណូលជាទៀងទាត់ នៃតម្លៃសេដ្ឋកិច្ចនោះ បានដឹកនាំពួកគេឱ្យមកបំពេញការងារដោយខានពុំបាន។ យោងតាមរបាយការណ៍ហិរញ្ញវត្ថុ របស់ធនាគារភូមិ សហគមន៍កសិកម្ម និងក្រុមសន្សំប្រាក់យើងបានរកឃើញថា គណៈកម្មការទាំងអស់ទទួលបាននូវផលប្រយោជន៍ជាសាច់ប្រាក់ ដោយគណនាតាមចំនួនថ្ងៃដែលពួកគេមកបំពេញកិច្ចការរបស់ពួកគេជូនសហគមន៍។

## ៦. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

ការសន្និដ្ឋានជារួម មានការលំបាកដោយសារចរិតលក្ខណៈនៃករណីនីមួយៗ មានភាពខុសប្លែកគ្នាខ្លាំងពេក។ ជាក់ស្តែងដូចជា លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន យើងមើលជារូបភាពរួម សមាជិកសមាជិកា របស់អង្គការសហគមន៍មូលដ្ឋានមានសកម្មភាពផុសផុលក្នុងការចូលរួមអភិវឌ្ឍន៍សហគមន៍របស់ខ្លួន តាមរយៈការចូលរួមចងក្រងជាសមាគម និងជាក្រុម ព្រមទាំងដំណើរការ ព្រមទាំងសកម្មភាពអភិវឌ្ឍន៍ផ្សេងៗទៀត តែពួកគេទាំងអស់នោះមួយចំនួនមិនបានយល់ដឹងជ្រៅជ្រះពីគោលនយោបាយ ច្បាប់ និងគោលការណ៍នានា ដែលគាំទ្រដល់ដំណើការនៃការអភិវឌ្ឍនោះទេ។ ចំពោះការទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ ជាទូទៅគេមើលឃើញថា សហគមន៍មូលដ្ឋានមានភាពរឹងមាំក្នុងការទំនាក់ទំនងផ្ទៃក្នុងរបស់ខ្លួន ជាពិសេសរវាងគណៈកម្មការ និងសមាជិក តែពួកគេនៅមានចំណុចខ្សោយច្រើនក្នុងទំនាក់ទំនងជាមួយស្ថាប័នខាងក្រៅ រួមទាំងការចងបណ្តាញជាដើម។ ទោះបីយ៉ាងនោះក្តី អង្គការសហគមន៍មូលដ្ឋាន មានការចូលរួមយ៉ាងផុសផុលប្រសិនបើមានការសម្របសម្រួលពីស្ថាប័ន ឬអង្គការណាមួយ។

ដោយឡែក សមាជិកភាព និងការគ្រប់គ្រងសមាជិក យើងមើលឃើញថា ការស្ម័គ្រចិត្តសុំចូលជាសមាជិកភាពមានដំណើរការជាធម្មតា មិនមានរូបភាពជាលក្ខណៈបង្ខំទេ។ ប៉ុន្តសមាជិកមួយចំនួនតូចបានសុំចូលជាសមាជិកដោយសារតែតាមគេ និងចង់បានផលប្រយោជន៍ដែលជាតម្លៃសេដ្ឋកិច្ចរយៈពេលខ្លី។ ចំពោះការគ្រប់គ្រងសមាជិក ជាទូទៅនៅមានកម្រិត ទោះបីជាអង្គការសហគមន៍មូលដ្ឋានមួយចំនួន មានបទបញ្ជាផ្ទៃក្នុង និងលក្ខន្តិកៈក៏ដោយ ក៏គោលការណ៍គ្រប់គ្រងសមាជិកមួយចំនួនមិនទាន់បានអនុវត្តពេញនៅឡើយ។ ការគ្រប់គ្រងហិរញ្ញវត្ថុរបស់អង្គការសហគមន៍មូលដ្ឋាន អង្គការសហគមន៍មូលដ្ឋានភាគច្រើនអាចគ្រប់គ្រងហិរញ្ញវត្ថុរបស់សហគមន៍ខ្លួនបានល្អ ទោះបីពួកគេមិនយល់ច្បាស់លាស់ពីទ្រឹស្តី ស្តីពីហិរញ្ញវត្ថុ និងការគ្រប់គ្រងហិរញ្ញវត្ថុក្តី។

គណនេយ្យភាព និងតម្លាភាព ជាខ្លឹមសារមួយ ដែលអង្គការសហគមន៍មូលដ្ឋានមិនសូវយល់ពីអត្ថន័យ និងខ្លឹមសារ តែអង្គការសហគមន៍ភាគច្រើនបានអនុវត្តយ៉ាងត្រឹមត្រូវ នោះក៏ដោយសារមនសិការ និងឆន្ទៈក្នុងការធ្វើឱ្យមានភាពត្រឹមត្រូវ និងច្បាស់លាស់ក្នុងអង្គការសហគមន៍មូលដ្ឋានរបស់ពួកគេ។ ការចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃ របស់អង្គការសហគមន៍មូលដ្ឋាន យន្តការនៃការអនុវត្ត ចូលរួមអនុវត្ត ត្រួតពិនិត្យ និងវាយតម្លៃមិនទាន់មានទេ តែសកម្មភាពមួយចំនួនត្រូវបានយកមកប្រើប្រាស់ ដើម្បីឆ្លើយតបទៅនឹង សកម្មភាពនោះដូចជា កិច្ចប្រជុំ ឬសមាជប្រចាំឆ្នាំ។

ចំណែកយុទ្ធសាស្ត្រ និងការធានានិរន្តរភាពរបស់អង្គការសហគមន៍មូលដ្ឋាន ភាពយូរអង្វែងរបស់អង្គការសហគមន៍មូលដ្ឋាន គឺជាសេចក្តីបំណងប្រាថ្នារបស់សមាជិកសមាជិកាអង្គការសហគមន៍មូលដ្ឋាន ដែលជាបំណងមួយក្នុងគោលបំណងមួយចំនួនរបស់សហគមន៍គឺចង់ឱ្យយុវជនដែលជាកូនចៅបន្តសកម្មភាព តែពួកគេមិនទាន់មានសមត្ថភាពក្នុងការបង្កើតយុទ្ធសាស្ត្រនៅឡើយ សូម្បីតែទម្រង់ និងសមាសភាពសំខាន់ៗ ក្នុងការសរសេរផែនការយុទ្ធសាស្ត្រក៏ពួកគេមិនទាន់បានដឹងជ្រៅជ្រះផងដែរ។ ការពង្រឹងសមត្ថភាព និងការយល់ដឹងផ្នែកនេះ ទោះបីអង្គការសហគមន៍មូលដ្ឋានមិនមានផែនការពង្រឹងសមត្ថភាព និងការបង្កើនការយល់ដឹងដោយខ្លួនឯង តែអង្គការសហគមន៍មូលដ្ឋានទាំងនោះត្រូវបានយកចិត្តទុកដាក់ ធ្វើការបង្កើនសមត្ថភាព និងពង្រឹងសមត្ថភាពតាមសកម្មភាពមួយចំនួនដូចជា៖ សិក្ខាសាលាបណ្តុះបណ្តាល វគ្គបណ្តុះបណ្តាលបច្ចេកទេសខ្លី និងធម្យម ការបង្ហឹក ការរៀបចំសកម្មភាពគំរូ និងទស្សនកិច្ចសិក្សាជាដើម។ល។ ហើយអ្វីដែលជា ចំណុចខ្លាំងរបស់អង្គការសហគមន៍មូលដ្ឋានគឺចំណេះ ជំនាញ និងបទពិសោធន៍ដែលទទួលបានពីសកម្មភាពបណ្តុះបណ្តាលត្រូវបានយកទៅអនុវត្ត និងផ្សព្វផ្សាយដល់សមាជិករបស់ខ្លួន តាមរយៈកិច្ចប្រជុំ និងសមាជជាដើម។

យោងតាមការវិភាគតាមតារាង និងក្រាហ្វិកខាងលើ ជាសេចក្តីសន្និដ្ឋានរួម យើងអាចធ្វើចំណាត់ថ្នាក់ ដូចតទៅ៖ *យុទ្ធសាស្ត្រ និងការធានានិរន្តភាព* គឺជាផ្នែកដ៏សំខាន់បំផុត និងអាទិភាពទី១ *ភាពជាអ្នកដឹកនាំ*ជាផ្នែកអាទិភាពទី២ *ការទំនាក់ទំនង កិច្ចសហប្រតិបត្តិការ និងការចងបណ្តាញ* គឺជាផ្នែកអាទិភាពទី៣ *ការគោរពតាមតួនាទី និងភារកិច្ច* ជាអាទិភាពទី៤ *ការចូលរួមត្រួតពិនិត្យ និងវាយតម្លៃ*ជាទិភាពទី៥ *លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍន៍អង្គការ*សហគមន៍មូលដ្ឋានអាទិភាពទី៦ *សមាជិកភាព និងការគ្រប់គ្រងសមាជិក* អាទិភាពទី៧ *គណនេយ្យភាព និងតម្លាភាព* ជាអាទិភាពទី៨ *ការពង្រឹងសមត្ថភាព និងការយល់ដឹង* ជាអាទិភាពទី៩ និង *ការគ្រប់គ្រងហិរញ្ញវត្ថុ* គឺជាអាទិភាពទី១០ ក្នុងដំណើរការ ការកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាន ដែលឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដ ស្របនឹងស្ថានភាពបច្ចុប្បន្ន របស់អង្គការសហគមន៍មូលដ្ឋាននៅកម្ពុជា។

## អនុសាសន៍សម្រាប់ពង្រឹងអង្គការសហគមន៍មូលដ្ឋាន និងកសាងសមត្ថភាព

ឆ្លងតាមការរកឃើញក្នុងពេលសិក្សាស្រាវជ្រាវ ទាំងការសិក្សាលើឯកសារ និងរបាយការណ៍ដែលមានស្រាប់ ដោយអង្គការជាតិមិនមែនរដ្ឋាភិបាល និងអន្តរជាតិ លទ្ធផលសិក្ខាសាលាពិគ្រោះយោបល់ថ្នាក់ជាតិ ការចុះសម្ភាសន៍តាមអង្គការសហគមន៍មូលដ្ឋានតាមខេត្តនានា និងការជួបពិគ្រោះយោបល់ជាមួយអង្គការជាតិក្នុងស្រុក និងអន្តរជាតិពាក់ព័ន្ធមួយចំនួន ដែលបាននិងកំពុងតែបំពេញការងារលើការពង្រឹងស្ថាប័ន និងការកសាងសមត្ថភាពអង្គការសហគមន៍មូលដ្ឋាននានា[37] ដែលអាចទាញជាអនុសាសន៍ ដែលមានប្រយោជន៍ក្នុងការផ្តល់ជាទុនសម្រាប់ ធ្វើការកែទម្រង់ ពង្រឹងស្ថាប័ន និងការកសាងសមត្ថភាព ព្រមទាំងការចងក្រងឯកសារចាំបាច់នានា ឱ្យស្របតាមស្តង់ដារមួយ ដែលធានាថា បន្ទាប់ពីបានទទួលសេវាកម្ម ពង្រឹងស្ថាប័ន និងការបណ្តុះបណ្តាលរួច អង្គការសហគមន៍មូលដ្ឋាន អាចគ្រប់គ្រង និងចាត់ចែងស្ថាប័នដោយខ្លួនបាន ឆ្ពោះទៅរកនិរន្តរភាព ទាំងហិរញ្ញវត្ថុ និងស្ថាប័ន។ អនុសាសន៍ទាំងអស់នោះមានដូចខាងក្រោម៖

**ក. <u>លក្ខណៈផ្លូវច្បាប់ និងការអភិវឌ្ឍអង្គការសហគមន៍មូលដ្ឋាន</u>** - (១) គណៈកម្មការដឹកនាំ និងចាត់ចែងអង្គការសហគមន៍មូលដ្ឋាន គួរត្រូវបានធ្វើឱ្យប្រាកដថា សមាជិករបស់ខ្លួន មានការយល់ដឹងយ៉ាងទូលំទូលាយពីទស្សនៈ គោលការណ៍ គោលបំណង និងដំណើរការ ការបង្កើតអង្គការសហគមន៍មូលដ្ឋាន ឱ្យបានច្បាស់លាស់ជាមុនសិន រួមទាំងលក្ខណៈផ្លូវច្បាប់ តាមរយៈកិច្ចប្រជុំផ្សព្វផ្សាយជាលក្ខណៈឯកជន ឬថ្នាក់ក្រុមតូច ធំ និងជាលក្ខណៈភូមិ ហើយអាចជាកិច្ចប្រជុំជាលក្ខណៈចង្អៀត និងទូលាយជាសាធារណៈ ដែលអាចធ្វើទៅបាន និងសមស្រប។ ករណីពិសេសត្រូវរកស្ថាប័នជំនាញ[38] ដើម្បីជួយសម្របសម្រួល។ ការចងក្រងជាក្រុមសហគមន៍អាចដំណើរការទៅបាន បន្ទាប់ពីពួកគេមានការយល់ដឹងគ្រប់ជ្រុងជ្រោយ ពីផលប្រយោជន៍របស់វា រួមទាំងបទដ្ឋានច្បាប់ និងគោលការណ៍នានាដែលពាក់ព័ន្ធ។ អង្គការសហគមន៍មូលដ្ឋាន ដែលមានភាពទាក់ទិនជាមួយផ្នែកនេះជាអទិភាពបំផុតមានដូចជា សហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍អេកូទេសចរណ៍ធម្មជាតិ សហគមន៍ក្នុងតំបន់ការពារធម្មជាតិ និងសហគមន៍ព្រៃដៃគូជាដើម។ ប្រធានបទជាក់លាក់សម្រាប់ផ្នែកនេះមានដូចជា ទស្សនៈ វិធីសាស្រ្ត និងគោលការណ៍នានាក្នុងដំណើការ ការអភិវឌ្ឍន៍អង្គការសហគមន៍មូលដ្ឋានទាំងទ្រឹស្តីការចូលរួម ទិដ្ឋភាពស្ថាប័ន និងច្បាប់។

**ខ. <u>ទំនាក់ទំនង កិច្ចសហការ និងការចងបណ្តាញ</u>**- (២) អង្គការសហគមន៍មូលដ្ឋានគួរ ត្រូវបង្កើតឱ្យមានគោលការណ៍សាមញ្ញស្តីពី ការទំនាក់ទំនង កិច្ចសហប្រតិបត្តិការ និងការចងបណ្តាញ

---

[37] អង្គការទាំងនោះជាសមាជិករបស់អង្គការគ.ស.ក

[38] ស្ថាប័នជំនាញ គឺជាក្រសួង ឬមន្ទីរដែលមានតួនាទី និងកតព្វកិច្ចលើកិច្ចការនោះ ដូចជារដ្ឋបាលព្រៃឈើ ឬរដ្ឋបាលជលផល។ល។

តាមវិធីមួយ ឬរបៀបមួយ ដែលពួកគេអាចធ្វើទៅបាន។ គោលការណ៍នេះ គួរឱ្យមានចែងពីគុណតម្លៃ និងយុទ្ធសាស្ត្រ ព្រមទាំងរបៀបវារៈ ព្រមទាំងផ្នែកសំខាន់ៗ មានដូចជា គោលបំណង វិធីសាស្ត្រ ឧបករណ៍ និងសកម្មភាពសំខាន់ ក្នុងដំណើការទំនាក់ទំនង សហប្រតិបត្តិការណ៍ និងការភ្ជាប់បណ្តាញ ទាំងក្នុង និងខាងក្រៅសហាគមន៍។ គេអាចបន្ថែមយុទ្ធសាស្ត្រទាំងអស់នេះ ទៅក្នុងបទបញ្ជាផ្ទៃក្នុង ឬលក្ខន្តិកៈ។ អង្គការសហាគមន៍មូលដ្ឋាន ដែលពាក់ព័ន្ធជាមួយផ្នែកនេះ មានដូចជា សហាគមន៍កសិកម្ម សហាគមន៍សហគ្រាសខ្នាតតូច និងធម្យម សហាគមន៍ព្រៃឈើ សហាគមន៍នេសាទ សហាគមន៍តំបន់ការពារធម្មជាតិ និងសហាគមន៍អេកូទេសចរណ៍ធម្មជាតិជាដើម។ ប្រធានបទជាក់លាក់សម្រាប់ផ្នែកនេះមានដូចជា វិធីសាស្ត្រទំនាក់ទំនង និងវិធីសាស្ត្រចងបណ្តាញកំរិតអង្គការសហាគមន៍មូលដ្ឋាន។

**គ. <u>សមាជិកភាព និងការគ្រប់គ្រងសមាជិក</u>** - (៣) អង្គការសហាគមន៍មូលដ្ឋាន គួរត្រូវបានលើកទឹកចិត្តជាពិសេសដល់សមាជិក ដែលងាយរងគ្រោះ មិនសូវមានសម្លេង និងខ្សត់ខ្សោយចំណេះដឹង និងតម្លៃសេដ្ឋកិច្ច ឱ្យមានឱ្កចូលរួមជាសមាជិកឱ្យបានច្រើន តាមដែលអាចធ្វើទៅបាន ដោយការបង្កើតគោលការណ៍កាលានុវត្តភាពងាយៗ ដែលបង្កលក្ខណៈឱ្យពួកគេអាចដាក់ពាក្យចូលជាសមាជិកបាន។ ទន្ទឹមនឹងនោះ គោលការណ៍កាលានុវត្តភាពសាមញ្ញក្នុងការគ្រប់គ្រង និងចាត់ចែងសមាជិក គួរបង្កើតឡើង ដោយមានការចូលរួមពិគ្រោះយោបល់ យ៉ាងទូលំទូលាយជាមួយសមាជិក ក្នុងករណីពិសេសអង្គការសហាគមន៍មូលដ្ឋាន អាចរកជំនួយពីអង្គការនានា ឬអ្នកជំនាញណាមួយ ដើម្បីជួយផ្តល់ប្រឹក្សា។ ការគ្រប់គ្រងសមាជិក ត្រូវអនុលោមតាម លក្ខន្តិកៈ ឬបទបញ្ជាផ្ទៃក្នុងដ៏សាមញ្ញមួយ។ អង្គការដែលមានភាពទាក់ទិនជាមួយផ្នែកនេះ មានដូចជា សហាគមន៍កសិកម្ម សហាគមន៍សហគ្រាសខ្នាតតូច និងមធ្យម សហាគមន៍ព្រៃឈើ សហាគមន៍នេសាទ សហាគមន៍តំបន់ការពារធម្មជាតិ សហាគមន៍អេកូទេសចរណ៍ធម្មជាតិ ក្រុមសន្សំប្រាក់ និងធនាគារភូមិជាដើម។ ប្រធានបទជាក់លាក់សម្រាប់ផ្នែកនេះ មានដូចជា វិធីសាស្ត្របញ្ចូលសមាជិកភាព និងវិធីសាស្ត្រនៃការគ្រប់គ្រង ចាត់ចែងសមាជិក អោយមានប្រសិទ្ធភាព។

**<u>ឃ. ការគ្រប់គ្រងហិរញ្ញវត្ថុ</u>** - (៤) អង្គការសហាគមន៍មូលដ្ឋាន ត្រូវបង្កើតគោលការណ៍គ្រប់គ្រងហិរញ្ញវត្ថុដោយបង្កើតជាគោលការណ៍សាមញ្ញៗ ដូចជា បញ្ជីប្រាក់ចំណូល ចំណាយ តារាងសមតុល្យ ។ល។ ងាយស្រួលអនុវត្ត ស្របតាមស្ថានភាពជាក់ស្តែង តែគ្រប់ជ្រុងជ្រោយ ដើម្បីធានាថា ថវិកាអង្គការសហាគមន៍មូលដ្ឋាន ត្រូវបានចាត់ចែង និងប្រើប្រាស់បានយ៉ាងត្រឹមត្រូវ តម្លាភាព និងគណនេយ្យភាព។ អ្នកកាន់កាប់ហិរញ្ញវត្ថុ និងបេឡា គួរត្រូវបានធ្វើការបណ្តុះបណ្តាលពីជំនាញហិរញ្ញវត្ថុ ដើម្បីអាចឱ្យពួកគេ អាចបំពេញតាមតួនាទី និងកាតព្វកិច្ចបានយ៉ាងត្រឹមត្រូវ។ ករណីរបស់អង្គការសហាគមន៍មូលដ្ឋានខ្លះ ទាមទារឱ្យបង្កើតប្រព័ន្ធហិរញ្ញវត្ថុតាមបច្ចេកវិទ្យាខ្ពស់ ដើម្បីគ្រប់គ្រងទិន្នន័យឱ្យបានត្រឹមត្រូវ ដូចជា ក្រុមសន្សំប្រាក់ សហាគមន៍កសិកម្ម សហាគមន៍សហគ្រាសខ្នាត មធ្យម និងធនាគារភូមិជាដើម។ ប្រធានបទជាក់លាក់សម្រាប់ផ្នែកនេះមានដូចជា មូលដ្ឋានគ្រឹះការគ្រប់គ្រងហិរញ្ញវត្ថុបែប

សាមញ្ញ ការចុះបញ្ជីស្នាមហិរញ្ញវត្ថុ ការទុកដាក់សាច់ប្រាក់ ការចំណាយ និងចំណូល ការរៀបចំឯកសារហិរញ្ញវត្ថុ និងការទុកដាក់ឯកសារ ព្រមទាំងទម្រង់ផ្សេងៗ សម្រាប់ធ្វើរបាយការណ៍ហិរញ្ញវត្ថុ។ល។

**ង. គណនេយ្យភាព និងតម្លាភាព** - (៥) អង្គការសហគមន៍មូលដ្ឋាន គួរបង្កើតឱ្យមានគោលការណ៍ស្តង់ដារគណនេយ្យភាព និងតម្លាភាពសម្រាប់ជាមូលដ្ឋានគ្រឹះ ក្នុងការធ្វើឱ្យប្រាកដថា រាល់សកម្មភាពរបស់ពួកគេ ស្ថិតក្នុងស្ថានភាពដែលធានាគុណតម្លៃពីគណនេយ្យ និងតម្លាភាពដល់សមាជិករបស់ផងខ្លួន និងសង្គម។ ដែលក្នុងគោលការណ៍នោះ គួរចែងពីអាកប្បកិរិយា និងឥរិយាបថដែលបង្ហាញនូវភាពត្រឹមត្រូវ បើកចំហ និងទទួលនូវមតិកែលំអពីសមាជិករបស់ខ្លួន។ ការផ្សព្វផ្សាយរបាយការណ៍ហិរញ្ញវត្ថុ គួរធ្វើឱ្យមានជាលក្ខណៈជាប្រព័ន្ធ និងទៀងទាត់។ អង្គការសហគមន៍មូលដ្ឋានដែលមានភាពទាក់ទិននៅផ្នែកនេះ មានដូចជា ក្រុមសន្សំប្រាក់ សហគមន៍កសិកម្ម សហគមន៍សហគ្រាសខ្នាត មធ្យម និងធនាគារភូមិជាដើម។ ប្រធានបទជាក់លាក់សម្រាប់ផ្នែកនេះមានដូចជា ទស្សនៈជាមូលដ្ឋាន និងវិធីសាស្រ្តអនុវត្តគណនេយ្យភាព និងតម្លាភាពក្នុងផ្ទៃក្នុងរបស់អង្គការសហគមន៍មូលដ្ឋាន ក៏ដូចសង្គមទាំងមូល។

**ច. ការចូលរួមត្រួតពិនិត្យ និងវាយតម្លៃ** - (៦) អង្គការសហគមន៍មូលដ្ឋាន គួរបង្កើតឱ្យមានទម្រង់បែបបទ សម្រាប់ការចូលរួមត្រួតពិនិត្យ និងវាយតម្លៃ ផែនការសកម្មភាពរបស់ខ្លួន ជារបៀបសាមញ្ញ និងងាយស្រួលក្នុងការអនុវត្ត។ នៅក្នុងទម្រង់បែបបទ គួរមានតារាងសុក្រិត ដែលបានបង្ហាញពីសូចនាករជាបរិមាណ និងគុណភាព សម្រាប់ការវាស់វែង រវាងផែនការ និងលទ្ធផលដែលសម្រេចបាន ក្នុងពេលកំណត់មួយ។ តារាងសុក្រិត (Logical framework) គួរមានឋានានុក្រមគម្រោង សូចនាករ វិធីវាស់វែង ការសន្មត់ទុកជាមុន និងភាពប្រថុយប្រថាន។ ការចូលរួមត្រួតពិនិត្យ និងវាយម្លៃត្រូវធ្វើឱ្យមានជាលក្ខណៈប្រព័ន្ធ ជាដំណើរការនៃការរៀនសូត្រ និងធ្វើការកែលំអ ឱ្យប្រសើរឡើង។ អង្គការសហគមន៍មូលដ្ឋានទាំងអស់ មានភាពទាក់ទិនទៅនឹងផ្នែកនេះជាពិសេសសហគមន៍សហគ្រាសខ្នាតតូច និងមធ្យម សហគមន៍កសិកម្ម ធនាគារភូមិ ក្រុមសន្សំប្រាក់ និងក្រុមទីផ្សារសហគមន៍។ ប្រធានបទជាក់លាក់សម្រាប់ផ្នែកនេះមានដូចជា ទស្សនៈ វិធីសាស្រ្ត និងឧបករណ៍ការចូលរួមត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងរបៀបនៃការធ្វើផែនការ ព្រមទាំងតារាងសុក្រិត ។

**ឆ. យុទ្ធសាស្រ្ត និងការធានានិរន្តរភាព** - (៧) អង្គការសហគមន៍មូលដ្ឋាន គួរបង្កើតផែនការយុទ្ធសាស្រ្ត និងនិរន្តរភាពរយៈពេលវែង អាចពី៥ ទៅ១០ឆ្នាំ ផ្អែកតាមតម្រូវការច្បាប់[39] ឬដោយអង្គការសហគមន៍មូលដ្ឋានខ្លួនឯង ដោយមានការសម្របសម្រួលពីអ្នកជំនាញ។ ផែនការយុទ្ធសាស្រ្ត និងនិរន្តរភាព គួរចែងពីបេសកម្ម គុណតម្លៃ ទស្សនៈ គោលដៅ គោលបំណង ពេលវេលា និងសកម្មភាព

---

[39] សហគមន៍ព្រៃឈើ សហគមន៍តំបន់ការពារធម្មជាតិ និងសហគមន៍នេសាទ ច្បាប់តម្រូវអោយបង្កើតផែនការដែលមានរយៈពេល៥ឆ្នាំ។

ចម្បងៗ ដែលអង្គការសហគមន៍មូលដ្ឋាន ចង់បាន ឬស្រមើស្រមៃក្នុងការឱ្យសម្រេចបាន ក្នុងរយៈពេល៥ ឬ១០ឆ្នាំទៅមុខ។ ផែនការយុទ្ធសាស្ត្រ ត្រូវមានការចូលរួមពីសមាជិក សមាជិកាយ៉ាងពេញលេញ ក្នុងការពិគ្រោះយោបល់ ក្នុងដំណើរការចងក្រង។ ទន្ទឹមនឹងនោះ ផ្នែកសំខាន់ នៃផែនការយុទ្ធសាស្ត្ររយៈពេលវែង និងនិរន្តរភាព ត្រូវបិទនៅទីស្នាក់ការអង្គការសហគមន៍មូលដ្ឋាន ដើម្បីសមាជិក ឬអ្នកពាក់ព័ន្ធអាចមើលឃើញ។ ផែនការយុទ្ធសាស្ត្រ ត្រូវធ្វើការត្រួពិនិត្យឡើងវិញ រៀងរាល់មួយឆ្នាំម្តង ព្រមទាំងធ្វើការកែលំអឱ្យស្របតាមស្ថានភាពសង្គម និងសេដ្ឋកិច្ច ដែលមានការរីកចម្រើន។ អង្គការសហគមន៍មូលដ្ឋាន ដែលមានភាពទាក់ទិនទៅ ដូចជាសហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍ក្នុងតំបន់ការពារធម្មជាតិ សហគមន៍កសិកម្ម សហគមន៍សហគ្រាសខ្នាតតូច និងមធ្យម ជាដើម។ ប្រធានបទជាក់លាក់សម្រាប់ផ្នែកនេះមានដូចជា ទស្សនៈ និងវិធីសាស្ត្រ ព្រមទាំងទម្រង់ងាយៗ ក្នុងការសរសេរផែនការយុទ្ធសាស្ត្រ ដែលធានាដល់និរន្តភាពទាំងស្ថាប័ន និងហិរញ្ញវត្ថុអង្គការសហគមន៍មូលដ្ឋាន។

<u>**ជ.ការពង្រឹងសមត្ថភាព និងការយល់ដឹង**</u>-(៨) អង្គការសហគមន៍មូលដ្ឋាន គួរមានផែនការពង្រឹងស្ថាប័ន ការកសាងសមត្ថភាព និងការបង្កើនការយល់ដឹង។ ផែនការនេះត្រូវបែងចែកឱ្យច្បាស់លាស់ពីសកម្មភាពពង្រឹងស្ថាប័ន ការកសាងសមត្ថភាព និងការបង្កើនការយល់ដឹង តាមការផ្សព្វផ្សាយ។ល។ ការពង្រឹងស្ថាប័ន និងការកសាងសមត្ថភាព គួរផ្តោតយកចិត្តទុកដាក់ តែលើគណៈកម្មការគ្រប់គ្រង ក្នុងការអនុវត្តតួនាទី និងភារកិច្ច ព្រមទាំងភាពជាមេដឹកនាំ ខណៈដែលការបង្កើនការយល់ដឹង ផ្តោតការយកចិត្តទុកដាក់ លើសមាជិកទាំងអស់។ ប្រធានបទសំខាន់ៗ ក្នុងការកសាងសមត្ថភាព គួរអនុវត្តន៍ឱ្យមានស្តង់ដារ និងលំដាប់លំដោយ តាមរយៈការប៉ាន់ប្រមាណពីតម្រូវការ ការរៀបចំផែនការកសាងសមត្ថភាព ការរៀបចំឯកសារសម្របសម្រួល ឯកសារមេរៀន ទម្រង់បែបបទវាយតម្លៃ ការបង្កើតប្រព័ន្ធផ្ទុកទិន្នន័យការកសាងសមត្ថភាពតាមបែបសាមញ្ញ។ល។ អង្គការសហគមន៍មូលដ្ឋានទាំងអស់ មានភាពទាក់ទិនទៅនឹងផ្នែកនេះ ជាពិសេសសហគមន៍កសិកម្ម ធនាគារភូមិ សហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍ក្នុងតំបន់ការពារធម្មជាតិ សហគមន៍អេកូទេសចរណ៍ធម្មជាតិ និងសហគមន៍សហគ្រាសខ្នាតតូច និងមធ្យមជាដើម។ ប្រធានបទជាក់លាក់សម្រាប់ផ្នែកនេះមានដូចជា ទស្សនៈ វិធីសាស្ត្រ ប្រធានបទ និងឧបករណ៍សំខាន់ៗ ក្នុងការពង្រឹងសមត្ថភាព និងបង្កើនការយល់ដឹងរបស់អង្គការសហគមន៍មូលដ្ឋាន។

<u>**ឈ. ភាពជាអ្នកដឹកនាំ**</u> -(៩) អង្គការសហគមន៍មូលដ្ឋាន គួរមានយន្តការក្នុងការពង្រឹងជួរថ្នាក់ដឹកនាំ គណៈកម្មការអង្គការសហគមន៍មូលដ្ឋាន តាមរយៈការបង្កើតអោយមានវគ្គបណ្តុះបណ្តាល ពីទស្សនៈ គោលការណ៍ និងវិធីសាស្ត្រក្នុងការដឹកនាំ អង្គការសហគមន៍មូលដ្ឋាន អោយមានប្រសិទ្ធភាពខ្ពស់។ ការពង្រឹងភាពជាអ្នកដឹកនាំនេះ រាប់បញ្ចូលទាំងវិធីសាស្ត្រដោះស្រាយ និងការសម្របសម្រួលបញ្ហាផ្ទៃក្នុង ព្រមទាំងនិតិវិធីនៃការដឹកនាំតាមបែបប្រជាធិបតេយ្យ និងដោយមានការចូលរួម។

ការផ្លាស់ប្តូរអាកប្បកិរិយា និងឥរិយាបថក្នុងការដឹកនាំអង្គការសហគមន៍មូលដ្ឋាន ដែលមានគុណភាពឆ្លើយតបទៅនឹងស្ថានភាព និងតម្រូវការនាពេលបច្ចុប្បន្ន និងអនាគត។ អង្គការសហគមន៍មូលដ្ឋានទាំងអស់ មានភាពទាក់ទិនទៅនឹងផ្នែកនេះ ជាពិសេសសហគមន៍កសិកម្ម ធនាគារភូមិ សហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍ក្នុងតំបន់ការពារធម្មជាតិ សហគមន៍អេកូទេសចរណ៍ធម្មជាតិ និងសហគមន៍សហគ្រាសខ្នាតតូច និងមធ្យមជាដើម។ ប្រធានបទជាក់លាក់សម្រាប់ផ្នែកនេះមានដូចជា និយមន័យ តួនាទីក្នុងភាពជាអ្នកដឹកនាំ បែបផែននៃភាពជាអ្នកដឹកនាំ ការដឹកនាំរួមគ្នា គោលការណ៍ណែនាំ នៃភាពជាអ្នកដឹកនាំ និងលក្ខណៈសម្បត្តិរបស់អ្នកដឹកនាំល្អ។

<u>**៣. ការគោរពតាមតួនាទី និងភារកិច្ច**</u> -(១០) អង្គការសហគមន៍មូលដ្ឋាន គួរមានកម្មវិធីក្នុងការបណ្តុះបណ្តាល និងរំលឹកឡើងវិញជាញឹកញាប់ និងជាប្រចាំពីភារកិច្ចសំខាន់ៗ ដល់សមាសភាពគណៈកម្មការគ្រប់គ្រងអង្គការសហគមន៍មូលដ្ឋានដូចជា ប្រធាន អនុប្រធាន ហិរញ្ញិក លេខា និងសមាជិក ដើម្បីអោយពួកគាត់អាចអនុវត្តន៍ទៅបាន និងមានប្រសិទ្ធិភាព ដូចដែលមានចែងក្នុងបទបញ្ជាផ្ទៃក្នុងសហគមន៍។ ការរំលឹកឡើងវិញពីតួនាទី និងភារកិច្ចសំខាន់ៗ អាចធ្វើឡើងជាទៀងទាត់ នៅឯកិច្ចប្រជុំប្រចាំខែ របស់គណៈកម្មការ ឬពេលសមាជប្រចាំឆ្នាំរបស់សមាជិក។ ទន្ទឹមនឹងនោះ គួរមានទម្រង់ក្នុងការកត់ត្រាទុក ពីភាពអសកម្មរបស់គណៈកម្មការ ដើម្បីធ្វើការកែលំអរ ក្នុងស្មារតីស្ថាបនាគ្នាទៅវិញទៅមកនៅឯកិច្ចប្រជុំអាណត្តិប្រចាំខែ។ អង្គការសហគមន៍មូលដ្ឋានទាំងអស់ មានភាពទាក់ទិនទៅនឹងផ្នែកនេះ ជាពិសេសសហគមន៍កសិកម្ម ធនាគារភូមិ សហគមន៍ព្រៃឈើ សហគមន៍នេសាទ សហគមន៍ក្នុងតំបន់ការពារធម្មជាតិ សហគមន៍អេកូទេសចរណ៍ធម្មជាតិ និងសហគមន៍សហគ្រាសខ្នាតតូច និងមធ្យមជាដើម។ ប្រធានបទជាក់លាក់សម្រាប់ផ្នែកនេះមានដូចជា ទស្សនៈស្តីពីតួនាទី សមាសភាពតួនាទីសំខាន់របស់អ្នកដឹកនាំគណៈកម្មការ ទស្សនៈស្តីពីភារកិច្ចសំខាន់ៗ របស់អ្នកដឹកនាំគណៈកម្មការ និង អ្វីដែលត្រូវធ្វើ និងអ្វីដែលមិនត្រូវធ្វើ៕

# ឯកសារយោង


- គោលការណ៍ណែនាំស្តីពី សហគមន៍ក្នុងតំបន់ធម្មជាតិ ដោយក្រសួងបរិស្ថាន ២០១៧
- Internal Assessment Report CBOs Functional, អង្គការ LIVE & LEARN Environmental Education, 2017
- សៀវភៅណែនាំពីការគ្រប់គ្រងហិរញ្ញវត្ថុ របស់កម្រងក្រុមជួយខ្លួនឯង អង្គការ LIVE & LEARN Environmental Education, 2017
- គោលការណ៍ណែនាំស្តីពី សហគមន៍ព្រៃឈើ ដោយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- គោលការណ៍ណែនាំស្តីពី សហគមន៍កសិកម្មដោយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- គោលការណ៍ណែនាំស្តីពី សហគមន៍នេសាទ ដោយក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ
- គោលការណ៍ប្រតិបត្តិល្អ របស់អង្គការសហគមន៍មូលដ្ឋាន ដោយអង្គការសហប្រតិបត្តិការណ៍ដើម្បីកម្ពុជា ២០១៧
- គោលការណ៍ អ្នកសម្របសម្រួល ដោយ CONCERN WORLDWIDE ឆ្នាំ១៩៩៧ ឆ្នាំ២០០២ និងឆ្នាំ២០១៦
- មេរៀន ភាពជាមេដឹកនាំ អង្គការ LIVE & LEARN Environmental Education, 2016
- ឯកសារជំនួយស្មារតី គម្រោងលើកកំពស់ជីវភាពប្រជាពលរដ្ឋ តាមរយៈការពង្រឹងសិទ្ធិអំណាចសហគមន៍ជនបទ អង្គការ LIVE & LEARN Environmental Education, 2016
- ឯកសារណែនាំស្តីពីការបង្កើត និងរៀបចំក្រុមសហគមន៍ អង្គការ LIVE & LEARN Environmental Education, 2016
- សៀវភៅណែនាំការសម្របសម្រួលការ គោលការណ៍បង្កើតសហគមន៍អេកូទេសចរណ៍ធម្មជាតិ ដោយ RECOFTC, ២០១៣
- គោលការបង្កើតសហគមន៍សហគមន៍គ្រាសខ្នាតតូច និងមធ្យមដោយ អង្គការអុកហ្វាមអង់គ្លេស ២០១០
- Community Based Capacity Development Guidelines, LWD, 2009
- Emerging Trends, Challenges and Innovations, Community Based Natural Resource Management (CBNRM) in Cambodia, CBNRM Learning Institute Volume I&II, 2009.
- ឯកសារបណ្តុះបណ្តាល អង្គការសហគមន៍មូលដ្ឋាន ដោយអង្គការសហគមន៍ព្រៃឈើអន្តរជាតិ ២០០៤
- សៀវភៅណែនាំការសម្របសម្រួលការ គោលការណ៍បង្កើតសហគមន៍សហគ្រាសព្រៃឈើ ដោយ FAO, 2000
- សៀវភៅណែនាំការសម្របសម្រួល ការបង្កើតផែនការប្រើប្រាស់ដីធ្លី ដោយមានការចូលរួម ដោយ CONCERN WORLDWIDE/ GTZ ២០០០

- Community Forestry at a Grassroots: Reflections and Future Direction in the Development of Community Forestry, RECOFTC Report No. 16, 1997
- សៀវភៅណែនាំ ការសម្របសម្រួលការបង្កើតសហគមន៍ព្រៃឈើ ដោយ CONCERN WORLDWIDE ១៩៩៧។

គេហទំព័រដែលបានធ្វើការស្រាវជ្រាវ

- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា: http://www.cambodiainvestment.gov.kh/
- ក្រសួងមហាផ្ទៃ: https://www.interior.gov.kh/about
- វេទិកានៃអង្គការមិនមែនរដ្ឋាភិបាល ស្តីពីកម្ពុជា: http://www.ngoforum.org.kh/?lang=kh
- គណៈកម្មាធិការ សហប្រតិបត្តការដើម្បីកម្ពុជា: http://www.ccc-cambodia.org/kh
- Forum Syd: http://www.forumsyd.org/int/Cambodia/
- ក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ: http://www.maff.gov.kh/
- ក្រសួងបរិស្ថាន: http://www.moe.gov.kh/
- អង្គការសម្ព័ន្ធភាព ដើម្បីអភិរក្សធនធានជលផល: http://www.fact.org.kh/
- VBNK: http://www.vbnk.org/
- PACT International: http://www.pactcambodia.org/
- Live and Learn: http://www.livelearn.org/locations/cambodia
- Life With Dignity: http://www.lwd.org.kh/

# ឧបសម្ព័ន្ធ

## <u>ឧបសម្ព័ន្ធ១៖</u> រូបភាពសកម្មភាព នៃដំណើរពិគ្រោះយោបល់








**<u>ឧបសម្ព័ន្ធ២</u>៖ បញ្ជីសំណួរទី១**

ឈ្មោះអង្គការ/ សហគមន៍:………………………………… ……………………………….

ទីកន្លែង ភូមិ ឃុំ ស្រុក និងខេត្ត:…………………………………………………………….

ឈ្មោះ និងលេខទូរស័ព្ទទំនាក់ទំនង:…………………………………… …………………….

| ល.រ | ប្រធានបទ | សំណួរ | ពិន្ទុ |
|---|---|---|---|
| ១ | ការយល់ដឹងពីទស្សនៈ អង្គការសហគមន៍មូលដ្ឋាន | - អង្គការសហគមន៍មូលដ្ឋាន ត្រូវបានបង្កើតឡើង ដោយរបៀបណា?<br>- ……………………………………………………………………………………………………………………<br>- តើការបង្កើតអង្គការសហគមន៍មូលដ្ឋាន មានអត្ថប្រយោជន៍អ្វីខ្លះ?<br>- ……………………………………………………………………………………………………………………<br>- តើមានចំណុចខ្វះខាតអ្វីខ្លះ ក្នុងដំណាក់ការដំបូងនៃការរៀបចំបង្កើតអង្គការសហគមន៍មូលដ្ឋាន ?<br>- ……………………………………………………………………………………………………………………<br>- សំណូមពរ ការកសាងសមត្ថភាពលើចំណុចខាងលើ<br>- …………………………………………………………………………………………………………………… | - |
| ២ | ភាពស្របច្បាប់ និងការអភិវឌ្ឍស្ថាប័ន | - តើអង្គការសហគមន៍មូលដ្ឋាន ចុះបញ្ជី បានដោយរបៀបណា?<br>- ……………………………………………………………………………………………………………………<br>- តើរចនាសម្ព័ន្ធ អង្គការសហគមន៍មូលដ្ឋានមានរូបភាពបែបណា?<br>- ……………………………………………………………………………………………………………………<br>- តើរចនាសម្ព័ន្ធ អង្គការសហគមន៍មូលដ្ឋាន កើតឡើង ដោយរបៀបណា?<br>- ……………………………………………………………………………………………………………………<br>- សំណូមពរ ការកសាងសមត្ថភាពលើចំណុចខាងលើ<br>- ……………………………………………………………………… | - |

| | | | |
|---|---|---|---|
| | | ……………………………………………… | |
| ៣ | ការទំនាក់ទំនង កិច្ចសហប្រតិបត្តិការ និងបណ្តាញ | - តើអង្គការសហគមន៍មូលដ្ឋាន ធ្វើការទំនាក់ទំនងផ្ទៃក្នុង និងស្ថាប័នខាងក្រៅដោយរបៀបណា?<br>- ………………………………………………………………………………………………………………………<br>- តើអង្គការសហគមន៍មូលដ្ឋាន ធ្លាប់មានបទពិសោធន៍ ធ្វើកិច្ចសហប្រតិបត្តិការ និងបណ្តាញឬទេ?<br>- ………………………………………………………………………………………………………………………<br>- ហើយតើអង្គការសហគមន៍មូលដ្ឋាន បានទទួលប្រយោជន៍អ្វីខ្លះ ពីការសហប្រតិបត្តិការ និងបណ្តាញ?<br>- …………………………………………………………………………………………………………………………………<br>- សំណូមពរ ការកសាងសមត្ថភាពលើចំណុចខាងលើ<br>- ……………………………………………………………………………………………………………………… | - |
| ៤ | សមាជិក និងការគ្រប់គ្រងសមាជិក | - តើត្រូវធ្វើដូចម្តេច ដើម្បីអាចក្លាយជាសមាជិកភាពបាន?<br>- ………………………………………………………………………………………………………………………<br>- តើក្រុមសមាជិក អង្គការសហគមន៍មូលដ្ឋាន ត្រូវគ្រប់គ្រងដោយរបៀបណា?<br>- ………………………………………………………………………………………………………………………<br>- សំណូមពរ ការកសាងសមត្ថភាពលើចំណុចខាងលើ<br>- ……………………………………………………………………………………………………………………… | - |
| ៥ | ការគ្រប់គ្រងហិរញ្ញវត្ថុ | - តើអង្គការសហគមន៍មូលដ្ឋាន មានថវិកាឬទេ?<br>- ………………………………………………………………………………………………………………………<br>- បើមាន តើថវិកាទាំងនោះចាត់ចែងយ៉ាងត្រឹមត្រូវដោយរបៀបណា?<br>- ……………………………………………………………………… | - |

| | | | |
|---|---|---|---|
| | | ………………………………………………….<br>- តើមានការលំបាកអ្វីខ្លះ ក្នុងការចាត់ចែង និងគ្រប់គ្រងហិរញ្ញវត្ថុ?<br>- ……………………………………………………………………………<br>………………………………………………….<br>- សំណូមពរ ការកសាងសមត្ថភាពលើចំណុចខាងលើ<br>- ……………………………………………………………………………<br>…………………………………………………. | |
| ៦ | គណនេយ្យភាព និង តម្លាភាព | - តើអង្គការសហគមន៍មូលដ្ឋាន មានគោលការណ៍ ឬនិតិវិធី ចាត់ចែងហិរញ្ញវត្ថុឬទេ?<br>- ……………………………………………………………………………<br>………………………………………………….<br>- តើនរណា ជាអ្នកគ្រប់គ្រងសាច់ប្រាក់?<br>- ……………………………………………………………………………<br>………………………………………………….<br>- តើមានការផ្សព្វផ្សាយពីរបាយការណ៍ហិរញ្ញវត្ថុដល់សមាជិក ឬទេ? ញឹកញាប់ប៉ុណ្ណា?<br>- ……………………………………………………………………………<br>………………………………………………….<br>- សំណូមពរ ការកសាងសមត្ថភាពលើចំណុចខាងលើ<br>- ……………………………………………………………………………<br>…………………………………………………. | - |
| ៧ | ការចូលរួមត្រួតពិនិត្យ និងវាយតម្លៃ | - តើអង្គការសហគមន៍មូលដ្ឋាន ត្រួតពិនិត្យសកម្មភាព ដោយរបៀបណា?<br>- ……………………………………………………………………………<br>………………………………………………….<br>- តើអង្គការសហគមន៍មូលដ្ឋាន ធ្វើការវាយតម្លៃសកម្មភាពរបស់ខ្លួនញឹកញាប់ប៉ុណ្ណា?<br>- ……………………………………………………………………………<br>………………………………………………….<br>- សំណូមពរ ការកសាងសមត្ថភាពលើចំណុចខាងលើ<br>- ……………………………………………………………………………<br>…………………………………………………. | - |

<table>
<tr><td>៨</td><td>យុទ្ធសាស្ត្រ និងនិរន្តរភាព</td><td>- តើអង្គការសហគមន៍មូលដ្ឋាន មានផែនការយុទ្ធសាស្ត្ររយៈពេលវែង និងនិរន្តរភាព ឬទេ?<br>- ……………………………………………………………………………<br>………………………………………………<br>- បើមាន តើមានកំណត់កត្តាអ្វីខ្លះ ដែលបានកំណត់ធ្វើឱ្យមានរយៈពេលវែង និងនិរន្តរភាព?<br>- ……………………………………………………………………………<br>………………………………………………<br>- តើនរណាខ្លះ ដែលបានចូលរួម រៀបចំបង្កើតផែនការយុទ្ធសាស្ត្រនោះ?<br>- ……………………………………………………………………………<br>………………………………………………<br>- សំណូមពរ ការកសាងសមត្ថភាពលើចំណុចខាងលើ<br>- ……………………………………………………………………………<br>………………………………………………</td><td>-</td></tr>
<tr><td>៩</td><td>ការពង្រឹងស្ថាប័ន និងការបង្កើនការយល់ដឹង</td><td>- អង្គការសហគមន៍មូលដ្ឋាន ត្រូវបានពង្រឹងដោយរបៀបណា?<br>- ……………………………………………………………………………<br>………………………………………………<br>- តើមានកត្តាសំខាន់ៗ អ្វីខ្លះ ក្នុងការពង្រឹងស្ថាប័ន?<br>- ……………………………………………………………………………<br>………………………………………………<br>- តើអង្គការសហគមន៍មូលដ្ឋាន ធ្លាប់ធ្វើការបង្កើនការយល់ដឹង ឬទេ? ធ្វើដោយរបៀបណា?<br>- ……………………………………………………………………………<br>………………………………………………<br>- សំណូមពរ ការកសាងសមត្ថភាពលើចំណុចខាងលើ<br>- ……………………………………………………………………………<br>………………………………………………</td><td>-</td></tr>
<tr><td colspan="4"><u>សំណូមពរ ឬយោបល់បន្ថែម</u><br>…………………………………………………………………………………………………………………………<br>………………………………………………………………………………………………………………………។</td></tr>
</table>

**បញ្ជីសំណួរទី២ (សម្រាប់បំពេញមុនពេលសិក្ខាសាលាពិគ្រោះយោបល់)**

| | |
|---|---|
| ឈ្មោះសហាគមន៍ និងទីតាំង | |
| ចំនួនគណៈកម្មការ (ប្រុស/ស្រី) | |
| ចំនួនសមាជិក(ប្រុស/ស្រី) | |
| កាលបរិច្ឆេទបង្កើត | |
| ប្រភេទ ឬវិស័យ | |

<u>គោលបំណងនៃការបង្កើតអង្គការសហាគមន៍មូលដ្ឋាន:</u>

.......................................................................................................................................................

.......................................................................................................................................................

.................. .................. .................. .................. .................. .................. ..............

<u>ភាពជោគជ័យ: (៣ចំណុចសំខាន់)</u>

.......................................................................................................................................................

.......................................................................................................................................................

..........................................................................................................................................

<u>ការលំបាក ឬចំណុចត្រូវធ្វើឱ្យប្រសើរឡើង: (៣ចំណុចសំខាន់)</u>

.......................................................................................................................................................

.......................................................................................................................................................

..........................................................................................................................................

<u>សំណូមពរ លើការកសាងសមត្ថភាព (ប្រធានបទ និងវិធីសាស្ត្រ)</u>

.......................................................................................................................................................

.......................................................................................................................................................

.................................................................................................................................................

**សូមអរគុណ!**